សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Science Economiques

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# នីតិវិធីពិសេសក្នុងការអនុវត្តទៅលើ អនីតិជននៅក្នុងរឿងក្តីព្រហ្មទណ្ឌ

ស្រាវជ្រាវចាប់ពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១


| | |
|---|---|
| ស្រាវជ្រាវដោយ | សាស្ត្រាចារ្យណែនាំ |
| និស្សិតឈ្មោះ លោក **ផល សុភ័ក្ររិទ្ធ** | លោក **ជ្រ សុភារ៉ា** |
| កញ្ញា **សុវណ្ណ ថាវឡ្យន៍** | |
| ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ** | ឆ្នាំចូលសិក្សា ២០១៧ |
| ជំនាន់ទី២១ | ឆ្នាំសរសេរសារណា ២០២១ |

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**
Université Royale de Droit et des Science Economiques
Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# នីតិវិធីពិសេសក្នុងការអនុវត្តទៅលើ អនីតិជននៅក្នុងរឿងក្ដីព្រហ្មទណ្ឌ

ស្រាវជ្រាវចាប់ពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១

| | |
|---|---|
| ស្រាវជ្រាវដោយ | សាស្ត្រាចារ្យណែនាំ |
| និស្សិតឈ្មោះ លោក **ផល់ សុភ័ក្រ្តរិទ្ធ** | លោក **ជ្រុ សុភាព៉** |
| កញ្ញា **សុវណ្ណា ថាវឡ្យន៍** | |
| ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ** | ឆ្នាំចូលសិក្សា ២០១៧ |
| ជំនាន់ទី២១ | ឆ្នាំសរសេរសារណា ២០២១ |

# សេចក្តីថ្លែងអំណរគុណ

ជាដំបូងយើងខ្ញុំឈ្មោះ **ផល់ សុភ័ក្ររិទ្ធ** និងឈ្មោះ **សុវណ្ណ ថាវឌ្ឍន៍** ជានិស្សិត ថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី២១ ក្នុងឆ្នាំសិក្សា២០១៧-២០២១ សូមសម្តែងនូវកតញ្ញូ និងដឹងគុណដ៏ជ្រាលជ្រៅមិនអាចកាត់ថ្លៃបានដល់លោកអ្នកមានគុណទាំងបួន គឺលោកឪពុក **សម នៀង** អ្នកម្តាយ **ស៊ូ ណារីន** លោកឪពុក **ថៃ សុវណ្ណ** និងអ្នកម្តាយ **ភាន់ ទេពសិរី** ដែលបានផ្តល់កំណើតដល់រូបយើងខ្ញុំ និងចិញ្ចឹមបីបាច់ថែរក្សា ព្រមទាំងបានផ្តល់នូវការស្នាក់នៅ និងការរៀនសូត្រតាំងពីថ្នាក់មត្តេយ្យនៅបឋមវ័យសិក្សារហូតមកដល់កម្រិតថ្នាក់បរិញ្ញាបត្រ និងបានរួមចំណែកទាំងការផ្តល់នូវកម្លាំងចិត្ត ការអប់រំ ប្រៀនប្រដៅ និងផ្តល់នូវព្រហ្មវិហារធម៌ពីសំណាក់បុព្វញាតិ និងសាខាញាតិ។ សេចក្តីដឹងគុណទាំងអស់នេះ ពិតជាធំធេងពុំអាចកាត់ថ្លៃបានឡើយសម្រាប់ជីវិតពួកយើងទាំងពីរ។

យើងខ្ញុំសូមថ្លែងអំណរគុណដល់ ក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំង សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បានផ្តល់នូវកន្លែងបណ្តុះបណ្តាលចំណេះដឹង សមត្ថភាព ក៏ដូចជាការស្រាវជ្រាវ ក្នុងផ្នែកនីតិសាស្ត្រ នេះតាំងពីឆ្នាំទីមួយរហូតមកដល់ការបញ្ចប់ថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ ប្រកបដោយភាពជោគជ័យ ផ្លែផ្កា និងសមិទ្ធផលចំណេះដឹងយ៉ាងគាប់ប្រសើរ។

យើងខ្ញុំសូមថ្លែងអំណរគុណដល់ ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ថ្នាក់ដឹកនាំ គណៈគ្រប់គ្រង និង លោក លោកស្រីសាស្ត្រាចារ្យ នៃសាកលវិទ្យាល័យភូមិន្ទនីតិស្រាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលលោក លោកស្រី បានធ្វើការផ្តល់នូវចំណេះដឹង ការអប់រំ និងសីលធម៌ដល់យើងខ្ញុំទាំងពីរក្នុងរយៈពេលជិត ៤ឆ្នាំនេះ។

លើសពីនេះទៅទៀត យើងខ្ញុំសូមថ្លែងអំណរគុណដល់គណៈគ្រប់គ្រង នៃបណ្ណាល័យនីតិសាស្ត្រ ដែលរៀបចំ គ្រប់គ្រងឯកសារច្បាប់ សៀវភៅមេរៀន ឯកសារស្រាវជ្រាវ ក៏ដូចជាជួយសម្រួលក្នុងការស្រាវជ្រាវតាក់តែងសារណារបស់យើងខ្ញុំ។

ពិសេសជាងនេះទៅទៀត យើងខ្ញុំសូមថ្លែងអំណរអរគុណយ៉ាងជ្រាលជ្រៅដល់ លោកសាស្ត្រាចារ្យ **ជ្រឹ សុភារ៉ា** ដែលជាសាស្ត្រាចារ្យណែនាំ និងដឹកនាំការសរសេរសារណារបស់យើងខ្ញុំ ដោយលោកបានខិតខំទាំងកម្លាំងកាយ កម្លាំងចិត្ត និងពេលវេលាដ៏មានតម្លៃ ក្នុងការផ្តល់នូវដំបូន្មាន គំនិត ចំណេះដឹង យោបល់ ការលើកទឹកចិត្ត និងការបង្ហាញផ្លូវដល់យើងខ្ញុំ ចាប់ពីថ្ងៃចាប់ផ្តើមសរសេរ រហូតដល់ទទួលបានស្នាដៃមួយនេះជាស្ថាពរ ដែលគុណទាំងនេះ គឺពិតជាមានតម្លៃវិសេសវិសាលឥតកាត់ថ្លៃបានមកលើយើងខ្ញុំ។

# អារម្ភកថា

យើងខ្ញុំឈ្មោះ **ផល់ សុភ័ក្រវិទ្ធ** និងឈ្មោះ **សុវណ្ណា ថាវឌ្ឍន៍** និស្សិតនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាន់ទី ២១ បានឆ្លងកាត់ការសិក្សា និងការបណ្តុះបណ្តាលក្នុងថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រអស់រយៈពេល ៤ឆ្នាំមកហើយ។ តាមរយៈការសិក្សារយៈពេល ៤ ឆ្នាំនេះ ឃើញថាការសិក្សាបរិញ្ញាបត្រនីតិសាស្ត្រ ផ្នែកនីតិសាស្ត្រនេះ ពិតជាផ្តល់នូវសារៈសំខាន់យ៉ាងខ្លាំងសម្រាប់យើងខ្ញុំក្នុងនាមជាយុវជនជំនាន់ក្រោយ។ ជាក់ស្តែង យើងខ្ញុំបានទទួលបាននូវចំណេះដឹង និងបទពិសោធន៍ជាច្រើនពីការសិក្សាកន្លងមកនេះ។ ទោះបីជាកាលៈទេសៈខ្លះ យើងខ្ញុំបានជួបប្រទះនូវឧបសគ្គ និងការលំបាកយ៉ាងណាក៏ដោយ ក៏យើងខ្ញុំនៅតែព្យាយាមតស៊ូក្រេបយកចំណេះវិជ្ជា ដោយមិនព្រមបោះបង់នូវការសិក្សាដ៏គាប់ប្រសើរនេះឡើយ ក្នុងគោលបំណងមួយដើម្បីបញ្ចប់ថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រនេះឲ្យបានជោគជ័យជាស្ថាពរ។ ទន្ទឹមនឹងការបញ្ចប់បរិញ្ញាបត្រឲ្យបានជោគជ័យផងដែរ យើងខ្ញុំក៏មានគោលបំណងក្នុងការបញ្ចប់ការសិក្សាដោយការសរសេរសារណាមួយដ៏សមប្រកប ដែលជាលទ្ធផល និងជាស្នាដៃដ៏សំខាន់មួយសម្រាប់យើងខ្ញុំបន្ទាប់ពីបានសិក្សាក្រេបយកចំណេះដឹងអស់រយៈពេល ៤ឆ្នាំកន្លងមកនេះ។

ដោយឡែក ដោយសារតែមានការឆ្លងកាត់ការសិក្សាកន្លងមកនូវមុខវិជ្ជាសំខាន់ៗជាច្រើនក្នុងបរិញ្ញាបត្រនីតិសាស្ត្រ ផ្នែកនីតិសាស្ត្រនេះ យើងខ្ញុំមានការចាប់អារម្មណ៍យ៉ាងខ្លាំងលើមុខវិជ្ជានីតិវិធីព្រហ្មទណ្ឌ ព្រោះថាមុខវិជ្ជានេះ គឺជាមុខវិជ្ជា ដែលសិក្សាទាក់ទងនឹងនីតិវិធីព្រហ្មទណ្ឌ ដែលជាវិធានច្បាប់មួយដ៏សំខាន់ក្នុងចំណោមវិធានច្បាប់ផ្សេងៗទៀត សម្រាប់គ្រប់គ្រងសង្គម ដោយយើងខ្ញុំបានសិក្សាទាក់ទងនឹងនីតិវិធីដែលត្រូវអនុវត្តពិសេស គឺបញ្ញត្តិចែងអំពីនីតិវិធីនៃដំណាក់កាលទាំងបួនក្នុងរឿងព្រហ្មទណ្ឌ។ ជាពិសេសនោះ គឺយើងខ្ញុំបានសិក្សាអំពីដំណាក់ពិសេសនីមួយៗដែលអនុវត្តទៅលើអនីតិជននៅគ្រប់ដំណាក់កាលនីតិវិធី។ ហេតុនេះហើយទើបយើងខ្ញុំសម្រេចចិត្តជ្រើសរើសយក ប្រធានបទមួយគឺ “**នីតិវិធីពិសេសក្នុងការអនុវត្តទៅលើអនីតិជននៅក្នុងរឿងក្តីព្រហ្មទណ្ឌ**” មកធ្វើការសិក្សាស្រាវជ្រាវ។

មូលហេតុ ដែលយើងខ្ញុំសម្រេចចិត្តជ្រើសរើសយកប្រធានបទមួយនេះមកធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងឡើងនោះគឺ ដោយសារយើងខ្ញុំមានបំណងក្នុងការទទួលបាននូវបទពិសោធន៍ និងចំណេះដឹងកាន់តែស៊ីជម្រៅអំពីការអនុវត្តពិសេសនេះ។ ទោះបីជាយ៉ាងណាក៏ដោយ យើងខ្ញុំសង្ឃឹមថាការស្រាវជ្រាវថ្មីនេះនឹងមានអ្វីដែលថ្មីខុសពីការស្រាវជ្រាវមុនៗ ដោយសារតែមានការបញ្ចូលនូវការអនុវត្តជាក់ស្តែងខ្លះៗ នៃការប្រព្រឹត្តទៅរបស់តុលាការមួយចំនួនយកមកបកស្រាយ។

ដោយហេតុថា ប្រធានបទ “**នីតិវិធីពិសេសក្នុងការអនុវត្តទៅលើអនីតិជននៅក្នុងរឿងក្តីព្រហ្មទណ្ឌ**” មានភាពធំទូលាយ ដូច្នេះយើងខ្ញុំសូមអភ័យទោសជាមុនប្រសិនបើមានភាពខ្វះខាតត្រង់ចំណុចណាមួយ ជា

ពិសេសរាល់ចំណុចដែលទាក់ទងនឹងការអនុវត្តជាក់ស្តែង ដោយហេតុថា យើងខ្ញុំជានិស្សិត ដែលពុំទាន់ឆ្លងកាត់ការអនុវត្តជាក់ស្តែងនៅឡើយ ដែលនាំឲ្យការស្រាវជ្រាវរបស់យើងខ្ញុំនៅមានកម្រិត។ ប៉ុន្តែ ទោះបីជាយ៉ាងណាក៏ដោយ ក៏យើងខ្ញុំនៅតែសង្ឃឹមថាការស្រាវជ្រាវមួយនេះនឹងអាចផ្តល់នូវចំណេះដឹងបន្ថែមបន្តិចបន្តួចដល់អ្នកសិក្សា។

យើងខ្ញុំសូមទទួលការរិះគន់ដោយស្តាបនាពីសំណាក់ លោក លោកស្រីសាស្ត្រាចារ្យ បងៗ ប្អូនៗ មិត្តនិស្សិត ទាំងអស់ដែលបានអានស្នាដៃមួយនេះ និងរីករាយទទួលនូវរាល់កំហុសដែលកើតមានដោយអចេតនារបស់យើងខ្ញុំ។

# មាតិកា


**សេចក្តីផ្តើម** ........ ១

**ជំពូកទី១**

**ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន**

**ផ្នែកទី១. លក្ខខណ្ឌដែលនាំឲ្យមានការទទួលខុសត្រូវព្រហ្មទណ្ឌ** ........ ៥

១.១ លក្ខខណ្ឌអាយុក្រោម ១៤ឆ្នាំ ........ ៥

១.២. លក្ខខណ្ឌអាយុចាប់ពី ១៤ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ ........ ៦

**ផ្នែកទី២. កាលៈទេសៈនៃបទល្មើស និងបុគ្គលិកលក្ខណៈ** ........ ៧

២.១. កាលៈទេសៈនៃបទល្មើស ........ ៧

២.២. បុគ្គលិកលក្ខណៈរបស់អនីតិជន ........ ៨

**ជំពូកទី២**

**នីតិវិធីពិសេសក្នុងការអនុវត្តទៅលើអនីតិជន**

**ផ្នែកទី១. ដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ និងការស៊ើបអង្កេត** ........ ១០

១.១. សមាសភាពរបស់មន្ត្រីនគរបាលយុត្តិធម៌ ........ ១១

១.២. សមត្ថកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌ ........ ១១

១.៣. អំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌ ........ ១១

១.៣.១. ការចាប់ខ្លួន ........ ១១

១.៣.២. ការឆែកឆេរ ........ ១៣

១.៣.៣. ការឃាត់ខ្លួន ........ ១៣

១.៣.៤. ការជូនដំណឹង ........ ១៤

១.៣.៥. ការស្តាប់ចម្លើយ ........ ១៦

១.៣.៦. ការបញ្ចប់ និងការបញ្ជូនខ្លួនទៅតំណាងអយ្យការ ........ ១៦

**ផ្នែកទី២៖ ដំណាក់កាលអយ្យការ និងការចោទប្រកាន់** ........ ១៧

២.១. គោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់ ........ ១៧

២.២. សមត្ថកិច្ច និងអំណាចរបស់តំណាងអយ្យការ ........ ១៧

២.២.១. ការពិនិត្យឯកសារសំណុំរឿង និងការផ្ទៀងផ្ទាត់អាយុរបស់អនីតិជន ........ ១៧

២.២.២. ការស្តាប់ចម្លើយអនីតិជន ........ ១៨

២.៣. សេចក្តីសម្រេចរបស់តំណាងអយ្យការ ............................................................ ១៩
២.៣.១. ការសម្រេចចោទប្រកាន់ ............................................................ ១៩
២.៣.១.១. ការបើកការស៊ើបសួរ ............................................................ ២០
២.៣.១.២. ការបញ្ជូនទៅជំនុំជម្រះផ្ទាល់ ............................................................ ២០
២.៣.១.៣. នីតិវិធីក្នុងការបង្ហាញខ្លួនភ្លាម ............................................................ ២០
២.៣.២. ការសម្រេចមិនចោទប្រកាន់ ............................................................ ២០
២.៣.២.១. ការប្រើប្រាស់វិធានការបង្វែរ ............................................................ ២១
២.៣.២.២. ការតម្កល់រឿងទុកឥតចាត់ការ ............................................................ ២១
**ផ្នែកទី៣៖ ដំណាក់កាលស៊ើបសួរ** ............................................................ ២២
៣.១. កិច្ចស៊ើបសួរ ............................................................ ២២
៣.១.១ ការជូនដំណឹងអំពីការដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យ ............................................................ ២២
៣.១.២ ការប្រាប់អំពីសិទ្ធិរបស់អនីតិជន ............................................................ ២៣
៣.១.២ ការស្តាប់ចម្លើយ និងជំនួយរបស់មេធាវី ............................................................ ២៤
៣.២. អំណាចរបស់ចៅក្រមស៊ើបសួរ ............................................................ ២៥
៣.២.១. ការប្រើប្រាស់វិធានការបង្វែរ ............................................................ ២៥
៣.២.២ ការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ............................................................ ២៥
៣.២.៣. ការបង្គាប់ឲ្យដោះលែងឲ្យនៅក្រៅឃុំ ............................................................ ២៦
៣.៣ ការបិទការស៊ើបសួរ ............................................................ ២៦
៣.៣.១ ការលើកលែងការចោទប្រកាន់ ............................................................ ២៧
៣.៣.២ ការបញ្ជូនរឿងទៅជំនុំជម្រះ ............................................................ ២៧
**ផ្នែកទី៤. ដំណាក់កាលចៅក្រមជំនុំជម្រះ និងការជំនុំជម្រះ** ............................................................ ២៨
៤.១ សមត្ថកិច្ចរបស់ចៅក្រមជំនុំជម្រះ ............................................................ ២៨
៤.២ នីតិវិធីមុនពេលសវនាការរឿងក្តីអនីតិជន ............................................................ ២៨
៤.៣ ដំណើរការសវនាការ ............................................................ ២៨
៤.៤ ការប្រកាសសាលក្រមរឿងក្តីរបស់អនីតិជន ............................................................ ៣០
៤.៤.១ ការឲ្យរួចផុតពីបទចោទ ............................................................ ៣០
៤.៤.២ ការផ្តន្ទាទោស និងការកំណត់ឲ្យសងសំណងរដ្ឋប្បវេណី ............................................................ ៣០

៤.៤.៣ ការប្រើប្រាស់វិធានបង្វែរ......................................................................................................................៣០

**ជំពូកទី៣**

**ការប្រើប្រាស់វិធានការបង្វែរ**

**ផ្នែកទី១៖ របៀបអនុវត្ត** ............................................................................................................ ៣១
**ផ្នែកទី២៖ ការមិនគោរពតាមកាតព្វកិច្ច និងបរាជ័យក្នុងការអនុវត្ត**.................................... ៣២
២.១ ការមិនគោរពតាមកាតព្វកិច្ចនៅក្នុងវិធានការបង្វែរ................................................................. ៣២
២.២ អានុភាពនៃបរាជ័យនៅក្នុងវិធានការបង្វែរ ......................................................................... ៣២
**សេចក្តីសន្និដ្ឋាន**......................................................................................................................... ៣៣
**អនុសាសន៍**.................................................................................................................................. ៣៤
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា

នៅលើសាកលលោក មិនថាប្រទេសណាក៏ដោយ របបនៃការដឹកនាំសង្គមបែបណាក៏ដោយ បែបកុំមុយនីស្តសក្តី ប្រជាធិបតេយ្យក្តី គេតែងតែបង្កើតច្បាប់មកសម្រាប់គ្រប់គ្រងសង្គម ដើម្បីកុំឲ្យសង្គមរបស់ខ្លួនមានភាពអាណាធិបតេយ្យ បង្កភាពមិនមានរបៀបរយ អសន្តិសុខ និងធ្វើឲ្យខូចខាតដល់សណ្តាប់ធ្នាប់សង្គម ឬការប្រើប្រាស់សិទ្ធិរបស់ខ្លួនដែលច្បាប់បានផ្តល់ឲ្យនោះហួសកម្រិត។ ជាការពិតណាស់ប្រទេសមួយចំនួន គ្រប់បទដ្ឋានគតិយុត្តទាំងអស់មានការបង្កើតនូវវិធាននៃការទទួលខុសត្រូវមួយចំនួន មិនថាជាប្រជាពលរដ្ឋរបស់ខ្លួន ឬជនជាតិបរទេស បានប្រព្រឹត្តអំពើណាមួយ ហើយបានបង្កផលប៉ះពាល់ដល់សង្គមរបស់ខ្លួន ឬប្រទេសគេ បុគ្គលនោះត្រូវទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើនោះ ចំណែកឯទណ្ឌកម្មក៏មានការអនុវត្តដូចគ្នាទៅលើបុគ្គលនោះផងដែរ ទណ្ឌកម្មទាំងនោះមានដូចជា ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ការទទួលខុសត្រូវផ្នែករដ្ឋប្បវេណី ចំពោះជនរងគ្រោះ ឬរដ្ឋ ជាដើម។ ផ្ទុយទៅវិញ បណ្តាប្រទេសមួយចំនួនក៏មិនតម្រូវឲ្យមានការទទួលខុសត្រូវចំពោះអំពើមួយចំនួនផងដែរ ដោយហេតុថាប្រទេសទាំងនោះមានការរីកចម្រើនគ្រប់វិស័យ មិនថាសេដ្ឋកិច្ច ពាណិជ្ជកម្ម ឬអប់រំនោះទេ ជាពិសេសទៀតនោះក៏មានសម្បត្តិធនធានធម្មជាតិជាច្រើន ដែលជាហេតុធ្វើឲ្យប្រទេសគេមានគ្រប់បែបយ៉ាង។ ដូច្នេះហើយបានជាគេចាត់ទុកអំពើមួយចំនួន មិនតម្រូវឲ្យមានការទទួលខុសត្រូវឡើយ។

ជាក់ស្តែងនៅក្នុងប្រទេសកម្ពុជា ច្បាប់នៃព្រះរាជាណាចក្រកម្ពុជា នៅពេលដែលបុគ្គលម្នាក់បានប្រព្រឹត្តបទល្មើស មិនថាជានីតិជន ឬអនីតិជនក្តី គឺត្រូវទទួលខុសត្រូវចំពោះអំពើនោះ ទាំងផ្នែកព្រហ្មទណ្ឌ និងផ្នែករដ្ឋប្បវេណីចំពោះជនរងគ្រោះ ឬការដាក់ទណ្ឌកម្មផ្សេងទៀត តាមរយៈការដាក់ពន្ធនាគារ ដើម្បីយកបុគ្គលនោះមកធ្វើការអប់រំណែនាំ ឲ្យដឹងអំពីកំហុសរបស់ខ្លួន ហើយក្រោយពីការអនុវត្តទោសរួចហើយគេនឹងបញ្ជូនបុគ្គលនោះឲ្យចូលមករស់នៅក្នុងសង្គមវិញ ដើម្បីធ្វើជាពលរដ្ឋល្អដែលមានប្រយោជន៍ សម្រាប់សង្គម គ្រួសារ និងមិត្តភក្តិជាដើម។ ប៉ុន្តែក៏មានករណីមួយចំនួនខ្លះដែលតម្រូវឲ្យមានលក្ខខណ្ឌមួយចំនួនដែលច្បាប់បានកំណត់។ គួរយ៉ាងនៅក្នុងលក្ខខណ្ឌនៃការទទួលខុសត្រូវចំពោះបុគ្គលទាំងពីរនេះ យើងឃើញមានលក្ខខណ្ឌនៃការទទួលខុសត្រូវ និងរបបនៃការប្រកាសទោសសម្រាប់បុគ្គលទាំងពីរ និងជាពិសេសនោះគឺការអនុវត្តទោស ចាប់តាំងពីដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ រហូតដល់ដំណាក់កាលជំនុំជម្រះ និងការអនុវត្តទោសឃើញថាមានលក្ខណៈខុសគ្នាផងដែរ។

ការតម្រូវឲ្យមានការទទួលខុសត្រូវនេះគឺមានគោលបំណងឲ្យបុគ្គលដែលបានប្រព្រឹត្តអំពើល្មើសនោះទទួលខុសត្រូវនូវអំពើរបស់ខ្លួនដែលបានប្រព្រឹត្ត និងចូលរួមបង្ការកុំឲ្យមានបទល្មើសដទៃទៀតកើតឡើង

នៅក្នុងសង្គមបន្តទៀតផងដែរ។ ម្យ៉ាងវិញទៀតការអនុវត្តនីតិវិធីរបស់តុលាការ ក៏បានរួមចំណែកក្នុងការធានានូវការផ្តល់សេវាកម្មយុត្តិធម៌ដល់បុគ្គលទាំងពីរទាំងគ្រប់ដំណាក់កាល ក្នុងគោលបំណងបង្ក្រាប និងទប់ស្កាត់នូវអំពើល្មើសទាំងនោះដែលបានកើតឡើងផងដែរ។

នៅពេលដែលសង្គមមួយគ្មានភាពអាណាធិបតេយ្យ អសន្តិសុខសង្គម គ្មានរបៀបរៀបរយ គ្មានបទល្មើសកើតឡើង ហើយប្រជាពលរដ្ឋបានយល់ដឹងអំពីច្បាប់ និងគោរពច្បាប់ដែលរដ្ឋបង្កើតឡើង នឹងធ្វើឲ្យការដឹកនាំសង្គមមួយក្លាយជាប្រទេសនីតិរដ្ឋ ពោលគឺនឹងក្លាយជាប្រទេសមួយដែលយកច្បាប់ជាធំ។

## ២. ចំណោទបញ្ហា នៃការស្រាវជ្រាវ

នីតិវិធីពិសេសក្នុងការអនុវត្តទៅលើអនីតិជនមានសារៈសំខាន់ណាស់ ដែលការអនុវត្តនេះតម្រូវឲ្យមានការដកហូតនូវសិទ្ធិសេរីភាព ឬវិធានការផ្សេងៗដល់បុគ្គលនោះ នៅក្នុងរយៈពេលណាមួយដែលច្បាប់បានកំណត់។ ការដកហូតនេះ គឺក្នុងករណីដែលអនីតិជននោះបានប្រព្រឹត្តអំពើណាមួយដែលប៉ះពាល់ដល់សមាជិកនៃសង្គម ហើយច្បាប់បានអនុញ្ញាតឲ្យធ្វើការដកហូតសិទ្ធិរបស់អនីតិជននោះបានផងដែរ ក្នុងគោលបំណងអប់រំអនីតិជននោះឲ្យមានការកែប្រែ និងបញ្ជូនជននោះឲ្យត្រឡប់ចូលមករស់នៅក្នុងសង្គមវិញ ដើម្បីក្លាយទៅជាពលរដ្ឋល្អនៅក្នុងសង្គម។

ហេតុដូច្នេះប្រធានបទ "**នីតិវិធីពិសេសក្នុងការអនុវត្តទៅលើអនីតិជននៅក្នុងរឿងក្តីព្រហ្មទណ្ឌ**" ត្រូវបានជ្រើសរើស និងបានតាក់តែងឡើង ដើម្បីឲ្យសិស្ស និស្សិតជំនាន់ក្រោយ ក៏ដូចជាសាធារណៈជនដែលចង់ស្វែងយល់ អាចធ្វើការស្រាវជ្រាវឲ្យកាន់តែច្បាស់លាស់បន្ថែមទៀតចំពោះលក្ខខណ្ឌកិច្ចនីតិវិធីណាខ្លះដែលអាចអនុវត្តទៅលើអនីតិជន ព្រមទាំងនីតិវិធីក្នុងការអនុវត្តទៅលើអនីតិជនមានអ្វីខ្លះ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ក្នុងការសិក្សាស្រាវជ្រាវ រៀបចំតាក់តែងនូវឯកសារ និងធ្វើការចងក្រងនេះឡើង គឺដើម្បីបកស្រាយនូវបញ្ហាចម្ងល់ ធ្វើការពង្រីកនូវចំណេះដឹងបន្ថែម និងទុកជាស្នាដៃសម្រាប់ខ្លួនឯង ជាពិសេសគឺសម្រាប់ទុកជូនសិស្ស និស្សិតជំនាន់ក្រោយ ព្រមទាំងសាធារណៈជនទាំងឡាយដែលមានបំណងចង់ធ្វើការសិក្សាស្រាវជ្រាវ និងស្វែងយល់អំពីប្រធានបទនេះបន្ថែមទៀត។

## ៤. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

ដើម្បីធ្វើការឆ្លើយតបទៅនឹងប្រធានបទ ដែលបានលើកឡើងក្នុងចំណោមបញ្ហាខាងលើនេះ សារណានេះត្រូវបានស្រាវជ្រាវទៅលើឯកសារមូលដ្ឋានមួយចំនួនដូចជា ក្រមព្រហ្មទណ្ឌ ឆ្នាំ២០១០ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦ និងឯកសារបទដ្ឋានគតិយុត្តិទាំងឡាយ ដែលបានលើកឡើងនៅក្នុងឯកសារយោងនេះស្រាប់ ដើម្បីសរសេរសារណានេះឡើង។

នៅក្នុងការសរសេរសារណានេះ គឺលើកពីការពាក់ព័ន្ធទាំងឡាយ ដែលទាក់ទងទៅនឹងទៅនឹង នីតិវិធីពិសេសក្នុងការអនុវត្តទៅលើអនីតិជននៅក្នុងរឿងក្តីព្រហ្មទណ្ឌតែប៉ុណ្ណោះ។

## ៥. សារៈសំខាន់ នៃការស្រាវជ្រាវ

តាមរយៈការសរសេរសារណានេះ អាចជាជំនួយស្មារតីដល់បងប្អូន សិស្ស និស្សិត ក៏ដូចជាសាធារណៈជនដទៃ ព្រមទាំងផ្តល់នូវចំណេះដឹងដល់ការសិក្សាស្រាវជ្រាវ និងយល់ដឹងអំពីនីតិវិធីពិសេសក្នុងការអនុវត្តទៅលើអនីតិជន ថាតើមានលក្ខណៈត្រឹមត្រូវ និងស្របតាមបញ្ញត្តិច្បាប់ដែរឬទេ?សារណានេះក៏បានបញ្ចូលនូវឯកសារផ្លូវការដែលមានអត្ថប្រយោជន៍ និងអាចជឿជាក់បានមួយចំនួនទុកជាឧទាហរណ៍ជាក់ស្តែងសម្រាប់ឲ្យសាធារណជនដែលមានបំណងស្រាវជ្រាវបន្ថែម និងងាយស្រួលយល់

## ៦. រចនាសម្ព័ន្ធ នៃការស្រាវជ្រាវ

ទាក់ទងទៅនឹងប្រធានបទ **“នីតិវិធីពិសេសក្នុងការអនុវត្តទៅលើអនីតិជន”** នៅក្នុងចំណុចបន្ទាប់ នឹងធ្វើការបកស្រាយនូវចំណុចសំខាន់ទាក់ទងនឹង៖

(**ជំពូកទី១**) **ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន**

(**ជំពូកទី២**) **នីតិវិធីពិសេសក្នុងការអនុវត្តទៅលើអនីតិជន**

(**ជំពូកទី៣**) **ការប្រើប្រាស់វិធានការបង្ខំ**

# ជំពូកទី១

# ការទទួលខុសត្រូវ

# ព្រហ្មទណ្ឌរបស់អនីតិជន

# ជំពូកទី១
# ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន

នៅក្នុងនីតិវិធីព្រហ្មទណ្ឌ ជាទូទៅនៅពេលដែលមានបទល្មើសមួយបានកើតឡើង ទោះបីជាអំពើនោះត្រូវបានប្រព្រឹត្តដោយចេតនាក្តី ឬអចេតនាក្តី ហើយបង្កជាព្យសនកម្មដល់អ្នកដទៃ គឺជាលក្ខខណ្ឌមួយនៃការទទួលខុសត្រូវព្រហ្មទណ្ឌ។ នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌគឺកំណត់ចាប់ពីអាយុ ១៨ (ដប់ប្រាំបីឆ្នាំ) ឡើងទៅ[1]។ ប៉ុន្តែតុលាការអាចប្រកាសទោសព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំឡើងបានផងដែរ ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជននោះតម្រូវ។

## ផ្នែកទី១ លក្ខខណ្ឌដែលនាំឲ្យមានការទទួលខុសត្រូវព្រហ្មទណ្ឌ

ផ្អែកតាមគោលការណ៍នៃការទទួលខុសត្រូវព្រហ្មទណ្ឌ អាយុគឺជាលក្ខខណ្ឌមួយចំបងនៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ។ អាយុនៃការទទួលខុសត្រូវរបស់អនីតិជន ត្រូវបានកំណត់យកអាយុនៅពេលអនីតិជននោះប្រព្រឹត្តបទល្មើស[2]។ ការកំណត់អំពីកម្រិតអាយុនៃការទទួលខុសត្រូវនេះ គឺជាការប្រកាន់យក និងទទួលស្គាល់ជាផ្លូវការពីសំណាក់រដ្ឋថា អនីតិជនម្នាក់នៅពេលដែលឈានដល់អាយុតាមការកំណត់នោះ ទើបមានលទ្ធភាពទទួលខុសត្រូវព្រហ្មទណ្ឌ។ ដើម្បីឆ្លើយតបទៅនឹងលក្ខខណ្ឌអាយុនេះ សូមធ្វើការបែងចែកជាពីរប្រភេទគឺៈ **លក្ខខណ្ឌអាយុក្រោម ១៤ឆ្នាំ** និង **លក្ខខណ្ឌអាយុចាប់ពី ១៤ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ** ។

### ១.១ លក្ខខណ្ឌអាយុក្រោម ១៤ឆ្នាំ

ក្នុងករណីនេះ នៅពេលដែលអនីតិជនបានប្រព្រឹត្តបទល្មើសគឺច្បាប់បានកំណត់ថា មិនឲ្យទទួលខុសត្រូវព្រហ្មទណ្ឌនោះទេ។ ដោយយោងទៅលើអនុសញ្ញាស្តីពីសិទ្ធិកុមារត្រង់មាត្រា ៤០ ចំណុចទី៣ កថាខណ្ឌ ក បានតម្រូវឲ្យរដ្ឋជាភាគី ដែលក្នុងនោះក៏មានព្រះរាជាណាចក្រកម្ពុជាផងដែរ ត្រូវធ្វើការកំណត់កម្រិតអាយុអប្បបរមានៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់កុមារដែលក្រោមអាយុអប្បបរមានេះ កុមារត្រូវបានសន្មតជាមុនថាពុំមានសមត្ថភាពនិងប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌឡើយ[3]។ រីឯមាត្រា ១៤ កថាខណ្ឌទី១ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ប្រកាសឲ្យប្រើនៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៦ បានចែងថា អនីតិជនមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ ដែលជាប់សង្ស័យថាបានប្រព្រឹត្តបទល្មើស ពុំអាចត្រូវបានគេឃាត់ខ្លួនឡើយ ហើយមន្ត្រីនគរបាលយុត្តិធម៌ត្រូវប្រគល់អនីតិជននោះទៅកាន់អ្នកតំណាងដែលច្បាប់បានកំណត់។ ចំណែកឯមាត្រា ២៧ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន បានចែងផងដែរថា ក្នុងករណីអនីតិជនមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ គិតមកត្រឹមថ្ងៃដែលសង្ស័យ

[1] មាត្រា៧ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[2] មាត្រា៩ កថាខណ្ឌទី១ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[3] មាត្រា ៤០ អនុសញ្ញាស្តីពីសិទ្ធិកុមារ

ថាបានចូលរួមប្រព្រឹត្តបទល្មើសនោះ ព្រះរាជអាជ្ញាត្រូវសម្រេចតម្កល់រឿងទុកឥតចាត់ការ និងត្រូវប្រគល់អនីតិជនទៅឲ្យអ្នកតំណាងដែលច្បាប់បានកំណត់។ បញ្ញត្តិនៃមាត្រា ៣៩ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ក៏បានចែងថា អនីតិជនអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ មិនត្រូវបានឃុំខ្លួនបណ្តោះអាសន្នឡើយ។ ដូច្នេះគេអាចសន្និតបានថា អាយុ ១៤ (ដប់បួន) ឆ្នាំ គឺជាកម្រិតអាយុអប្បបរមានៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ឬពុំត្រូវបានទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌនោះទេ។

ឧទាហរណ៍ ៖ ក្មេងម្នាក់អាយុ ១០ឆ្នាំ បានចោលដុំថ្មលេងមិនប្រយ័ត្ន បណ្តាលឲ្យត្រូវចំក្បាលក្មេងប្រុសម្នាក់បណ្តាលឲ្យរងរបួសបែកក្បាលជាដំណំ។ ក្នុងករណីនេះ ក្មេងដែលបានប្រព្រឹត្តអំពើនោះ មិនអាចត្រូវទទួលខុសត្រូវព្រហ្មទណ្ឌនោះទេ ដោយហេតុថាក្មេងនោះមិនមានការយល់ដឹងខុសត្រូវទៅនឹងអំពើរបស់ខ្លួននៅឡើយ។

**១.២. លក្ខខណ្ឌអាយុចាប់ពី ១៤ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ**

ចំពោះអនីតិជនប្រភេទនេះវិញ នៅពេលដែលបានប្រព្រឹត្តបទល្មើស គឺត្រូវទទួលខុសត្រូវលើអំពើដែលខ្លួនបានប្រព្រឹត្តនោះ។ ដោយយល់ឃើញថា អនីតិជនប្រភេទនេះមានសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌហើយ។ សមត្ថភាពនៃការទទួលខុសត្រូវនេះគឺចង់សំដៅទៅលើលទ្ធភាពរបស់មនុស្សនៅពេលដែលប្រព្រឹត្តអំពើគ្រោះថ្នាក់ដល់សង្គម ហើយជននោះបានដឹងអំពីចរិកគ្រោះថ្នាក់នៃអំពើរបស់ខ្លួន និងអាចបញ្ជានូវរាល់អំពើទាំងនោះបាន។ ការយល់ឃើញដូច្នេះ គឺផ្អែកទៅលើការរីកចម្រើននៃអំពើរូបរាងកាយ ប្រាជ្ញា ស្មារតី និងការសន្សំបទពិសោធន៍នៃជីវិតក្នុងជីវភាពរស់នៅកន្លងមករបស់អនីតិជន។ កត្តាទាំងអស់នេះហើយ ដែលជាហេតុនាំឲ្យច្បាប់សន្និតថា អនីតិជនប្រភេទនេះ មានការយល់ដឹងពីចារណាបានគ្រប់គ្រាន់នូវបណ្តាការទាមទារ និងរបបកំណត់របស់សង្គម ព្រមទាំងអាចបញ្ជាបាននូវរាល់អំពើរបស់ខ្លួន។ ទោះបីជាយ៉ាងណាក៏ដោយ ការទទួលខុសត្រូវនេមិនមានលក្ខណៈពេញលេញដូចនីតិជនឡើយ ពោលគឺស្ថានភាពដែលជននេះត្រូវទទួលរងគឺមានកម្រិតស្រាលជាងនីតិជន ហើយដើម្បីអាចសម្រេចផ្តន្ទាទោសលើអនីតិជននោះបាន តុលាការត្រូវពិនិត្យពិចារណា ថ្លឹងថ្លែងជាមុនពាក់ព័ន្ធទៅនឹងកាលៈទេសៈនៃបទល្មើសដែលអនីតិជននោះបានប្រព្រឹត្ត និងរួមទាំងបុគ្គលិកលក្ខណៈរបស់គាត់ផងដែរ។ ចំពោះទោសដែលត្រូវទទួលរងវិញគឺអាចជាការដកហូតសេរីភាព និងទោសពិន័យជាប្រាក់។

ទោះបីជាអនីតិជននោះទទួលទោសបែបនេះក៏ដោយ ក៏កម្រិតនៃទោសដែលទទួលរង គឺត្រូវបន្ថយមកត្រឹមពាក់កណ្តាល បើប្រៀបធៀបទៅនឹងទោសដែលមានចែងចំពោះនីតិជន។

ឧទាហរណ៍ ៖ ក្មេងស្រី ខ មានអាយុ ១៧ឆ្នាំ បានឈ្លោះប្រកែកគ្នាជាមួយក្មេងស្រីម្នាក់ទៀត ក៏ជ្រុលទៅចាក់សម្លាប់ក្មេងស្រីនោះបណ្តាលឲ្យស្លាប់។ ដូចនេះក្មេងស្រីឈ្មោះ ខ មិនអាចជៀសផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ ដោយអះអាងថា ខ្លួនមិនមានចេតនា និងមិនដឹងទាល់តែសោះចំពោះអំពើរបស់ខ្លួននោះឡើយ។

ដូច្នេះចំពោះទោសដែលត្រូវអនុវត្តទៅលើក្មេងស្រីនោះ គឺត្រូវបន្ថយមកត្រឹមពាក់កណ្ដាល បើធៀបទៅនឹងទោសដែលអនុវត្តទៅលើអនីតិជន។

## ផ្នែកទី២ ៖ កាលៈទេសៈនៃបទល្មើស និងបុគ្គលិកលក្ខណៈ

យោងតាមគោលការណ៍នៃការកំណត់អំពីទណ្ឌកម្ម ឬគោលការណ៍នៃការផ្ដន្ទាទោស ចៅក្រមអាចធ្វើការផ្ដន្ទាទោសជនល្មើសណាម្នាក់បាន ត្រូវពិចារណាអំពីបាតុភូតសង្គមដែលបទល្មើសបានកើតឡើងឲ្យបានគ្រប់ជ្រុងជ្រោយជាមុនសិន ទើបធ្វើការសម្រេចផ្ដន្ទាទោសទៅលើចារីនោះ បានសេចក្ដីថាដើម្បីឲ្យចេញសេចក្ដីសម្រេចប្រកបទៅដោយភាពសុក្រឹត្យភាព និងសុភវិនិច្ឆ័យ ចៅក្រមត្រូវពិចារណាទៅលើចំណុចសំខាន់គឺទីមួយគឺពាក់ព័ន្ធទៅនឹងបញ្ហាដែលមានចែងក្នុងច្បាប់ ពោលគឺគោលការណ៍នីត្យានុកូលភាពនៃទោស។ ទីពីរគឺស្ថានភាពនៃការប្រព្រឹត្តបទល្មើសថា តើបទល្មើសនោះប្រព្រឹត្តក្នុងកាលៈទេសៈបែបណា? ពេលវេលាណា? ទីកន្លែងណា? និងទីបីគឺពីនិត្យទៅលើបុគ្គលិកលក្ខណៈរបស់ជនល្មើសនោះ។

### ២.១. កាលៈទេសៈនៃបទល្មើស

ដោយហេតុថា ច្បាប់ពុំបានកំណត់អំពីនិយមន័យនៃពាក្យ កាលៈទេសៈបទល្មើសឲ្យបានជាក់លាក់ ដូចនេះយើងអាចកំណត់អត្ថន័យបានថា គឺជាកត្តារួមផ្សំនៃបទល្មើស។ បានសេចក្ដីថា គឺជាកត្តាមួយដែលស្ថិតនៅក្នុងធាតុសត្យានុម័តនៃបទល្មើស ដែលមានតួនាទីក្នុងការកំណត់បទល្មើស និងកំណត់អំពីព្រំដែនទណ្ឌកម្មផងដែរ ហើយក្នុងនោះផងដែរយើងក៏អាចសិក្សាស្វែងយល់ និងពិចារណាតាមរយៈបទពិសោធន៍ជាក់ស្ដែងរបស់ចៅក្រមក្នុងការពិចារណា និងសម្រេចអំពីទណ្ឌកម្មជាក់ស្ដែងទៅលើអនីតិជនដែលជាជនល្មើស តាមរយៈរួមផ្សំដូចខាងក្រោម[4]៖

**មធ្យោបាយប្រព្រឹត្តបទល្មើស** សំដៅទៅលើបណ្ដាវត្ថុ ឬសម្ភារៈ និងរួមបញ្ចូលទាំងឧបករណ៍ប្រព្រឹត្តបទល្មើសផងដែរ ដែលអនីតិជននោះបានប្រើប្រាស់ដើម្បីប្រព្រឹត្តបទល្មើស។ ឧទាហរណ៍ អនីតិជនម្នាក់ បានប្រើប្រាស់អំពើហឹង្សាទៅលើអនីតិជនម្នាក់ទៀត ដោយប្រើប្រាស់អាវុធដោយខុសច្បាប់ ដែលនេះជាសញ្ញាមួយនៃស្ថានទម្ងន់ទោសក្នុងបទ ហឹង្សាដោយចេតនា ដែលមានចែងក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ២១៨។

**វិធីសាស្ត្រប្រព្រឹត្តបទល្មើស** សំដៅទៅលើបែបបទនៃនីតិវិធីក្នុងការប្រព្រឹត្តនូវអំពើល្មើសច្បាប់មួយដែលបានកើតឡើង។ ឧទាហរណ៍ អនីតិជនម្នាក់បានប្រើប្រាស់កលល្បិច ទៅលើអនីតិជនម្នាក់ទៀត ដើម្បីឲ្យអនីតិ

[4] សៀវភៅ នីតិព្រហ្មទណ្ឌទូទៅ សាស្ត្រាចារ្យ ហ៊ី សោភា

ជននោះ ប្រគល់នូវទ្រព្យសម្បត្តិ អ្វីមួយមកឲ្យខ្លួន ដែលនេះជាបទល្មើស **ឆបោក** ដែលមានចែងក្នុងព្រហ្មទណ្ឌ មាត្រា ៣៧៧។

**ពេលវេលាប្រព្រឹត្តបទល្មើស** ជាពេលវេលាប្រព្រឹត្តបទល្មើស អាចពេលមួយ ឬរយៈពេលមួយជាកំណត់ ដែលអំពើល្មើសច្បាប់ព្រហ្មទណ្ឌបានស្ដែងចេញមកខាងក្រៅ។ មានន័យថា នៅក្នុងរឿងព្រហ្មទណ្ឌពេលវេលា ប្រព្រឹត្តបទល្មើស អាចជាសញ្ញាមួយសម្រាប់កំណត់នូវបទល្មើសផ្ទាល់តែម្ដង។ ឧទាហរណ៍ ៖ ការធ្វើនេសាទនៅក្នុងរដូវបិទឡូត៍នេសាទជាដើម។

**ទីកន្លែងប្រព្រឹត្តបទល្មើស** មានន័យថា ជារង្វង់ដែនដីមួយជាកំណត់ ដែលនៅទីនោះបទល្មើសបានចាប់ផ្ដើម និងបញ្ចប់ ឬនៅទីនោះបច្ច័យនៃអំពើល្មើសច្បាប់បានកើតឡើង។ បានសេចក្ដីថាទីកន្លែងអាចជាចំណុចណាមួយ ឬជាតំបន់ដែនដីណាមួយជាកំណត់ ដែលច្បាប់ព្រហ្មទណ្ឌបានបញ្ញត្តិថា វាជាទីកន្លែងមួយដែលសម្រាប់កំណត់នូវបទល្មើសព្រហ្មទណ្ឌ។ ឧទាហរណ៍ ៖ បទល្មើសនេសាទ ដែលប្រព្រឹត្តនៅដែននេសាទទឹកសាប រួមមានដូចជា ស្ទឹង បឹង ព្រែក អូរ ឬដៃទន្លេ ជាអាទិ៍។

**ទិដ្ឋភាពនានាជុំវិញបទល្មើស** ជាការសរុបនូវរាល់ករណីលំអិតនានាផ្នែកសត្យានុម័តជុំវិញការប្រព្រឹត្តបទល្មើសដែលមានឥទ្ធិពលទៅលើកម្រិតគ្រោះថ្នាក់ដល់សង្គមនៃបទល្មើស។ ទិដ្ឋភាពជុំវិញនៃបទល្មើសទាំងនោះ ត្រូវបានកំណត់ថាជា ស្ថានទម្ងន់ទោស ឬស្ថានសម្រាលទោសផងដែរ។ ឧទាហរណ៍ ៖ អនីតិជនម្នាក់បានប្រព្រឹត្តបទ ឃាតកម្ម ដោយសារកាលៈទេសៈ ឬដោយសារស្ថានភាពចិត្តសាស្ត្ររបស់អនីតិជននោះជាសញ្ញាណនៃការទទួលបាននូវស្ថានសម្រាលទោស (មាត្រា ៩៣ និងមាត្រា ២០៧ នៃក្រមព្រហ្មទណ្ឌ) ។

### ២.២. បុគ្គលិកលក្ខណៈរបស់អនីតិជន

ផ្អែកតាមមាត្រា ៦៥ ចំណុច (គ) នៃច្បាប់ស្ដីពីយុត្តិធម៌អនីតិជន បានចែងថា បុគ្គលិកលក្ខណៈរបស់អនីតិជនមានដូចជា អាយុ កម្រិតយល់ដឹង បញ្ញា និងអត្តចរិតរបស់អនីតិជននោះ។ ត្រង់ចំណុចនេះ បុគ្គលិកលក្ខណៈចង់សំដៅទៅលើសមត្ថភាពទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់អនីតិជននោះផ្ទាល់តែម្ដងចំពោះបទល្មើសដែលខ្លួនបានប្រព្រឹត្ត។ ដូច្នេះតុលាការមុននឹងប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជនត្រូវពិចារណាអំពីការរីកចម្រើននៃរូបរាងកាយរបស់អនីតិជន ប្រាជ្ញា ស្មារតី និងបទពិសោធន៍ក្នុងជីវភាពរស់នៅរបស់អនីតិជននោះជាមុនសិន។ ដើម្បីអាចវាយតម្លៃបានថា អនីតិជនអាចយល់ដឹង ឬមិនយល់ដឹងបាន គឺវាយតម្លៃបានតាមរយៈ ០២ បែប គឺ របបវិជ្ជសាស្ត្រ និងរបបធម្មជាតិ[5] ៖

[5] សៀវភៅ នីតិព្រហ្មទណ្ឌទូទៅ សាស្ត្រាចារ្យ ហ៊ី សោភា

**របបវេជ្ជសាស្ត្រ** គឺសំដៅទៅលើស្ថានភាពនៃជម្ងឺដែលនាំឲ្យជននោះមិនអាចយល់ដឹងបានដូចជាមនុស្សដែលស្ថិតក្នុងស្ថានភាពវិបល្លាសស្មារតីជាប្រចាំ ពោលគឺជាជនដែលមានជំងឺសរសៃប្រសាទជាប្រចាំ ឬខ្សោយសតិ ឬសតិពុំប្រក្រតី ឬជំងឺផ្សេងៗទៀតដែលបណ្តាលឲ្យមានភាពរឹករក្នុងសកម្មភាពនេះតែម្តង។

ភាពសរសៃប្រសាទនេះអាចមានរូបភាពជាក់ស្តែងខុសៗគ្នាដែលនាំមកនូវលទ្ធផលសភាពជំងឺជាប្រចាំឬយូរអង្វែង។

ក្នុងករណីខ្លះភាពនៃសរសៃប្រសាទអាចជាបណ្តោះអាសន្នស្តែងឡើងភ្លាមៗក្នុងរយៈពេលខ្លីធ្វើឲ្យមានការបាត់បង់នូវការយល់ដឹងភ្លេចទាំងស្រុង ឬមួយផ្នែកនៃករណីដែលបានកើតឡើងក្នុងពេលវេលាណាមួយដែលជំងឺនោះបានធ្វើសកម្មភាព។

**របបបែបធម្មជាតិ** គឺពិចារណាទៅលើផ្នែកសរីរាង្គ ដោយពិនិត្យទៅលើអាយុរបស់ជននោះ រួមទាំងចំណេះដឹងរបស់ពួកគេផងដែរ។ ការពិចារណានេះគឺផ្អែកទៅលើការរីកចម្រើនផ្នែកសរីរាង្គផងដែរ ដែលអាចមានជាបញ្ហាសរសៃប្រសាទ និងរាងកាយ។ ហេតុដូច្នេះហើយទើបច្បាប់បានកំណត់ថាអនីតិជនដែលអាយុចាប់ពី ១៤ (ដប់បួន)ឆ្នាំ អាចមានការយល់ដឹងខ្លះ ដោយសារការប្រែប្រួលនៃស្ថានភាពផ្នែករូបរាងកាយ និងការទទួលរបបឥទ្ធិពលផ្នែកខាងធម្មជាតិ។

ហេតុដូច្នេះហើយទើបនៅក្នុងក្រមព្រហ្មទណ្ឌបានកំណត់អំពី អនីតិជនដែលមានអាយុចាប់ពី ១៤ (ដប់បួន)ឆ្នាំឡើងទៅ ហើយបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌណាមួយក្នុងកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈនៃបទល្មើស គឺចៅក្រមអាចប្រកាសផ្តន្ទាទោសទៅលើអនីតិជននោះបាន។

# ជំពូកទី២
# នីតិវិធីពិសេសក្នុងការអនុវត្តទៅលើអនីតិជន

# ជំពូកទី២
# នីតិវិធីពិសេសក្នុងការអនុវត្តទៅលើអនីតិជន

នីតិវិធីក្នុងការអនុវត្តទៅលើអនីតិជនមានលក្ខណៈដូចគ្នាទៅនឹងនីតិវិធីអនុវត្តចំពោះនីតិជនផងដែរ ដោយហេតុថា ការអនុវត្តនីតិវិធីនេះត្រូវមានចំណាត់ការទៅតាមដំណាក់កាលនីមួយៗផងដែរ ក្នុងនោះយើងឃើញមានជា ដំណាក់កាលស៊ើបអង្កេតរបស់មន្ត្រីនគរបាល ការបន្តចំណាត់ការសំណុំរឿងដោយតំណាងអយ្យការ (ការចោទប្រកាន់) ការស៊ើបសួរដោយចៅក្រមស៊ើបសួរ និងដំណាក់កាលជំនុំជម្រះនាពេលសវនាការជាដើម។ ប៉ុន្តែដោយហេតុថាអនីតិជនគឺជាជនដែលមានសមត្ថភាពយល់ដឹងខាងអំពើនៅមានកម្រិត ដូច្នេះហើយទើបច្បាប់បានពិចារណាទៅលើកម្រិតនៃការយល់ដឹងរបស់ពួកគេ ដែលតម្រូវឲ្យមានការអនុវត្តនូវនីតិវិធីពិសេសមួយចំនួនចំពោះអនីតិជន។

## ផ្នែកទី១ ៖ ដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ និងការស៊ើបអង្កេត

នៅក្នុងរឿងក្តីព្រហ្មទណ្ឌជាដំបូងឡើយ គឺគេត្រូវចាប់ផ្តើមឡើងដោយការស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ដែលអាចស្វែងរកឃើញថា អង្គហេតុមួយចំនួនត្រូវបានចាត់ទុកថាមានបទល្មើស ការស៊ើបអង្កេតនេះគឺជាដំណាក់កាលត្រៀមនៃរឿងក្តីព្រហ្មទណ្ឌដែលប្រព្រឹត្តទៅមុនពេលមានការចោទប្រកាន់ ក្នុងគោលបំណងដើម្បីកំណត់ភស្តុតាងមួយឲ្យបានច្បាស់លាស់។

ប្រសិនបើអនីតិជននោះមានអាយុចាប់ពី ១៤ (ដប់បួនឆ្នាំ) ដល់អាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ បានប្រព្រឹត្តបទលហុ នោះមន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើការអប់រំណែនាំព្រមានដោយផ្ទាល់មាត់ ឬលាយលក្ខណ៍អក្សរ រួចហើយប្រគល់អនីតិជននោះទៅកាន់អ្នកតំណាងដែលច្បាប់បានកំណត់ជាបន្ទាន់[6] ក្នុងករណីអនីតិជននោះបានសារភាពថាបានប្រព្រឹត្តបទល្មើស ហើយបទល្មើសនោះជាបទលហុនគរបាលយុត្តិធម៌អាចធ្វើការសម្រុះសម្រួលរវាងភាគីពាក់ព័ន្ធដើម្បីបញ្ចប់វិវាទ[7]។ បន្ទាប់មកមន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើរបាយការណ៍ និងបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញាដើម្បីចាត់ការតាមច្បាប់។ ប្រសិនបើអនីតិជននោះត្រូវការកិច្ចការពារថែទាំ មន្ត្រីនគរបាលយុត្តិធម៌ត្រូវបញ្ជូនអនីតិជននោះទៅមន្ទីរ ឬការិយាល័យទទួលបន្ទុកផ្នែកវិស័យសង្គមកិច្ច រាជធានី ខេត្ត ក្រុង ខណ្ឌ ដើម្បីចាត់ការវិធានការសមស្របទៅតាមសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន[8]។ មន្ទីរ ឬការិយាល័យទទួលបន្ទុក វិស័យសង្គមកិច្ចរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវធ្វើរបាយការណ៍អំពីការទទួលអនីតិជនពីនគរបាលយុត្តិធម៌ ជូនទៅព្រះរាជអាជ្ញា។

[6] មាត្រា ១៣ កថាខណ្ឌទី១ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[7] មាត្រា ១៣ កថាខណ្ឌទី២ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[8] មាត្រា ១៣ កថាខណ្ឌទី៣ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

**១.១. សមាសភាពរបស់មន្ត្រីនគរបាលយុត្តិធម៌**

មន្ត្រីនគរបាលយុត្តិធម៌ដែលមានជំនាញទទួលបន្ទុកការងារអនីតិជន មានភារៈកិច្ចត្រួតពិនិត្យលើបទឧក្រិដ្ឋ បទមជ្ឈិម កំណត់អត្តសញ្ញាណ និងចាប់អនីតិជន ព្រមទាំងប្រមូលភស្តុតាង[9]។

**១.២. សមត្ថកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌**

ក្រោមការដឹកនាំ ក៏ដូចជាការសម្របសម្រួលសកម្មភាពការងារដោយព្រះរាជអាជ្ញា មន្ត្រីនគរបាលយុត្តិធម៌មានភារៈកិច្ចធ្វើការត្រួតពិនិត្យបទឧក្រិដ្ឋ បទមជ្ឈិម បទលហុ ដែលប្រព្រឹត្តទៅដោយអនីតិជន និងធ្វើការប្រមូលភស្តុតាង ក៏ដូចជាកំណត់អត្តសញ្ញាណដើម្បីធ្វើការឃាត់ខ្លួន ឬចាប់ខ្លួនអនីតិជនដែលបានប្រព្រឹត្តបទល្មើស ក្នុងករណីចាំបាច់។ ការចាប់ខ្លួន និងការស៊ើបអង្កេតលើករណីអនីតិជននេះ ត្រូវធ្វើឡើងដោយមន្ត្រីជំនាញ ឬជំនួយពីមន្ត្រីនគរបាលយុត្តិធម៌ ដែលបានទទួលការបណ្តុះបណ្តាលស្តីពីយុត្តិធម៌ និងអនីតិជនប្រសិនបើអាចធ្វើបាន។ ដូចនេះក្នុងករណីណាមួយក៏ដោយ នគរបាលយុត្តិធម៌ដែលបានចាប់ខ្លួនអនីតិជន ឬនគរបាលយុត្តិធម៌ ដែលបានឃាត់ខ្លួនអនីតិជន ត្រូវប្រគល់របាយការណ៍ និងកំណត់ហេតុលម្អិតស្តីពីការចាប់ ឬឃាត់ខ្លួន និងប្រគល់អនីតិជននោះទៅឲ្យផ្នែក ឬអង្គភាពដែលមាននគរបាលយុត្តិធម៌ជំនាញទទួលបន្ទុកផ្នែកការងារអនីតិជន[10]។

**១.៣. អំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌**

ក្នុងករណីណាក៏ដោយប្រសិនបើមានបទល្មើសណាមួយ ដែលប្រព្រឹត្តឡើងដោយអនីតិជន គឺមន្ត្រីនគរបាលយុត្តិធម៌ត្រូវមានតួនាទីក្នុងការឃាត់ ឬចាប់ខ្លួន អនីតិជននោះ ដើម្បីយកមកធ្វើការបំពេញកិច្ចមួយចំនួននៅអង្គភាពនគរបាលយុត្តិធម៌។ មន្ត្រីនគរបាលយុត្តិធម៌ដែលទទួលបន្ទុកលើអនីតិជន មានអំណាចនៅក្នុងការបំពេញកិច្ចរបស់ខ្លួន ដោយផ្អែកទៅលើក្រមនីតិវិធីព្រហ្មទណ្ឌ និងច្បាប់ស្តីពីយុត្តិធម៌អនីតិជន។ កិច្ចទាំងនោះអាចជា **ការចាប់ខ្លួន ការឆែកឆេរ ការឃាត់ខ្លួន ការជូនដំណឹង ការស្តាប់ចម្លើយ** និង **ការបញ្ជប់ និងការបញ្ជូនខ្លួនទៅព្រះរាជអាជ្ញា**។

**១.៣.១. ការចាប់ខ្លួន**

នគរបាលយុត្តិធម៌ អាចចាប់ខ្លួនអនីតិជនដែលមានអាយុចាប់ពី ១៤ (ដប់បួន)ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី)ឆ្នាំ តែក្នុងករណីដែលអនីតិជនប្រព្រឹត្តបទមជ្ឈិម ឬបទឧក្រិដ្ឋជាក់ស្តែងតែប៉ុណ្ណោះ។ ប៉ុន្តែអនីតិជនដែលមានអាយុចាប់ពី ១៤(ដប់បួន)ឆ្នាំ ដល់ក្រោម ១៦(ដប់ប្រាំមួយ)ឆ្នាំ ការចាប់ខ្លួនអាចធ្វើទៅបានតែក្នុងករណីដែល

---

[9] មាត្រា ១២ កថាខណ្ឌទី១ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[10] មាត្រា ១២ កថាខណ្ឌទី២ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

អនីតិជននោះប្រព្រឹត្តបទមជ្ឈិមដោយចេតនា។ រាល់ការចាប់ខ្លួនត្រូវរាយការណ៍ជូនព្រះរាជអាជ្ញាភ្លាម[11]។ ការអនុវត្តការចាប់ខ្លួនរបស់មន្ត្រីនគរបាលយុត្តិធម៌ត្រូវគោរពតាមនីតិវិធីដូចខាងក្រោម៖

- ក្នុងការចាប់ខ្លួនអនីតិជនត្រូវជៀសវាងក្នុងការធ្វើឲ្យអាម៉ាស់មុខ និងបាត់បង់សេចក្តីថ្លៃថ្នូររបស់អនីតិជន និងត្រូវបញ្ជូនអនីតិជនទៅឲ្យផ្នែក ឬអង្គភាពដែលមាននគរបាលយុត្តិធម៌ជំនាញទទួលបន្ទុកការងារអនីតិជនដែលនៅជិតបំផុត[12]។
- មិនត្រូវប្រើប្រាស់ខ្នោះដៃ អាវុធ កាំភ្លើង ឬឧបករណ៍ប្រហាក់ប្រហែលសម្រាប់បង្ខំ ឬរារាំងឡើយ លើកលែងតែបានប្រើប្រាស់គ្រប់មធ្យោបាយសម្រាប់ការត្រួតត្រាផ្សេងៗរួចហើយ ឬប្រើប្រាស់គ្រប់មធ្យោបាយផ្សេងៗទៀតពុំសមស្របនឹងកាលៈទេសៈ ឬដើម្បីរារាំងសកម្មភាពដែលអនីតិជននោះអាចបង្កគ្រោះថ្នាក់ធ្ងន់ធ្ងរលើខ្លួនឯង ឬលើបុគ្គលដទៃទៀត[13]។ ក្នុងករណីប្រសិនបើមានការរារាំង ឬប្រើប្រាស់កម្លាំងមន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះក្នុងកំណត់ហេតុ ហើយបញ្ជាក់ពីមូលហេតុ និងកាលៈទេសៈដែលត្រូវប្រើប្រាស់កម្លាំង។ បន្ទាប់មកត្រូវបញ្ជូនអនីតិជនទៅឲ្យផ្នែក ឬអង្គភាពដែលមាននគរបាលយុត្តិធម៌ជំនាញទទួលបន្ទុកការងារអនីតិជនដែលនៅជិតបំផុត។

  ក្នុងការចាប់ខ្លួនអនីតិជន មន្ត្រីនគរបាលយុត្តិធម៌ត្រូវប្រាប់ពីសិទ្ធិមួយចំនួនទៅកាន់អនីតិជននោះដែលមានសិទ្ធិដូចជា[14] ៖
- សិទ្ធិមិនផ្តល់ចម្លើយនៅពេលមាន ឬគ្មានមេធាវី
- សិទ្ធិមិនទទួលការបង្ខិតបង្ខំឲ្យឆ្លើយដាក់បន្ទុកលើខ្លួនឯង
- សិទ្ធិរក្សាការសម្ងាត់នៃជីវិតឯកជន
- សិទ្ធិក្នុងការជូនដំណឹងអំពីការចាប់ខ្លួនទៅដល់អ្នកតំណាងដែលច្បាប់បានកំណត់
- សិទ្ធិទទួលបានជំនួយមេធាវីដោយការជ្រើសរើស ឬដោយការចាត់តាំងដោយមិនយកកម្រៃស្របតាមលក្ខខណ្ឌដូចមានចែងនៅក្នុងច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ចាប់ពីដំណាក់កាលដំបូងនៃនីតិវិធី
- សិទ្ធិឲ្យមានការចូលរួមពីអ្នកតំណាងដែលច្បាប់បានកំណត់នៅគ្រប់ដំណើរការរឿងក្តី ប្រសិនបើការចូលរួមនេះមិនផ្ទុយនឹងឧត្តមប្រយោជន៍របស់អនីតិជន
- សិទ្ធិទទួលបានជំនួយពីអ្នកបកប្រែភាសាដោយមិនយកកម្រៃ ប្រសិនបើចាំបាច់
- សិទ្ធិបង្ហាញភស្តុតាង

[11] មាត្រា ១៥ កថាខណ្ឌទី១ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[12] មាត្រា ១៥ កថាខណ្ឌទី២ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[13] មាត្រា ១២ កថាខណ្ឌទី២ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជនទំនាស់នឹងច្បាប់ ឆ្នាំ២០១០

[14] មាត្រា ៦ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

- សិទ្ធិស្នើសុំឲ្យកោះហៅសាក្សី និងសាកសួរសាក្សី
- សិទ្ធិទំនាក់ទំនងជាមួយស្ថានទូត ស្ថានកុងស៊ុល ក្នុងករណីអនីតិជនជាជនបរទេស និង
- សិទ្ធិផ្សេងៗទៀតដូចដែលមានចែងនៅក្នុងបទដ្ឋានគតិយុត្តិជាធរមាន។

ទោះបីជាយ៉ាងណាក៏ដោយ ការចាប់ខ្លួនគួរតែអនុវត្តសម្រាប់វិធានការចុងក្រោយបំផុតប៉ុណ្ណោះ។ ការចាប់ខ្លួនត្រូវមានមូលហេតុត្រឹមត្រូវតាមច្បាប់ ទោះបីជាការចាប់ខ្លួននោះ ត្រូវធ្វើឡើងដោយដីកាចាប់ខ្លួនតាមភស្តុតាងស៊ីសង្វាក់ ឬតាមបទល្មើសជាក់ស្តែងក្តី[15]។

### ១.៣.២. ការឆែកឆេរ

មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឆែកឆេរលើបុគ្គលដែលជាអនីតិជនបាន។ ការឆែកឆេរខ្លួនបុគ្គលដែលធ្វើឡើងត្រូវតែជាភេទដូចគ្នា និងមិនត្រូវជាប់ពាក់ព័ន្ធនឹងបទល្មើសពុំមានទំនាស់ ឬមិនជាប់សាច់ញាតិ ឬមានទំនាក់ទំនងជិតស្និទ្ធជាមួយអនីតិជននោះឡើយ លើកលែងតែករណីមិនអាចជៀសបាន។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើកំណត់ហេតុ និងចុះនិទ្ទេសអំពីបញ្ហានេះ[16]។

### ១.៣.៣. ការឃាត់ខ្លួន

អនីតិជនដែលមានអាយុក្រោម ១៤(ដប់បួន) ឆ្នាំ ដែលសង្ស័យថាបានប្រព្រឹត្តបទល្មើស ពុំអាចត្រូវបានគេឃាត់ខ្លួនឡើយ។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវប្រគល់អនីតិជននោះទៅអ្នកតំណាងដែលច្បាប់បានកំណត់។

ប៉ុន្តែដើម្បីឆ្លើយតបទៅនឹងតម្រូវការចាំបាច់នៃការស៊ើបអង្កេត មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឃាត់ខ្លួនអនីតិជនដែលមានអាយុចាប់ពី ១៤ (ដប់បួន)ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី)ឆ្នាំ ឡើងបាន ប្រសិនបើជឿជាក់ថាអនីតិជននោះនឹងរត់គេចខ្លួន ឬបំផ្លាញភស្តុតាង ឬបង្កគ្រោះថ្នាក់ដល់សុវត្ថិភាពសាក្សី ឬសន្តិសុខសាធារណៈ ឬក្នុងគោលបំណងការពារអនីតិជននោះ។ ក្នុងករណីដែលអនីតិជនដែលមានអាយុចាប់ពី ១៤ (ដប់បួន)ឆ្នាំ ដល់ក្រោម ១៦ (ដប់ប្រាំមួយ)ឆ្នាំ ការឃាត់ខ្លួនមិនអាចប្រព្រឹត្តទៅបានឡើយ ប្រសិនបើអនីតិជននោះមិនមានចេតនាក្នុងការប្រព្រឹត្តបទល្មើស។ រាល់ការឃាត់ខ្លួនអនីតិជនត្រូវរាយការណ៍ជូនទៅព្រះរាជអាជ្ញា[17]។

រាល់ការឃាត់ខ្លួនអនីតិជន ត្រូវដាក់ដោយឡែកពីនីតិជន និងទៅតាមភេទ។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវធានាឲ្យបាននូវសុវត្ថិភាពរបស់អនីតិជន ដោយមិនត្រូវឲ្យអនីតិជនទទួលរងទារុណកម្ម ការបង្ខិតបង្ខំ ការគំរាមកំហែង ការសម្លុត ការបំភិតបំភ័យ ឬទង្វើណាមួយផ្សេងទៀតដែលនាំឲ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់អនីតិជន ឬអាចទទួលរងនូវអំពើអមនុស្សធម៌ណាមួយឡើយ។ មន្ត្រីនគរបាលយុត្តិធម៌មិនត្រូវយកអនីតិជនដាក់បង្ហាញ

[15] មាត្រា ៣៨ សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស ឆ្នាំ១៩៤៨

[16] មាត្រា ១៦ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[17] មាត្រា ១៧ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

មុខជាដួរឡើយ ប្រសិនបើគ្មានការយល់ព្រមជាមុនពីអនីតិជន ដោយមានការពិគ្រោះយោបល់ជាមួយមេធាវី និង អ្នកតំណាងដោយច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុងអនីតិជន។ ប្រសិនបើមានការយល់ព្រម ត្រូវមាន កំណត់ហេតុជាលាយលក្ខណ៍អក្សរ និងផ្តិតម្រាមដៃ[18]។

ចំពោះរយៈពេលនៃការឃាត់ខ្លួនអនីតិជនមិនត្រូវបានពន្យាឡើយ ហើយការឃាត់ខ្លួននេះត្រូវអនុវត្ត យ៉ាងជាក់លាក់តាមការកំណត់[19] ៖

- អនីតិជនដែលបានប្រព្រឹត្តបទមជ្ឈិម ដែលមានអាយុពី ១៤ (ដប់បួន)ឆ្នាំ ដល់ក្រោម ១៦ (ដប់ប្រាំមួយ) ឆ្នាំ មិនអាចត្រូវបានឃាត់ខ្លួនហួសរយៈពេល ២៤ ម៉ោងឡើយ។ ប៉ុន្តែប្រសិនបើអនីតិជនដែលមានអាយុចាប់ពី ១៦ (ដប់ប្រាំមួយ) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ មិនអាចត្រូវបានឃាត់ខ្លួនហួសរយៈពេល ៣៦ ម៉ោងឡើយ។
- អនីតិជនដែលបានប្រព្រឹត្តបទឧក្រិដ្ឋ ដែលមានអាយុពី ១៤ (ដប់បួន)ឆ្នាំ ដល់ក្រោម ១៦ (ដប់ប្រាំមួយ) ឆ្នាំ មិនអាចត្រូវបានឃាត់ខ្លួនហួសរយៈពេល ៣៦ ម៉ោងឡើយ។ ប៉ុន្តែប្រសិនបើអនីតិជនដែលមានអាយុចាប់ពី ១៦ (ដប់ប្រាំមួយ) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ បានប្រព្រឹត្តបទឧក្រិដ្ឋ មិនត្រូវបានឃាត់ខ្លួនហួសរយៈពេល ៤៨ ម៉ោងឡើយ។

ថេរវេលានៃការឃាត់ខ្លួនអនីតិជន ត្រូវចាប់គិតពីពេលដែលបានបញ្ជូនខ្លួនអនីតិជននោះមកដល់អង្គភាពនគរបាលយុត្តិធម៌ ឬកងរាជអាវុធហត្ថ។

### ១.៣.៤. ការជូនដំណឹង

មន្ត្រីនគរបាលយុត្តិធម៌ត្រូវជូនដំណឹងជាបន្ទាន់ទៅអ្នកតំណាងដែលច្បាប់បានកំណត់របស់អនីតិជន បន្ទាប់ពីការចាប់ខ្លួន ឬឃាត់ខ្លួនអនីតិជននោះ។ ក្នុងករណីមិនអាចផ្តល់ដំណឹងនេះជាបន្ទាន់ត្រូវជូនដំណឹងដល់អ្នកតំណាងដែលច្បាប់បានកំណត់ក្នុងរយៈពេលយ៉ាងខ្លីបំផុតដែលអាចធ្វើបានអំពី៖

១.មូលហេតុនៃការចាប់ខ្លួន ឬឃាត់ខ្លួន និងប្រភេទនៃបទល្មើស

២.ទីកន្លែងដែលអនីតិជនកំពុងស្ថិតនៅ

៣.សិទ្ធិចូលរួមរបស់អ្នកតំណាងដែលច្បាប់បានកំណត់នៅក្នុងអង្គភាពនគរបាល។[20]

[18] មាត្រា ២៣ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[19] មាត្រា ៩៦ កថាខណ្ឌទី៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[20] មាត្រា ១៨ កថាខណ្ឌទី១ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

ក្នុងករណីមិនអាចទាក់ទងអ្នកតំណាងដោយច្បាប់កំណត់របស់អនីតិជនបាន មន្ត្រីនគរបាលយុត្តិធម៌ត្រូវប្រឹងប្រែងទាក់ទងអ្នកទំនុកបម្រុងដែលជ្រើសរើសដោយអនីតិជន ឬដោយមន្ត្រីនគរបាលយុត្តិធម៌ ដោយមានការយល់ព្រមពីអនីតិជននោះ[21]។

មន្ត្រីនគរបាលយុត្តិធម៌ ត្រូវជូនដំណឹងភ្លាមទៅភ្នាក់ងារសង្គមកិច្ច បន្ទាប់ពីអនីតិជននោះត្រូវបាននាំមកដល់អង្គភាពនគរបាលយុត្តិធម៌ ដើម្បីផ្តល់សេវាគាំទ្រសេវាផ្លូវចិត្ត និងសង្គមដល់អនីតិជននោះ[22]។

ភ្នាក់ងារសង្គមកិច្ចគឺជាភ្នាក់ងារមួយដែលជួយអនីតិជន ក្នុងករណីដែលអនីជនបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ដើម្បីការពារផលប្រយោជន៍របស់អនីតិជននោះ។ ភ្នាក់ងារសង្គមកិច្ចមានភារៈកិច្ច ៖

- ជួយអនីតិជននៅគ្រប់ដំណាក់កាលនីតិវិធី ជាពិសេសនៅក្នុងដំណាក់ដំបូងនៃនីតិវិធីរបស់មន្ត្រីនគរបាលយុត្តិធម៌ និងក្នុងពន្ធនាគារ ដើម្បីប្រមូលពត៍មានវាយតម្លៃ និងផ្តល់សេវាបន្ទាន់ដល់អនីតិជន។
- ប្រមូលពត៌មានស្តីពីស្ថានភាព អាកប្បកិរិយា ប្រវត្តិអប់រំ ការសិក្សា លក្ខខណ្ឌដែលទាក់ទងនឹងការរស់នៅ ការរីកលូតលាស់ និងពត៌មានផ្សេងទៀតដែលពាក់ព័ន្ធទៅនឹងកម្រិតយល់ដឹង បញ្ហាអារម្មណ៍ផ្លូវចិត្ត សង្គមរបស់អនីតិជន ដើម្បីរៀបចំ និងផ្តល់របាយការណ៍ និងយោបល់ប៉ាន់ប្រមាណស្តីពីសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជនជូន ចៅក្រម ព្រះរាជអាជ្ញា និងតុលាការ។
- ផ្តល់ការគាំទ្រផ្លូវចិត្ត និងសង្គមដល់អនីតិជននៅគ្រប់ដំណាក់កាលនីតិវិធី
- រៀបចំ និងផ្តល់ផែនការបង្វែរ ជូនអាជ្ញាធរទទួលបន្ទុកបង្វែរ ដើម្បីពិនិត្យ និងសម្រេច
- ផ្តល់សេវាស្តារនីតិសម្បទា និងការធ្វើសមាហរណកម្មដល់អនីតិជន
- ភារៈកិច្ចផ្សេងទៀតដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងដែលទទួលបន្ទុកវិស័យសង្គមកិច្ច។[23]

មន្ត្រីនគរបាលយុត្តិធម៌ ត្រូវជូនដំណឹងទៅមេធាវីរបស់អនីតិជន ប្រសិនបើមាន។ ក្នុងករណីដែលគ្មានការជ្រើសរើស មន្ត្រីនគរបាលយុត្តិធម៌ត្រូវរកមេធាវីដោយមិនយកកម្រៃឲ្យអនីតិជននោះឲ្យបានឆាប់បំផុតតាមដែលអាចធ្វើបាន បន្ទាប់ពីអនីតិជននោះត្រូវបាននាំមកអង្គភាពនគរបាលយុត្តិធម៌[24]។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវមាន

[21] មាត្រា ១៨ កថាខណ្ឌទី២ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[22] មាត្រា ១៨ កថាខណ្ឌទី៣ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[23] មាត្រា ១១ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[24] មាត្រា ១៨ កថាខណ្ឌទី៤ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

បញ្ជីឈ្មោះមេធាវីសម្រាប់ឲ្យអនីតិជនធ្វើការជ្រើសរើស[25]។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវរកអ្នកបកប្រែភាសាដោយមិនយកកម្រៃឲ្យអនីតិជន ក្នុងករណីដែលអនីតិជននោះពុំមានអ្នកបកប្រែភាសាផ្ទាល់ខ្លួន[26]។

### ១.៣.៥. ការស្តាប់ចម្លើយ

មុននឹងចាប់ផ្តើមនីតិវិធីស្តាប់ចម្លើយ អនីតិជនទទួលបាននូវសិទ្ធិសន្ទនាជាលក្ខណៈឯកជន និងជាសម្ងាត់ជាមួយអ្នកតំណាង អ្នកទំនុកបម្រុង ភ្នាក់ងារសង្គមកិច្ច ឬមេធាវី ប្រសិនបើមានការស្នើសុំ។

នីតិវិធីនៃការស្តាប់ចម្លើយត្រូវបានចាប់ផ្តើម ត្រូវអនុលោមតាមវិធានការមួយចំនួនដូចជា[27] ៖

- ជាបឋមមន្ត្រីនគរបាលយុត្តិធម៌ ត្រូវប្រាប់អំពីសិទ្ធិជាមូលដ្ឋានរបស់អនីតិជន ដែលមានចែងនៅក្នុងមាត្រា ៦ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន។
- ការស្តាប់ចម្លើយ ត្រូវប្រព្រឹត្តទៅដោយមានវត្តមានរបស់មេធាវី ដោយប្រើប្រាស់នីតិវិធីកុមារមេត្រី ដោយមានលក្ខណៈជាឯកជន និងសម្ងាត់
- អ្នកតំណាងដោយច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុងរបស់អនីតិជន ឬភ្នាក់ងារសង្គមកិច្ច ដែលមានសិទ្ធិ អាចផ្តល់ជាជំនួយដល់អនីតិជន និងត្រូវបានផ្តល់សិទ្ធិចូលរួមក្នុងការស្តាប់ចម្លើយរបស់អនីតិជនបានផងដែរ
- ចុះនិទ្ទេសក្នុងកំណត់ហេតុ ក្នុងករណីដែល មេធាវី អ្នកតំណាងដោយច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុងរបស់អនីតិជន ឬភ្នាក់ងារសង្គមកិច្ច អវត្តមាននៅក្នុងពេលស្តាប់ចម្លើយ ដោយបញ្ជាក់ពីមូលហេតុនៃអវត្តមាន ហើយបញ្ចូលទៅក្នុងសំណុំរឿងអនីតិជននោះ។

ក្រោយការបញ្ចប់ការស្តាប់ចម្លើយ អនីតិជន មេធាវី អ្នកតំណាងដោយច្បាប់បានកំណត់ អ្នកទំនុកបម្រុង ឬភ្នាក់ងារសង្គមកិច្ច មានសិទ្ធិក្នុងការអានកំណត់ហេតុស្តាប់ចម្លើយ។ អនីតិជនអាចអាចសុំកែប្រែ ឬបន្ថែមបន្ថយចម្លើយលើកំណត់ហេតុស្តាប់ចម្លើយបាន មុននឹងធ្វើការចុះហត្ថលេខា ឬផ្តិតមេដៃលើកំណត់ហេតុដែលចុះនិទ្ទេស រួចហើយអ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុង ឬភ្នាក់ងារសង្គមកិច្ច ដែលមានវត្តមានត្រូវចុះហត្ថលេខា ឬផ្តិតម្រាមដៃលើកំណត់ហេតុនោះ។

### ១.៣.៦. ការបញ្ចប់ និងការបញ្ជូនខ្លួនទៅតំណាងអយ្យការ

មន្ត្រីនគរបាលយុត្តិធម៌ ចាំបាច់ត្រូវបញ្ចប់ដំណើរការស៊ើបអង្កេតរបស់ខ្លួនឲ្យបានឆាប់រហ័ស និងលឿនបំផុតតាមដែលអាចធ្វើបាន សម្រាប់ជាឧត្តមប្រយោជន៍ដល់អនីតិជន ដោយហេតុថារយៈពេលនៃការឃាត់ខ្លួន

[25] មាត្រា ១៨ កថាខណ្ឌទី៥ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[26] មាត្រា ១៨ កថាខណ្ឌទី៦ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[27] មាត្រា ២២ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

គឺមន្ត្រីនគរបាលយុត្តិធម៌អាចឃាត់ខ្លួនអនីតិជនបានរយៈពេលត្រឹម ៤៨ម៉ោង ប៉ុណ្ណោះ ហើយមិនអាចបន្តរយៈពេលឃាត់ខ្លួនបានទេ ប្រសិនបើគ្មានតម្រុយពីបទល្មើសដែលអនីតិជននោះបានប្រព្រឹត្ត ដូច្នេះគឺត្រូវធ្វើការដោះលែងអនីតិជននោះឲ្យត្រឡប់ទៅវិញ ដោយមានការធានាពីឪពុកម្តាយ ឬអាណាព្យាបាលរបស់អនីតិជននោះ។

ក្រោយពីធ្វើការស៊ើបអង្កេតបានចប់សព្វគ្រប់ហើយ មន្ត្រីនគរបាលយុត្តិធម៌ត្រូវរៀបចំ និងបញ្ជូនសំណុំរឿងឯកសារ ភស្តុតាងផ្សេងៗ ដែលពាក់ព័ន្ធ ព្រមទាំងអនីតិជននោះទៅកាន់តំណាងអយ្យការឲ្យបានឆាប់បំផុតស្របតាមបញ្ញត្តិមាត្រា ១០៤ នៃក្រមព្រហ្មទណ្ឌ។

## ផ្នែកទី២៖ ដំណាក់កាលអយ្យការ និងការចោទប្រកាន់

### ២.១. គោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់

គោលការណ៍កាលានុវត្តភាពនេះគឺជាគោលការណ៍ដែលត្រូវបាន ក្រមនីតិវិធីព្រហ្មទណ្ឌបច្ចុប្បន្នរបស់កម្ពុជាយកមកប្រើប្រាស់សម្រាប់ឲ្យអង្គការអយ្យការធ្វើការពិចារណាមុននឹងធ្វើចំណាត់ការនីតិវិធី។ នៅក្នុងគោលការណ៍នេះព្រះរាជអាជ្ញាជាអ្នកដែលមានសិទ្ធិក្នុងការសម្រេចដោយការថ្លឹងថ្លែងមុននឹងសម្រេចថា ធ្វើការចោទប្រកាន់ ឬតម្កល់រឿងទុកឥតចាត់ការ។

គោលការណ៍នេះបានផ្តល់ផលវិជ្ជមានដែលផ្តល់ប្រសិទ្ធិភាពក្នុងការស្វែងរកភស្តុតាងដាក់បន្ទុក ដោយគ្មានការកកស្ទះសំណុំរឿង ព្រមទាំងផ្តល់នូវភាពឆាប់រហ័ស និងយុត្តិធម៌ក្នុងសង្គម។

### ២.២. សមត្ថកិច្ច និងអំណាចរបស់តំណាងអយ្យការ

បណ្តឹងអាជ្ញាត្រូវធ្វើឡើងក្នុងនាមផលប្រយោជន៍ទូទៅដោយអយ្យការ។ អយ្យការធ្វើការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌដែលពាក់ព័ន្ធនឹងអនីតិជន។ តំណាងអយ្យការដែលនឹងត្រូវចាត់ការរឿងក្តីរបស់អនីតិជនត្រូវទទួលការបណ្តុះបណ្តាលជំនាញឯកទេសផ្នែកសិទ្ធិកុមារ ក៏ដូចជាច្បាប់ និងបទប្បញ្ញត្តិផ្សេងៗដែលទាក់ទងទៅនឹងយុត្តិធម៌អនីតិជន[28]។

#### ២.២.១. ការពិនិត្យឯកសារសំណុំរឿង និងការផ្ទៀងផ្ទាត់អាយុរបស់អនីតិជន

នៅដំណាក់កាលអយ្យការ ជាបឋមគឺត្រូវពិនិត្យអំពីអាយុរបស់អនីតិជន ដើម្បីបញ្ជាក់ឲ្យបានច្បាស់ថាជនសង្ស័យ ពិតជាគ្រប់អាយុ ឬលើសពី ១៤ (ដប់បួន) ឆ្នាំ ដើម្បីអាចទទួលខុសត្រូវចំពោះបទល្មើសដែលខ្លួនបានប្រព្រឹត្ត។ ដូច្នេះហើយដើម្បីសបញ្ជាក់អំពីអាយុអនីតិជននោះឲ្យច្បាស់លាស់ តំណាងអយ្យការត្រូវពិនិត្យទៅលើឯកសារផ្លូវការដែលអាចជឿទុកចិត្តបាន ឯកសារទាំងនោះអាចជា សំបុត្រកំណើត សៀវភៅស្នាក់នៅសៀវភៅគ្រួសារ ឬឯកសារផ្សេងៗទៀតជាអាទិ៍។

[28] មាត្រា ២៤ កថាខណ្ឌទី២ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

ក្នុងករណីប្រសិនបើមានការសង្ស័យ ឬមិនអាចបញ្ជាក់បានអំពីអាយុពិតរបស់អនីតិជននោះ តំណាងអយ្យការត្រូវបើកការស៊ើបអង្កេតបឋមឲ្យបានឆាប់បំផុត ដើម្បីធ្វើការស្វែងរកឲ្យបានច្បាស់អំពីអាយុរបស់អនីតិជននោះ[29]។ ប៉ុន្តែប្រសិនបើការស៊ើបអង្កេតនោះ នៅតែមិនអាចបង្ហាញពីអាយុពិតរបស់អនីតិជននោះ ព្រះរាជអាជ្ញាត្រូវចេញដីកាសន្និដ្ឋានបញ្ជូនរឿងនេះទៅឲ្យចៅក្រមស៊ើបសួរ[30]។

ប្រសិនបើតំណាងអយ្យការពិនិត្យឃើញថា អនីតិជននោះមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ គិតពីថ្ងៃដែលគេត្រូវបានសង្ស័យថាបានចូលរួមប្រព្រឹត្តបទល្មើស ព្រះរាជអាជ្ញាត្រូវសម្រេចតម្កល់រឿងទុកឥតចាត់ការ និងប្រគល់អនីតិជននោះ ទៅឲ្យអ្នកតំណាងដែលច្បាប់បានកំណត់វិញ[31]

### ២.២.២. ការស្តាប់ចម្លើយអនីតិជន

ក្រោយពីបានទទួលសំណុំរឿងពីមន្ត្រីនគរបាលយុត្តិធម៌ និងផ្ទៀងផ្ទាត់អាយុរបស់អនីតិជនហើយ តំណាងអយ្យការនឹងធ្វើការសួរចម្លើយរបស់អនីតិជននោះ ក៏ប៉ុន្តែមុននឹងធ្វើការសាកសួរអនីតិជន តំណាងអយ្យការត្រូវជូនដំណឹងជាមុនទៅឪពុកម្តាយរបស់អនីតិជន ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន។ ព្រះរាជអាជ្ញាត្រូវប្រាប់អនីតិជន និងអ្នកដែលចូលរួមស្តាប់ចម្លើយ អំពីសិទ្ធិដែលមានចែងនៅក្នុងមាត្រា ៦ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ដោយប្រើភាសា និងអាកប្បកិរិយាសមស្របទៅនឹងកម្រិតនៃការយល់ដឹងរបស់អនីតិជននោះ មុននឹងធ្វើការស្តាប់ចម្លើយ។ ក្នុងករណីដែលគ្មានការជ្រើសរើស ព្រះរាជអាជ្ញាត្រូវចាត់តាំងមេធាវី ដោយមិនយកកម្រៃឲ្យអនីតិជននោះ[32]។

ការស្តាប់ចម្លើយរបស់អនីតិជនត្រូវធ្វើជាសម្ងាត់ និងប្រើប្រាស់នីតិវិធីកុមារមេត្រី។ ការស្តាប់ចម្លើយនេះត្រូវមានវត្តមានរបស់មេធាវី ភ្នាក់ងារសង្គមកិច្ច អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុងរបស់អនីតិជន។ ព្រះរាជអាជ្ញាមិនអនុញ្ញាតឲ្យអ្នកតំណាងដែលកំណត់ចូលរួមស្តាប់ចម្លើយបាន ប្រសិនបើវត្តមានអ្នកទាំងនោះផ្ទុយនឹងឧត្តមប្រយោជន៍របស់អនីតិជន។ ការមិនអនុញ្ញាតនេះត្រូវមានការពិគ្រោះយោបល់ជាមួយមេធាវី ឬភ្នាក់ងារសង្គមកិច្ច និងអនីតិជន។ ក្នុងករណីអវត្តមានជនណាមួយខាងលើព្រះរាជអាជ្ញាត្រូវចុះនិទ្ទេសក្នុងកំណត់ហេតុស្តាប់ចម្លើយដោយបញ្ជាក់ពីមូលហេតុ[33]។

បន្ទាប់ពីបញ្ចប់ការស្តាប់ចម្លើយភ្លាម អនីតិជនមានសិទ្ធិអានកំណត់ហេតុស្តាប់ចម្លើយ។ ក្នុងករណីប្រសិនអនីតិជនមិនអាចអានកំណត់ហេតុស្តាប់ចម្លើយបាន ក្រឡាបញ្ជី ឬអ្នកបកប្រែត្រូវអានកំណត់ហេតុស្តាប់

[29] មាត្រា ២៥ កថាខណ្ឌទី២ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[30] មាត្រា ២៥ កថាខណ្ឌទី៣ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[31] មាត្រា ២៧ កថាខណ្ឌទី១ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[32] មាត្រា ២៦ កថាខណ្ឌទី១ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[33] មាត្រា ២៦ កថាខណ្ឌទី២ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

ចម្លើយនោះឲ្យអនីតិជនស្តាប់។ អនីតិជនអាចសុំកែប្រែ ឬបន្ថែមបន្ថយចម្លើយលើកំណត់ហេតុស្តាប់ចម្លើយបាន មុននឹងចុះហត្ថលេខា ឬផ្តិតម្រាមដៃ[34]។

ព្រះរាជអាជ្ញាត្រូវអនុញ្ញាតឲ្យមេធាវី ឬឳពុកម្តាយរបស់អនីតិជន ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬអ្នកទំនុកបម្រុង ឬភ្នាក់ងារសង្គមកិច្ចអានកំណត់ហេតុស្តាប់ចម្លើយបាន[35]។ មេធាវី អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុងអនីតិជន ភ្នាក់ងារសង្គមកិច្ចដែលមានវត្តមាន ត្រូវចុះហត្ថលេខា ឬផ្តិតម្រាមដៃលើកំណត់ហេតុ។ ក្នុងករណីដែលអនីតិជន ឬអ្នកចូលរួមណាមួយមិនព្រមចុះហត្ថលេខា ឬផ្តិតម្រាមដៃលើកំណត់ហេតុ ព្រះរាជអាជ្ញាត្រូវចុះនិទ្ទេសក្នុងកំណត់ហេតុស្តាប់ចម្លើយ[36]។

### ២.៣. សេចក្តីសម្រេចរបស់តំណាងអយ្យការ

ក្រោយពេលតំណាងអយ្យការបានបញ្ចប់នូវការស្តាប់ចម្លើយរបស់អនីតិជន ព្រមទាំងពិនិត្យទៅលើភស្តុតាងរួចហើយ តំណាងអយក្យការនឹងធ្វើការសម្រេចសេចក្តី ដោយការសម្រេចនេះតំណាងអយ្យការអាចបើកការស៊ើបសួរតាមដីកាសន្និដ្ឋានបញ្ជូនសំណុំរឿងឲ្យស៊ើបសួរ តម្កល់រឿងទុកឥតចាត់ការ ការប្រើប្រាស់វិធានការបង្វែរ ឬនីតិវិធីបង្ហាញខ្លួនភ្លាម?

#### ២.៣.១. ការសម្រេចចោទប្រកាន់

##### ២.៣.១.១.ការបើកការស៊ើបសួរ

ព្រះរាជអាជ្ញាអាចបើកការស៊ើបសួរ តាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ដែលត្រូវប្តឹងទៅចៅក្រមស៊ើបសួរ។ ការស៊ើបសួរអាចប្រឆាំងលើបុគ្គលម្នាក់ ឬច្រើននាក់ ដោយមានចង្អុលប្រាប់អំពីឈ្មោះ ឬប្រឆាំងទៅលើអញ្ញាតជន[37]។

ដីកាបញ្ជូនរឿងឲ្យស៊ើបសួររួមមាន[38] ៖

-សេចក្តីសង្ខេបនៃអង្គហេតុ

-ការកំណត់ឈ្មោះបទល្មើស

-ការបង្ហាញអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស

-ឈ្មោះបុគ្គលដែលត្រូវរងការស៊ើបសួរ ប្រសិនបើអាចកំណត់បាន។

[34] មាត្រា ២៦ កថាខណ្ឌទី៤ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦
[35] មាត្រា ២៦ កថាខណ្ឌទី៥ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦
[36] មាត្រា ២៦ កថាខណ្ឌទី៦ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦
[37] មាត្រា ៤៤ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧
[38] មាត្រា ៤៤ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧

ទម្រង់ការនេះមានលក្ខណៈដាច់ខាតត្រូវគោរព បើពុំដូច្នោះទេ ដីកាបញ្ជូនរឿងឲ្យស៊ើបសួរនេះត្រូវចាត់ទុកជាមោឃៈ។

### ២.៣.១.២.ការបញ្ជូនទៅជំនុំជម្រះផ្ទាល់

ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់គឺជាបញ្ជាឲ្យជនជាប់ចោទចូលទៅបង្ហាញខ្លួននៅមុខតុលាការជាន់ដំបូង។ ដីកាបញ្ជូនទៅជំនុំជម្រះផ្ទាល់រួមមាន[39] ៖

-សេចក្តីសង្ខេបនៃអង្គហេតុ

-ការកំណត់ឈ្មោះបទល្មើស

-ការបង្ហាញអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស។

ដីកានេះត្រូវចង្អុលបង្ហាញប្រាប់ពីតុលាការ ព្រមទាំងទីកន្លែង កាលបរិច្ឆេទ និងម៉ោងពេលនៃសវនាការ ដីកានេះត្រូវបញ្ជាក់ថា ជនជាប់ចោទអាចពឹងមេធាវីឲ្យអមខ្លួនបាន[40]។

### ២.៣.១.៣. នីតិវិធីក្នុងការបង្ហាញខ្លួនភ្លាម

ចំពោះនីតិវិធីក្នុងការបង្ហាញខ្លួនភ្លាម មិនត្រូវធ្វើបាននោះទេ ដោយហេតុថាលក្ខខណ្ឌនៃនីតិវិធីក្នុងការបង្ហាញខ្លួនបើផ្អែកតាមមាត្រា ៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានបញ្ញត្តិត្រង់កថាខណ្ឌទី១ ចំណុចទី៣ បានបញ្ជាក់ថា ការបង្ហាញខ្លួនភ្លាមធ្វើបានចំពោះជនជាប់ចោទជានីតិជន។ ដូច្នេះតំណាងអយ្យការ មិនត្រូវចោទប្រកាន់អនីតិជន ដោយប្រើប្រាស់នីតិវិធីបង្ហាញខ្លួនភ្លាមបាននោះទេ។

## ២.៣.២. ការសម្រេចមិនចោទប្រកាន់

### ២.៣.២.១.ការប្រើប្រាស់វិធានការបង្វែរ

ប្រសិនបើអនីតិជននោះមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ គិតមកត្រឹមថ្ងៃដែលគេសង្ស័យថាបានចូលរួមប្រព្រឹត្តបទល្មើស ព្រះរាជអាជ្ញាត្រូវសម្រេចតម្កល់រឿងទុកឥតចាត់ការ និងប្រគល់អនីតិជននោះទៅឲ្យ ឪពុកម្តាយ ឬអាណាព្យាបាលវិញ[41]។

ក្នុងករណីដែលអនីតិជននោះត្រូវការកិច្ចការពារ និងថែទាំ ព្រះរាជអាជ្ញាត្រូវបញ្ជូនអនីតិជននោះទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានីខេត្ត ដើម្បីចាត់វិធានការសម្រេចស្របទៅតាមសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន[42]។

---

[39] មាត្រា ៤៦ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧

[40] មាត្រា ៤៦ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧

[41] មាត្រា ២៧ កថាខណ្ឌទី១ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[42] មាត្រា ២៧ កថាខណ្ឌទី២ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

### ២.៣.២.២.ការប្រើប្រាស់វិធានការបង្វែរ

ចំពោះអនីតិជនមានអាយុចាប់ពី ១៤ (ដប់បួន)ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី)ឆ្នាំ បានប្រព្រឹត្តបទលហុ ឬបទមជ្ឈិម ព្រះរាជអាជ្ញាត្រូវពិចារណាជាបឋមទៅលើការបង្វែរដូចមានចែងនៅក្នុងជំពូកទី១០ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន។ ក្នុងករណីព្រះរាជអាជ្ញាសម្រេចបង្វែរ បទប្បញ្ញត្តិនៃជំពូកទី១០ នេះត្រូវយកមកអនុវត្ត។ ក្នុងករណីនេះព្រះរាជអាជ្ញាត្រូវសម្រេចផ្អាកនីតិវិធីចោទប្រកាន់ដោយដីកាសម្រេច។ ប្រសិនបើការរៀបចំផែនការបង្វែរត្រូវការពេលវេលា ព្រះរាជអាជ្ញាអាចផ្អាកនីតិវិធីចោទប្រកាន់ និងបង្គាប់ឲ្យប្រគល់អនីតិជនទៅឲ្យឪពុកម្តាយ ឬអ្នកអាណាព្យាបាល ឬមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ដើម្បីទទួលបានការគ្រប់គ្រង និងថែទាំ ដើម្បីរង់ចាំអនុវត្តផែនការបង្វែរ។ ក្នុងករណីអនុវត្តផែនការបង្វែរមិនបានជោគជ័យ ព្រះរាជអាជ្ញាអាចចេញដីកាសម្រេចបង្វែរជាថ្មី ដោយពិចារណាទៅលើមូលហេតុដែលនាំបរាជ័យក្នុងការអនុវត្តផែនការបង្វែរទស្សនៈរបស់អនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ និងការពិគ្រោះយោបល់ជាមួយភ្នាក់ងារសង្គមកិច្ច ឬចាត់វិធានការតាមនីតិវិធី[43]។

ក្នុងការអនុវត្តវិធានការបង្វែរ ព្រះរាជអាជ្ញាត្រូវជូនដំណឹងដល់ជនរងគ្រោះ ឬអ្នកតំណាងស្របច្បាប់របស់ជនរងគ្រោះ ក្នុងករណីជនរងគ្រោះជាអនីតិជន និងមេធាវីរបស់អនីតិជនអំពីការសម្រេចផ្អាកនីតិវិធីចោទប្រកាន់។ ជនរងគ្រោះ ឬអ្នកតំណាងស្របច្បាប់របស់ជនរងគ្រោះ អាចប្តឹងទាមទារសំណងទៅតុលាការរដ្ឋប្បវេណី។ ព្រះរាជអាជ្ញា ត្រូវសម្រេចចេញដីកាតម្កល់រឿងទុកឥតចាត់ការ ក្នុងករណីដែលការអនុវត្តផែនការបង្វែរទទួលបានជោគជ័យដោយផ្អែកលើលទ្ធផលនៃរបាយការណ៍ដែលបញ្ជាក់រួមគ្នាពីភ្នាក់ងារសង្គមកិច្ច និងអ្នកទទួលបន្ទុកអនុវត្តផែនការបង្វែរ។

## ផ្នែកទី៣ ៖ ដំណាក់កាលស៊ើបសួរ

ដំណាក់កាលស៊ើបសួររបស់ចៅក្រមស៊ើបសួរ ជាដំណាក់កាលមួយដែលមានសារៈសំខាន់ នៅក្នុងដំណើរការជម្រះក្តីនៃរឿងក្តីព្រហ្មទណ្ឌ ដែលចៅក្រមស៊ើបសួរធ្វើការប្រមូលនូវភស្តុតាងចាំ បាច់ដែលពាក់ព័ន្ធសម្រាប់សម្រេចសេចក្តីចំពោះការចោទប្រកាន់មុននឹងបិទបញ្ចប់ការស៊ើបសួរ។ នៅក្នុងការស៊ើបសួរទាំងឡាយណាដែលពាក់ព័ន្ធទៅនឹង រឿងក្តីរបស់អនីតិជន គឺជាសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរដែលមានជំនាញទាក់ទងនឹងអនីតិជន[44]។ ចៅក្រមស៊ើបសួរត្រូវលើកយករឿងក្តីព្រហ្មទណ្ឌរបស់អនីតិជនយកមកចាត់ការជាអាទិភាព ជាពិសេសរឿងក្តីអនីតិជនដែលកំពុងជាប់ឃុំបណ្តោះអាសន្ន ។

[43] មាត្រា ២៨ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[44] មាត្រា ៣១ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

### ៣.១. កិច្ចស៊ើបសួរ

នៅក្នុងដំណាក់កាលចៅក្រមស៊ើបសួរ យើងឃើញថាក៏មានកិច្ចមួយចំនួនផងដែរ ដែលជាកាតព្វកិច្ចរបស់ចៅក្រមស៊ើបសួរត្រូវបំពេញ។ កិច្ចទាំងនោះយើងឃើញមានចែងផងដែរផ្អែកតាមបទដ្ឋានគតិយុត្តិសំខាន់ៗដែលមានចែងនៅក្នុងបញ្ញត្តិ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ស្តីពីយុត្តិធម៌អនីតិជនជាដើម។

#### ៣.១.១ ការជូនដំណឹងអំពីការដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យ

ក្រោយពីទទួលបានដីកាបញ្ជូនសំណុំរឿងឲ្យស៊ើបសួររបស់តំណាងអយ្យការ ចៅក្រមស៊ើបសួរត្រូវធ្វើចំណាត់ការបើកការស៊ើបសួរភ្លាម។ អនីតិជនដែលជាជនត្រូវចោទ ត្រូវមានមេធាវីក្នុងអំឡុងពេលស្តាប់ចម្លើយដូចដែលមានចែងនៅក្នុងលក្ខន្តិកៈមេធាវី។ ចៅក្រមស៊ើបសួរត្រូវទុកអំឡុងពេលសមរម្យមួយដើម្បីឲ្យមេធាវីធ្វើការសិក្សាទៅលើសំណុំរឿង និងពិភាក្សាជាមួយអនីតិជន មុនដំណើរការកិច្ចសួរចម្លើយ។

នៅពេលអនីតិជនបង្ហាញខ្លួនជាលើកដំបូង ចៅក្រមស៊ើបសួរត្រូវពិនិត្យទៅលើអត្តសញ្ញាណ របស់អនីតិជន រួចត្រូវប្រាប់ឲ្យបានដឹងពីរឿងរ៉ាវដែលចោទប្រកាន់ ព្រមទាំងឈ្មោះបទល្មើសដែល ច្បាប់បានកំណត់ និងសិទ្ធិជាមូលដ្ឋានរបស់អនីតិជននៅក្នុងនីតិវិធីផងដែរ។ ចៅក្រមស៊ើបសួរត្រូវ ជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុង និងភ្នាក់ងារសង្គមកិច្ចអំពីការដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យ។ វិធានដែលបានបញ្ញត្តិនៅក្នុងមាត្រានេះមាន លក្ខណៈដាច់ខាតត្រូវតែគោរពតាម បើមិនដូច្នេះទេនឹងនាំឲ្យមានការមោឃភាពនីតិវិធី[45]។

#### ៣.១.២ ការប្រាប់អំពីសិទ្ធិរបស់អនីតិជន

អនីតិជនគ្រប់រូបដែលជាជនជាប់សង្ស័យ ឬត្រូវចោទថាបានប្រព្រឹត្តបទល្មើស ត្រូវបានទទួលនូវសិទ្ធិជាមូលដ្ឋាននៅក្នុងដំណើរការនីតិវិធីពិសេសនៅក្នុងកិច្ចនៃការស៊ើបសួរដែលធ្វើឡើងដោយចៅក្រមស៊ើបសួរ ដូចតទៅ[46] ៖

- សិទ្ធិមិនផ្តល់ចម្លើយនៅពេលដែលមាន ឬគ្មានវត្តមានមេធាវី
- សិទ្ធិមិនទទួលការបង្ខិតបង្ខំឲ្យឆ្លើយដាក់បន្ទុកលើខ្លួនឯង
- សិទ្ធិរក្សាការសម្ងាត់នៃជីវិតឯកជន
- សិទ្ធិទទួលបានការពិនិត្យសុខភាព និងការព្យាបាល
- សិទ្ធិទទួលបានការឲ្យដំណឹងអំពីបទចោទប្រកាន់
- សិទ្ធិក្នុងការជូនដំណឹងអំពីការចាប់ខ្លួនទៅដល់អ្នកតំណាងដែលច្បាប់បានកំណត់

[45] មាត្រា៣៣ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[46] មាត្រា៦ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

- សិទ្ធិទទួលបានជំនួយពីមេធាវីតាមរយៈការជ្រើសរើស និងការចាត់តាំងដោយពុំយកកម្រៃ ស្របតាមលក្ខខណ្ឌដែលចែងដោយច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ចាប់ពីដំណាក់កាលដំបូងបំផុតនៃនីតិវិធី
- សិទ្ធិឲ្យមានការចូលរួមរបស់អ្នកតំណាងដែលច្បាប់បានកំណត់ នៅគ្រប់ដំណើរការរឿងក្តី ប្រសិនបើការចូលរួមនេះមិនផ្ទុយនឹងឧត្តមប្រយោជន៍របស់អនីតិជន
- សិទ្ធិទទួលបានជំនួយពីអ្នកបកប្រែភាសាដោយមិនយកកម្រៃ ប្រសិនបើមានការចាំបាច់
- សិទ្ធិបង្ហាញភស្តុតាង
- សិទ្ធិស្នើសុំឲ្យកោះហៅសាក្សី និងសួរសាក្សី
- សិទ្ធិស្នើសុំអនុញ្ញាតឲ្យនៅក្រៅឃុំ
- សិទ្ធិស្នើសុំឲ្យកែប្រែវិធានការត្រួតពិនិត្យតាមផ្លូវតុលាការ
- សិទ្ធិទំនាក់ទំនងជាមួយនឹងស្ថានទូត ស្ថានកុងស៊ុល ក្នុងករណីដែលអនីតិជននោះជាជនបរទេស
- សិទ្ធិផ្សេងៗដែលមានចែងនៅក្នុងបទដ្ឋានគតិយុត្តជាធរមាន។

ក្រោយពេលដែលអនីតិជនដែលត្រូវបានជាប់សង្ស័យ ឬត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តបទល្មើសបានធ្វើការបង្ហាញខ្លួនជាលើកដំបូងហើយនោះ ចៅក្រមស៊ើបសួរត្រូវពិនិត្យផ្ទៀងផ្ទាត់អំពីអត្តសញ្ញាណរបស់អនីតិជននោះ រួចប្រាប់អំពីសិទ្ធិជាមូលដ្ឋានទាំងឡាយដែលបានរៀបរាប់ខាងលើនេះ ដើម្បីឲ្យអនីតិជនបានដឹងអំពីសិទ្ធិដែលខ្លួនទទួលបានស្របច្បាប់ទាំងឡាយ។

### ៣.១.២ ការស្តាប់ចម្លើយ និងជំនួយរបស់មេធាវី

ចៅក្រមស៊ើបសួរត្រូវស្តាប់ចម្លើយរបស់អនីតិជនដោយផ្ទាល់ និងមានក្រឡាបញ្ជីម្នាក់ជាជំនួយការក្នុងការកត់ត្រា។ ការស្តាប់ចម្លើយទៅលើជនសង្ស័យ ឬជនត្រូវចោទដែលជាអនីតិជនត្រូវធ្វើឡើងជាសម្ងាត់ និងអនុវត្តទៅតាមនីតិវិធីកុមារមេត្រី[47]។ នីតិវិធីកុមារមេត្រី ជានីតិវិធីដែលមានលក្ខណៈលើកទឹកចិត្តឲ្យអនីតិជនចូលរួមក្នុងរឿងក្តី តាមរយៈការប្រើប្រាស់ភាសា និងអាកប្បកិរិយាក្នុងកម្រិតដែលអនីតិជនអាចយល់ដឹងបាន ស្របទៅដោយបរិយាកាសដែលផ្តល់ឲ្យអនីតិជននូវសុវត្ថិភាព សន្តិភាព និង តម្រូវការជាមូលដ្ឋាន[48]។ បានន័យថា នៅគ្រប់ដំណាក់កាលនៃនីតិវិធីរឿងក្តីអនីតិជន តុលាការត្រូវអនុវត្តជានិច្ចនូវនីតិវិធីកុមារមេត្រី និងជាសម្ងាត់ ជាក់ស្តែងដូចជានៅក្នុងកិច្ចស៊ើបសួរដែលមានដូច ជាការសាកសួរចម្លើយ ជាដើម។

[47] មាត្រា៣៥ កថាខណ្ឌទី១ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[48] មាត្រា៤ ចំណុចទី៧ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

ការស្តាប់ចម្លើយរបស់អនីតិជន ជាចាំបាច់ត្រូវមានវត្តមានរបស់មេធាវីការពារសិទ្ធិអមជាមួយជានិច្ចព្រមទាំងអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុង របស់អនីតិជន និងភ្នាក់ងារសង្គមកិច្ចជាអាទិ៍ ក៏ប៉ុន្តែប្រសិនបើវត្តមានរបស់បុគ្គលទាំងអស់នេះផ្ទុយនឹងឧត្តមប្រយោជន៍របស់អនីតិជន ចៅក្រមស៊ើបសួរអាចមិនអនុញ្ញាតឲ្យអ្នកតំណាងដែលច្បាប់បានកំណត់ចូលរួមស្តាប់ចម្លើយបាន ដែលការណ៍នេះត្រូវពិភាក្សាជាមុនជាមួយមេធាវី ឬភ្នាក់ងារសង្គមកិច្ចព្រមជាមួយនឹងអនីតិជនដែលជាសាមីខ្លួន[49]។

ក្រោយបញ្ចប់ការសួរចម្លើយភ្លាម អនីតិជនមានសិទ្ធិនៅក្នុងការអានកំណត់ហេតុសួរចម្លើយ ឬស្នើសុំឲ្យក្រឡាបញ្ជីអានកំណត់ហេតុស្តាប់ចម្លើយឲ្យបានប្រសិន បើអនីតិជនពុំអាចអានដោយខ្លួនឯងបាន ដើម្បីឲ្យអនីតិជនផ្ទៀងផ្ទាត់ចម្លើយរបស់ខ្លួនមុននឹងចុះហត្ថលេខាឬផ្តិតមេដៃទទួលស្គាល់កំណត់ហេតុនោះ[50]។

ការសួរចម្លើយទៅលើអនីតិជនត្រូវតែអនុវត្តទៅ តាមវិធានដែលបានរៀបរាប់ខាងលើទាំងអស់នោះ បើពុំដូចនោះទេនឹងនាំឲ្យមានមោឃភាពនីតិវិធី ជាក់ជាពុំខាន[51]។

យ៉ាងណាមិញ វិធានការនៃការសាកសួរចម្លើយទៅលើអនីតិជន ចាំបាច់ត្រូវតែមានវត្តមានរបស់មេធាវីការពារសិទ្ធិអមជាមួយជានិច្ច ប្រសិនបើអវត្តមានមេធាវីចៅក្រមស៊ើបសួរត្រូវលើកពេលស្តាប់ចម្លើយ និងត្រូវកោះហៅមេធាវីដើម្បីចូលរួមស្តាប់ចម្លើយ។

ករណីអញ្ញត្តកម្មមួយដែលចៅក្រមស៊ើបសួរអាចធ្វើការសួរចម្លើយអនីតិជនដោយពុំចាំបាច់លើកថ្ងៃគឺករណីបន្ទាន់ដែលបណ្តាលមកពី គ្រោះថ្នាក់ដល់ស្លាប់ ឬបាត់បង់តម្រុយនៃភស្តុតាង កាលៈទេសៈបន្ទាន់នេះត្រូវចុះនិទ្ទេសទៅ ក្នុងកំណត់ហេតុស្តាប់ចម្លើយ[52]។

### ៣.២. អំណាចរបស់ចៅក្រមស៊ើបសួរ

#### ៣.២.១. ការប្រើប្រាស់វិធានការបង្វែរ

ក្រោយពីមានការចោទប្រកាន់តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់តំណាងអយ្យការ ចៅក្រមស៊ើបសួរនឹងបន្តនីតិវិធីដោយយុត្តាធិការស៊ើបសួររបស់ខ្លួនមុននឹងឈានដល់ការជំនុំជម្រះសម្រេចសេចក្តី។

ច្បាប់ស្តីពីអនីតិជនបានផ្តល់សិទ្ធិអំណាចដល់ចៅក្រមស៊ើបសួរ ក្នុងការអនុវត្តវិធានការបង្វែរនេះ ជាពិសេសនៅក្នុងរឿងក្តីដែលមានជនត្រូវចោទជាអនីតិជន។ ករណីដែលអនីតិជនត្រូវបានចោទប្រកាន់ថា

[49] មាត្រា៣៥ កថាខណ្ឌទី២ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦
[50] មាត្រា៣៥ កថាខណ្ឌទី៤ នៃច្បាប់ស្តីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦
[51] មាត្រា៣៥ កថាខណ្ឌទី៦ នៃច្បាប់ស្តីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦
[52] មាត្រា៣៦ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

បានប្រព្រឹត្តនូវបទឧក្រិដ្ឋ ឬបទមជ្ឈិមដែលមានស្ថានទម្ងន់ទោស ចៅក្រមស៊ើបសួរត្រូវធ្វើការពិចារណាជាអាទិភាពទៅលើការប្រើប្រាស់នូវវិធានការបង្វែរ មុននឹងប្រើនូវវិធានការផ្សេងពីនេះ។

### ៣.២.២ ការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

ក្រោយមានការចោទប្រកាន់របស់តំណាងអយ្យការ ចៅក្រមស៊ើបសួរអាចដាក់អនីតិជនឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបានគ្រប់ពេលជំនួសឲ្យការឃុំខ្លួនបណ្ដោះអាសន្ន ពីព្រោះការឃុំខ្លួនបណ្ដោះអាសន្នទៅលើអនីតិជន គឺជាវិធានការចុងក្រោយបង្អស់ដែលចៅក្រមស៊ើបសួរនឹងធ្វើការពិចារណាប្រើប្រាស់[53]។ ការដាក់អនីតិជនឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការត្រូវ អនុវត្តទៅតាមបទប្បញ្ញត្តិស្ដីពីការត្រួតពិនិត្យតាមផ្លូវតុលាការនៃក្រមនីតិវិធីព្រហ្មទណ្ឌ រួមបន្ថែមនឹង ចំណុចពិសេសមួយចំនួនដូចជា[54] ៖

- ឲ្យស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់ពីឪពុកម្ដាយ អ្នកអាណាព្យាបាលសម្រាប់អនីតិជនឬ អ្នកអាណាព្យាបាលទូទៅ ឬអ្នកទំនុកបម្រុងរបស់អនីតិជន ឬក្រុមគ្រួសារណាមួយសមស្រប
- ឲ្យស្ថិតនៅក្រោមការគ្រប់គ្រង និងការថែទាំនៅក្នុងមណ្ឌលណាមួយរបស់រដ្ឋ ឬមណ្ឌលណាមួយរបស់អង្គការមិនមែនរដ្ឋាភិបាលដែលមាននីតិសម្បទា និងថែទាំអនីតិជន
- បង្គាប់មិនឲ្យអនីតិជនចេញដើរហួសម៉ោងកំណត់ ឬសេពគ្រឿងស្រវឹង
- វិធានការផ្សេងទៀតដែលតុលាការយល់ឃើញថាសមស្រប។

### ៣.២.៣. ការបង្គាប់ឲ្យដោះលែងឲ្យនៅក្រៅឃុំ

ចៅក្រមស៊ើបសួរអាចបង្គាប់ដោះលែងអនីតិជនឲ្យនៅក្រៅឃុំបានគ្រប់ពេលដោយគំនិតផ្ដួចផ្ដើមរបស់ខ្លួន តែត្រូវជូនដំណឹងទៅព្រះរាជអាជ្ញាដើម្បីសុំយោបល់ ហើយព្រះរាជអាជ្ញាត្រូវផ្ដល់យោបល់ត្រឡប់មកវិញក្នុងរយៈពេលខ្លីបំផុត[55]។ យ៉ាងណាមិញ ចំពោះករណីបន្ទាន់ដែលចាំបាច់ ចៅក្រមស៊ើបសួរអាចបង្គាប់ឲ្យដោះលែងអនីតិជនភ្លាម ដោយពុំចាំបាច់រង់ចាំយោបល់របស់ព្រះរាជអាជ្ញានោះទេ ដោយត្រូវបញ្ជាក់ពីមូលហេតុបន្ទាន់នេះនៅក្នុងដីកាសម្រេចដោះលែងឲ្យនៅក្រៅឃុំរបស់ចៅក្រមស៊ើបសួរ[56]។

ក្រោយពីធ្វើការដោះលែងអនីតិជនឲ្យនៅក្រៅឃុំនោះហើយ ចៅក្រមស៊ើបសួរត្រូវបង្គាប់ឲ្យប្រគល់អនីតិជនទៅឲ្យអ្នកតំណាងដែលច្បាប់បានកំណត់ ឬបញ្ជូនអនីតិជនទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានីខេត្ត ទៅតាមស្ថានភាពសង្គម និងសុខុមាលភាព របស់អនីតិជនជាក់ស្ដែង[57]។

---

[53] មាត្រា៣៩ កថាខណ្ឌទី១ នៃច្បាប់ស្ដីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[54] មាត្រា៤០ នៃច្បាប់ស្ដីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[55] មាត្រា៤១ កថាខណ្ឌទី១ នៃច្បាប់ស្ដីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[56] មាត្រា៤១ កថាខណ្ឌទី១ នៃច្បាប់ស្ដីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[57] មាត្រា៤១ កថាខណ្ឌទី៣ នៃច្បាប់ស្ដីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

គួរបញ្ជាក់ផងដែរថា ក្រៅពីការសម្រេចអំពីការដោះលែងឲ្យអនីតិជននៅក្រៅឃុំដោយការផ្ដួចផ្ដើមរបស់ចៅក្រមស៊ើបសួរហើយនោះ ព្រះរាជអាជ្ញា អនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុងអនីតិជន អាចស្នើសុំទៅចៅក្រមស៊ើបសួរឲ្យដោះលែងអនីតិជនឲ្យនៅក្រៅឃុំបានគ្រប់ពេលវេលា ហើយចៅក្រមស៊ើបសួរត្រូវសម្រេចក្នុងរយៈពេល ៥(ប្រាំ) ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានពាក្យសុំ[58]។

### ៣.៣ ការបិទការស៊ើបសួរ

នៅពេលដែលចៅក្រមស៊ើបសួរយល់ឃើញថាការស៊ើបសួរត្រូវបានបញ្ចប់ចៅក្រមស៊ើបសួរនឹងជូនព័ត៌មាននេះទៅដល់ព្រះរាជអាជ្ញា និងភាគីជាប់ពាក់ព័ន្ធដូចជា ជនត្រូវចោទ ដើមបណ្ដឹងរដ្ឋប្បវេណី អ្នកតំណាងដែលច្បាប់បានកំណត់ ឬមេធាវី ជាដើម មុននឹងចៅក្រមស៊ើបសួរសម្រេចចេញដីកាដំណោះស្រាយ ដីកាដំណោះស្រាយគឺអាចជាដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះ ឬដីកាលើកលែងការចោទប្រកាន់ដែលចៅក្រមស៊ើបសួរសម្រេចក្រោយបិទការស៊ើបសួរ[59]។

បន្ថែមពីនេះទៅទៀត ចំពោះរឿងក្ដីជនត្រូវចោទជាអនីតិជនមានលក្ខណៈពិសេសត្រង់ថា មុនចេញដីកាដំណោះស្រាយ ចៅក្រមស៊ើបសួរត្រូវពិនិត្យ និងពិចារណាទៅលើរបាយការណ៍ស្ដីពីការប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជនពីភ្នាក់ងារសង្គមកិច្ចជាមុនសិន[60]។

#### ៣.៣.១ ការលើកលែងការចោទប្រកាន់

ចៅក្រមស៊ើបសួរចេញដីកាដំណោះស្រាយលើកលែងចោទប្រកាន់នៅក្នុងករណីដូចជា[61] ៖

ក. អំពើប្រព្រឹត្តនោះ ពុំមែនជាបទល្មើសឧក្រិដ្ឋ បទល្មើសមជ្ឈិម ឬបទលហុ

ខ. ជនដែលប្រព្រឹត្តអំពើនោះ នៅតែគេមិនស្គាល់

គ. គ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ទៅលើជនត្រូវចោទ។

អានុភាពនៃដីកាដំណោះស្រាយលើកលែងចោទប្រកាន់ គឺនាំឲ្យមានការដោះលែងអនីតិជនដែលបានជាប់ឃុំ បើទោះបីជាមានបណ្ដឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាក៏ដោយ[62]។

ចៅក្រមស៊ើបសួរត្រូវប្រគល់អនីតិជនទៅឲ្យអ្នកតំណាងដែលច្បាប់បានកំណត់ តែប្រសិនបើករណីដែលស្ថានភាពរបស់ អនីតិជននោះតម្រូវឲ្យមានកិច្ចការពារ និងថែទាំ ចៅក្រមស៊ើបសួរត្រូវបញ្ជូនអនីតិជននោះទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានីខេត្ត ដើម្បីចាត់វិធានការសមស្របទៅតាមសុខុមាលភាពនិងស្ថានភាពសង្គមរបស់អនីតិជន។ ម៉្យាងវិញទៀត គ្រប់ករណីដែលពាក់ព័ន្ធការព្យួរការដកហូត ឬ

[58] មាត្រា៤១ កថាខណ្ឌទី៦ នៃច្បាប់ស្ដីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[59] មាត្រា២៤៧ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧

[60] មាត្រា៤២ កថាខណ្ឌទី១ នៃច្បាប់ស្ដីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[61] មាត្រា២៤៧ កថាខណ្ឌទី៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧

[62] មាត្រា៤២ កថាខណ្ឌទី២ នៃច្បាប់ស្ដីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

ការបញ្ឈប់អ្នកតំណាងដែលច្បាប់បានកំណត់ព្រមទាំងសិទ្ធិអាណាព្យាបាលលើអនីតិជនដែលត្រូវបានធ្វើឡើងដោយការដាក់ពាក្យស្នើសុំទៅតុលាការដើម្បីឲ្យតុលាការធ្វើការសម្រេច[63]។

### ៣.៣.២ ការបញ្ជូនរឿងទៅជំនុំជម្រះ

ប្រសិនបើយល់ឃើញថាអំពើល្មើសនោះជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ចៅក្រមស៊ើបសួរនឹងសម្រេចបញ្ជូនជនត្រូវចោទទៅចំពោះមុខតុលាការជំនុំជម្រះ តាមរយៈដីកាបញ្ជូនរឿងឲ្យទៅជំនុំជម្រះរបស់ចៅក្រមស៊ើបសួរ ដែលត្រូវមានរៀបរាប់ពីអំពើដែលត្រូវចោទប្រកាន់ និងឈ្មោះបទល្មើសតាមច្បាប់[64]។

## ផ្នែកទី៤. ជំណាក់កាលចៅក្រមជំនុំជម្រះ និងការជំនុំជម្រះ

### ៤.១ សមត្ថកិច្ចរបស់ចៅក្រមជំនុំជម្រះ

សាលាដំបូងដែលមានសមត្ថកិច្ចជំនាញទាក់ទងនឹងអនីតិជន មានសមត្ថកិច្ចជំនុំជម្រះ បទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុដែលមានជនជាប់ចោទជាអនីតិជន[65]។ សមាសភាពនៃអង្គជំនុំជម្រះចំពោះបទល្មើសឧក្រិដ្ឋ បទល្មើសមជ្ឈិម និងបទលហុដែលជាប់ទាក់ទងនឹងបទឧក្រិដ្ឋ និងបទមជ្ឈិម ត្រូវសម្រេចជាក្រុមសមូហភាពដោយមានសមាសភាពចៅក្រមចំនួន ០៣(បី) រូប ដោយឡែកចំពោះបទល្មើសលហុ សាលាដំបូងសម្រេចសេចក្តីជាចៅក្រមទោល[66]។ តុលាការត្រូវលើកយករឿង ក្តីរបស់អនីតិជនមកចាត់ការជាអាទិភាព ជាពិសេសរឿងក្តីអនីតិជនដែលជាប់ឃុំខ្លួនបណ្តោះអាសន្ន។ មិនតែប៉ុណ្ណោះ ដើម្បីជាឧត្តមប្រយោជន៍សម្រាប់ការរង់ចាំការជំនុំជម្រះ តុលាការត្រូវពិចារណាដោះលែងអនីតិជនដែលជាប់ឃុំបណ្តោះអាសន្នឲ្យមានសេរីភាព។ ចំពោះរឿងក្តីដែលត្រូវបានលើកពេលជំនុំជម្រះ ដូចគ្នាដែរតុលាការត្រូវពិចារណាអំពីការដោះលែងអនីតិជនដែលជាប់ឃុំបណ្តោះអាសន្នឲ្យមានសេរីភាពឡើងវិញ[67]។

### ៤.២ នីតិវិធីមុនពេលសវនាការរឿងក្តីអនីតិជន

មុនពេលសវនាការ តុលាការចាំបាច់ត្រូវពិនិត្យរបាយការណ៍ និងយោបល់ស្តីពីការប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជនដែលផ្តល់ដោយភ្នាក់ងារសង្គមកិច្ច[68]។ ប្រសិនបើរបាយការណ៍ដែលត្រូវពិនិត្យនោះពុំទាន់បានរៀបចំ ឬបើតុលាការយល់ឃើញថាពត៌មានដែលផ្តល់ឲ្យនោះមិនទាន់គ្រប់គ្រាន់នោះទេ តុលាការត្រូវបង្គាប់ឲ្យភ្នាក់ងារសង្គមកិច្ចរៀបចំ និងបំពេញបន្ថែមនូវរបាយការណ៍ និងយោបល់នោះទៅតាមតម្រូវការជាក់ស្តែង[69]។

---

[63] មាត្រា៤២ កថាខណ្ឌទី៥ និងទី៦ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[64] មាត្រា២៤៧ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧

[65] មាត្រា៤៤ កថាខណ្ឌទី១ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[66] មាត្រា៤៤ កថាខណ្ឌទី២ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[67] មាត្រា៤៥ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[68] មាត្រា៤៦ កថាខណ្ឌទី១ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[69] មាត្រា៤៦ កថាខណ្ឌទី២ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

## ៤.៣ ដំណើរការសវនាការ

ចំពោះរឿងក្តីអនីតិជន ការពិភាក្សាដេញដោល និងការប្រកាសសាលក្រមត្រូវធ្វើឡើងនៅក្នុងបន្ទប់សវនាការជាអសាធារណៈ។ មានតែបុគ្គលដែលមានសិទ្ធិ កាតព្វកិច្ច ឬផលប្រយោជន៍ពាក់ព័ន្ធ នឹងរឿងក្តីដែលមានសិទ្ធិចូលរួមក្នុងសវនាការ[70]។ ជាក់ស្តែងដូចជា ដើមបណ្តឹងរដ្ឋប្បវេណី សាក្សី ឬ អ្នកបកប្រែ (ប្រសិនបើមាន) មេធាវីការពារសិទ្ធិជាអាទិ៍ទើបអាចចូលរួម ផ្ទុយទៅវិញសាធារណៈជនទូទៅ ដែលមិនពាក់ព័ន្ធ គឺមិនត្រូវបានអនុញ្ញាតឲ្យចូលរួមសវនាការនោះទេ យោងទៅតាមគោលការណ៍អសាធារណៈនៃសវនាការចំពោះរឿងក្តីអនីតិជន។ ដោយឡែកចំពោះអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុងរបស់អនីតិជនត្រូវចូលរួមក្នុងសវនាការជានិច្ច លើកលែងករណីបើមានសំណូមពររបស់អនីតិជនផ្ទុយពីនេះ ឬតុលាការយល់ឃើញថាការចូលរួមរបស់បុគ្គលទាំងនោះមិនបម្រើឧត្តមប្រយោជន៍របស់អនីតិជន[71]។

នៅពេលសវនាការ តុលាការត្រូវប្រើប្រាស់នីតិវិធីកុមារមេត្រី។ បន្ថែមពីនេះទៅទៀត ចំពោះករណីពិសេស មេធាវីរបស់អនីតិជន ភ្នាក់ងារសង្គមកិច្ច ឬព្រះរាជអាជ្ញា អាចស្នើសុំឲ្យតុលាការប្រើប្រាស់របាំងក្នុងពេលសវនាការ ឬប្រើប្រាស់វិធានសមស្របណាមួយក្នុងការស្តាប់ចម្លើយ[72]។

ចំពោះរឿងក្តីអនីតិជន ជំនួយរបស់មេធាវីត្រូវតែមានជាដាច់ខាតនៅក្នុងសវនាការ។ បើសិនជាពុំមានការជ្រើសរើសមេធាវីដោយអនីតិជនទេនោះ មេធាវីត្រូវបានចាត់តាំងដោយមិនយកកម្រៃ ក្រោមគំនិតផ្តួចផ្តើមរបស់ប្រធានតុលាការឲ្យស្របទៅតាមលក្ខខណ្ឌដែលមានចែងនៅក្នុងច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។ តុលាការត្រូវផ្តល់ពេលវេលាសមស្រប និងលិខិតចម្លងសំណុំរឿងឲ្យទៅមេធាវី ដើម្បីសម្រាប់មេធាវីត្រៀមរៀបចំការការពារ។

នៅពេលចាប់ផ្តើមសវនាការ តុលាការត្រូវប្រាប់អនីតិជនដោយប្រើប្រាស់ភាសាដែលអនីតិជនអាចយល់បាននូវសិទ្ធិមួយចំនួនដូចខាងក្រោម[73] ៖

- សិទ្ធិដែលទាក់ទងនឹងដំណាក់កាលនៃការជំនុំជម្រះ
- សិទ្ធិមានវត្តមាននៅពេលជំនុំជម្រះក្តី
- សិទ្ធិទទួលបានការការពារពីតុលាការនូវទង្វើមិនគប្បី ឬការសួរដេញដោលមិនសមរម្យ
- សិទ្ធិប្តឹងជិតចិត្តថៅក្រមជំនុំជម្រះ
- សិទ្ធិធ្វើសំណូមពរចុងក្រោយ
- សិទ្ធិប្តឹងឧទ្ធរណ៍ ។

---

[70] មាត្រា៤៧ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[71] មាត្រា៤៧ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[72] មាត្រា៤៨ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[73] មាត្រា៥១ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

អំឡុងពេលសវនាការ បើទោះបីជាជនជាប់ចោទដែលជាអនីតិជនបានឆ្លើយសារភាពទទួលស្គាល់យកនូវពិរុទ្ធភាពរបស់ខ្លួនក្តី ក៏តុលាការមានកាតព្វកិច្ចត្រូវពិនិត្យ ថ្លឹងថ្លែង និងបញ្ជាក់ឲ្យបានច្បាស់លាស់ដើម្បីអាចធានាបានថាចម្លើយសារភាពនោះត្រូវបានធ្វើឡើងដោយស្ម័គ្រចិត្តគ្មានការគំរាមកំហែង ឬបង្ខិតបង្ខំ និងយល់បានអំពីផលវិបាកនៃការសារភាពនេះ។ ចម្លើយសារភាពដែលបានមកពីការបង្ខិតបង្ខំ គំរាមកំហែង ឬការមិនយល់ដឹងពីផលវិបាកនៃការសារភាពមិនត្រូវចាត់ទុកជាភស្តុតាងនៃពិរុទ្ធភាពនោះឡើយ[74] ម៉្យាងវិញទៀត ការសារភាពទទួលយកផែនការបង្វែរមិនត្រូវបាន ចាត់ទុកថាជាភស្តុតាងសម្រាប់ពិរុទ្ធភាពក្នុងបទល្មើសដដែល សម្រាប់នីតិវិធីព្រហ្មទណ្ឌបន្តបន្ទាប់ នោះឡើយ[75]។

### ៤.៤ ការប្រកាសសាលក្រមរឿងក្តីរបស់អនីតិជន

ការប្រកាសសាលក្រមអាចធ្វើឡើងនៅពេលសវនាការ ក្រោយពីបានធ្វើការពិភាក្សាដេញដោលឬនៅពេលដែលសវនាការសម្រេចលើកទៅពេលក្រោយ[76]។

ជាគោលការណ៍ ចំពោះរឿងក្តីអនីតិជនសាលក្រមត្រូវប្រកាសជាអសាធារណៈនៅចំពោះមុខអនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុងរបស់អនីតិជន មេធាវី ភ្នាក់ងារសង្គមកិច្ច និងភាគីដែលមានប្រយោជន៍ជាប់ពាក់ព័ន្ធនៅក្នុងរឿងក្តី តែប៉ុណ្ណោះ[77]។ ប៉ុន្តែក្នុងករណីដែលការប្រកាសសាលក្រមចំពោះមុខធ្វើឲ្យខូចប្រយោជន៍របស់អនីតិជននោះ តុលាការអាចធ្វើការប្រកាសសាលក្រមកំបាំងមុខអនីតិជនបាន[78]។ ការប្រកាសសាលក្រម រឿងក្តីអនីតិជនអាចមានខ្លឹមសារជា ការឲ្យរួចផុតពីបទចោទ ការផ្តន្ទាទោសនិងការកំណត់ឲ្យសងសំណងរដ្ឋប្បវេណី និងការកំណត់អំពីវិធានការបង្វែរជាដើម។

#### ៤.៤.១ ការឲ្យរួចផុតពីបទចោទ

តុលាការសម្រេចឲ្យអនីតិជនរួចផុតពីបទចោទនៅក្នុងករណីពីរដូចជា ក្នុងករណីដែលរកឃើញថាអនីតិជនមានអាយុក្រោម ១៤(ដប់បួន) ឆ្នាំ នៅពេលប្រព្រឹត្តបទល្មើស ឬករណីដែលរកឃើញថាអំពើដែលចោទប្រកាន់មកលើអនីតិជនមានអាយុចាប់ពី ១៤(ដប់បួន) ឆ្នាំ ដល់ក្រោម ១៨(ដប់ប្រាំបី) ឆ្នាំ នោះពុំមែនជាបទល្មើស ឬអនីតិជនគ្មានកំហុសនោះទេ[79]។ នៅពេលដែល តុលាការសម្រេចឲ្យអនីតិជនរួចផុតពីបទចោទប្រកាន់ តុលាការត្រូវបង្គាប់ឲ្យដោះលែងអនីតិជនដែលជាប់ឃុំជាបន្ទាន់ទោះបីជាមានបណ្តឹងឧទ្ធរណ៍របស់តំណាងអយ្យការក៏ដោយ ហើយត្រូវប្រគល់អនីតិជននោះឲ្យទៅអ្នកតំណាងដែលច្បាប់បានកំណត់។

[74] មាត្រា៥៣ កថាខណ្ឌទី១ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦
[75] មាត្រា៥៣ កថាខណ្ឌទី២ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន
[76] មាត្រា៥៤ កថាខណ្ឌទី១ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន
[77] មាត្រា៥៤ កថាខណ្ឌទី២ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន
[78] មាត្រា៥៤ កថាខណ្ឌទី៣ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន
[79] មាត្រា៥៩ កថាខណ្ឌទី១ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន

### ៤.៤.២ ការផ្តន្ទាទោស និងការកំណត់ឲ្យសងសំណងរដ្ឋប្បវេណី

ប្រសិនបើតុលាការរកឃើញថាអនីតិជនដែលមានអាយុក្រោម ១៤(ដប់បួន)ឆ្នាំ ពិតជាបានប្រព្រឹត្ត បទល្មើសពិតមែន តុលាការ នឹងសម្រេចអំពីសំណងរដ្ឋប្បវេណីប្រសិនបើមានបណ្តឹងរដ្ឋប្បវេណីប៉ុណ្ណោះ[80] ក៏ប៉ុន្តែតុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជនដែលមាន អាយុចាប់ពី ១៤(ដប់បួន) ឆ្នាំ ឡើងទៅបាន បើសិនកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជននោះតម្រូវ[81]។

### ៤.៤.៣ ការប្រើប្រាស់វិធានបង្វែរ

នៅក្នុងដំណាក់កាលជំនុំជម្រះ ចំពោះរឿងក្តីដែលជនជាប់ចោទជាអនីតិជនដែលមាន អាយុចាប់ពី ១៤(ដប់បួន) ឆ្នាំ ឡើងទៅដល់ក្រោម ១៨(ដប់ប្រាំបី) ឆ្នាំ ជាប់ចោទពីបទលហុ ឬបទមជ្ឈិម រួមទាំងបទល្មើស មជ្ឈិមដែលមានស្ថានទម្ងន់ទោសផងដែរ តុលាការត្រូវពិចារណាជាបឋម ទៅលើការអនុវត្តវិធានបង្វែរ ដែលមានចែងនៅក្នុងច្បាប់ពិសេសជាមុន នោះគឺច្បាប់ស្តីពីអនីតិជន[82]។ ការអនុវត្តវិធានការបង្វែរទាមទារ ឲ្យមានលក្ខខណ្ឌអប្បបរមាមួយចំនួន ដូចមានចែងនៅក្នុងមាត្រា ៦៣ នៃច្បាប់ស្តីពីអនីតិជន ក្រោយពី លក្ខខណ្ឌត្រូវបានបំពេញតុលាការអាចចេញនូវសាលក្រមបង្អង់រឿងទុកសិន ដើម្បីទុកពេលសម្រាប់ពិគ្រោះ យោបល់ជាមួយអនីតិជន និងអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកពាក់ព័ន្ធផ្សេងទៀតពាក់ព័ន្ធជាមួយ នឹងការរៀបចំផែនការបង្វែរ[83]។

ប្រសិនបើតុលាការសម្រេចអនុវត្តវិធានបង្វែរ តុលាការអាចចេញសាលក្រមសម្រេចអំពីសំណង រដ្ឋប្បវេណី ក្នុងករណីដែលមានការប្តឹងសុំរួច ត្រូវបង្គាប់ឲ្យដោះលែងអនីតិជនដែលកំពុងជាប់ឃុំភ្លាមនិង ប្រគល់អនីតិជនទៅឲ្យអ្នកតំណាងដែលច្បាប់បានកំណត់វិញ បើទោះជាមានបណ្តឹងឧទ្ធរណ៍របស់តំណាង អយ្យការ[84]។

[80] មាត្រា៤៩ កថាខណ្ឌទី២ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន

[81] មាត្រា៣៩ កថាខណ្ឌទី២ នៃក្រមព្រហ្មទណ្ឌ លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧

[82] មាត្រា៥២ កថាខណ្ឌទី១ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[83] មាត្រា៥២ កថាខណ្ឌទី២ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[84] មាត្រា៥២ កថាខណ្ឌទី៣ និងកថាខណ្ឌទី៤ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

# ជំពូកទី៣
# ការប្រើប្រាស់វិធានការបង្វែរ

# ជំពូកទី៣
# ការប្រើប្រាស់វិធានការបង្វែរ

ការបង្វែរគឺជាវិធានមួយដែលអាចប្រើប្រាស់បានក្នុងករណីអនីតិជនបានសារភាពថាបានប្រព្រឹត្តបទល្មើសហើយដែលបានជឿជាក់ថាបានប្រព្រឹត្តបទល្មើសពិតមែនដោយចេញពីដំណាក់កាលនីមួយៗនៃនីតិវិធីរបស់តុលាការ[85]។ វិធាននេះមានគោលបំណងឲ្យមានការទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួន និងជំរុញឲ្យមានការសម្រុះសម្រួលគ្នារវាងអនីតិជន និងជនរងគ្រោះ ព្រមទាំងផ្តល់នូវអត្ថប្រយោជន៍ក្នុងការស្តារនីតិសម្បទា ការធ្វើសមាហរណកម្មអនីតិជននៅក្នុងសង្គម និងសហគមន៍។

ជាពិសេសគឺវិធាននេះ លើកស្ទួយផ្នែកសិទ្ធិរបស់កុមារ ដែលមានទំនាស់ទៅនឹងច្បាប់ និងការពារសិទ្ធិរបស់អនីតិជន និងជនរងគ្រោះ ក៏ដូចជាឧត្តមប្រយោជន៍របស់អនីតិជនដែលប្រព្រឹត្តបទល្មើស។

ការប្រើប្រាស់វិធានការបង្វែរគឺអាចប្រើប្រាស់បានគ្រប់នីតិវិធីរបស់តុលាការ តាំងពីដំណាក់កាលអយ្យការ ដំណាក់កាលចៅក្រមស៊ើបសួរ និងដំណាក់កាលជំនុំជម្រះ ដោយគោរពទៅតាមលក្ខខណ្ឌដែលច្បាប់ស្តីពីអនីតិជន ឆ្នាំ២០១៦ បានបញ្ញត្តិមក។ តើការអនុវត្តការប្រើប្រាស់វិធានការបង្វែរនេះ តើតុលាការអនុវត្តដូចម្តេច?

## ផ្នែកទី១៖ របៀបអនុវត្ត

ភ្នាក់ងារសង្គមកិច្ច និងបុគ្គលទទួលបន្ទុកក្នុងការអនុវត្តផែនការបង្វែរ ត្រូវធានាក្នុងការធានារ៉ាប់រងអនុវត្តសេចក្តីសម្រេច និងផែនការបង្វែររបស់អាជ្ញាធរទទួលបន្ទុកបង្វែរ ក្នុងការគ្រប់គ្រង និងត្រួតពិនិត្យលើអនីតិជនដែលត្រូវអនុវត្តផែនការបង្វែរនេះ[86]។ បុគ្គលដែលទទួលបន្ទុកក្នុងការអនុវត្តផែនការបង្វែរ ត្រូវធ្វើរបាយការណ៍ស្តីពីលទ្ធផលជោគជ័យ ឬបរាជ័យ ឬឧបសគ្គដែលកើតមាន នៅក្នុងការអនុវត្តផែនការខាងលើទៅភ្នាក់ងារសង្គមកិច្ច។ ភ្នាក់ងារសង្គមកិច្ចត្រូវបញ្ជូនរបាយការណ៍នោះរួមទាំងមតិយោបល់របស់ខ្លួនទៅកាន់អាជ្ញាធរទទួលបន្ទុកបង្វែរ ហើយចម្លងជូនទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានីខេត្ត។

វិធានការបង្វែរដែលទាក់ទងនឹងការងារ ត្រូវអនុលោមតាមច្បាប់ស្តីពីការងារ និងអនុសញ្ញាអន្តរជាតិស្តីពីការងារ ដែលមានការទទួលស្គាល់ពីកម្ពុជា។ ដូច្នេះប្រសិនបើការអនុវត្តវិធានបង្វែរនេះទទួលបានជោគជ័យ តំណាងអយ្យការត្រូវចេញដីកាលើកលែងចោទប្រកាន់ ហើយអនីតិជននោះរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ ពោលគឺមិនត្រូវបានទទួលរងនូវទណ្ឌកម្មព្រហ្មទណ្ឌណាមួយឡើយ ហើយចំពោះលទ្ធផលជោគជ័យក្នុងការអនុវត្តវិធានការបង្វែរ ត្រូវមានរបាយការណ៍បញ្ជាក់រួមគ្នាពីភ្នាក់ងារសង្គមកិច្ច និងបុគ្គលទទួលបន្ទុកក្នុងការបង្វែរផងដែរ។

---

[85] មាត្រា៦០ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[86] មាត្រា៦៩ កថាខណ្ឌទី១ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

## ផ្នែកទី២៖ ការមិនគោរពកាតព្វកិច្ច និងបរាជ័យក្នុងការអនុវត្ត

បរាជ័យក្នុងការអនុវត្តវិធានការបង្វែរនេះ គឺសំដៅទៅលើករណីដែលអនីតិជនមិនបានគោរពតាមកាតព្វកិច្ចដែលតម្រូវនៅក្នុងវិធានការបង្វែរ ឬនៅក្នុងវិធានការបង្វែរដែលបានកែប្រែ[87]។

### ២.១ ការមិនគោរពតាមកាតព្វកិច្ចនៅក្នុងវិធានការបង្វែរ

ក្នុងករណីដែលត្រូវបង្វែរ អាជ្ញាធរទទួលបន្ទុកបង្វែរអាចសម្រេចជ្រើសយកវិធានការមួយ ឬក៏ច្រើនដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ស្តីពីកាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការ ឬវិធានការបង្វែរដែលមានបញ្ញត្តិនៅក្នុងច្បាប់ស្តីពីអនីតិជន[88]។ អនីតិជនត្រូវអនុវត្តតាមវិធានការបង្វែរដែលតុលាការបានសម្រេចដាក់ជាកាតព្វកិច្ចតម្រូវឲ្យអនុវត្ត ផ្ទុយទៅវិញប្រសិនបើអនីតិជននោះមិនបានគោរពកាតព្វកិច្ចដែលត្រូវអនុវត្តតាមទេនោះ នឹងត្រូវចាត់ទុកថាជាបរាជ័យនៃការអនុវត្តវិធានការបង្វែរ។

ភ្នាក់ងារសង្គមកិច្ចត្រូវផ្តល់របាយការណ៍ស្តីអំពីលទ្ធផលនៃការមិនគោរពកាតព្វកិច្ចដែលបានកំណត់នៅក្នុងវិធានការបង្វែរ ឬនៅក្នុងវិធានការបង្វែរដែលបានកែប្រែរួមទាំងយោបល់ជូនទៅអាជ្ញាធរទទួលបន្ទុកដើម្បីសម្រេចដោយចម្លងជូនទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត។ ក្រោយបានពិនិត្យរបាយការណ៍ខាងលើ អាជ្ញាធរទទួលបន្ទុកបង្វែរត្រូវកោះហៅអនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុង ភ្នាក់ងារសមត្ថកិច្ច បុគ្គលទទួលបន្ទុកផែនការបង្វែរ និងមេធាវីរបស់អនីតិជនបើមានឲ្យចូលមកបង្ហាញខ្លួន ក្នុងថិរវេលាមិនលើសពី ១៥ (ដប់ប្រាំ) ថ្ងៃ ដើម្បីសាកសួរពីមូលហេតុដែលអនីតិជននោះមិនគោរពតាមវិធានការបង្វែរ[89]។

### ២.២ អានុភាពនៃបរាជ័យនៅក្នុងវិធានការបង្វែរ

ក្រោយពីធ្វើការសាកសួរមូលហេតុដែលអនីតិជនពុំបានគោរពតាមវិធានការបង្វែរ ព្រមទាំងបានពិចារណាអំពីទស្សនៈរបស់អនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុង និងបន្ទាប់ពីបានពិគ្រោះយោបល់ជាមួយនឹងភ្នាក់ងារសង្គមកិច្ច អាជ្ញាធរទទួលបន្ទុកបង្វែរអាចចេញ ដីកាបង្វែរថ្មី ឬបន្តចាត់ការតាមនីតិវិធីព្រហ្មទណ្ឌជាធរមាន[90]។

ប៉ុន្តែប្រសិនបើអនីតិជនមិនបានមកបង្ហាញខ្លួនតាមការកោះហៅដោយគ្មាននូវមូលហេតុច្បាស់លាស់ទេនោះ អាជ្ញាធរទទួលបន្ទុកបង្វែរត្រូវបន្តចាត់ការតាមនីតិវិធីព្រហ្មទណ្ឌដែលមានជាធរមានតែម្តងដោយពុំចាំបាច់ពិចារណាលើ វិធានការចេញដីកាបង្វែរថ្មីនោះទេ។

---

[87] មាត្រា៧១ កថាខណ្ឌទី១ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន

[88] មាត្រា៦៥ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន

[89] មាត្រា៧១ កថាខណ្ឌទី៣ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន

[90] មាត្រា៧១ កថាខណ្ឌទី៥ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន

# សេចក្ដីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវនូវប្រធានបទខាងលើរួចហើយមក យើងខ្ញុំឃើញថានៅពេលអនីតិជនប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌដែលបានកំណត់ដោយច្បាប់នោះ អនីតិជនដែលប្រព្រឹត្តគឺមិនអាចរួចផុតពីការអនុវត្តទោសព្រហ្មទណ្ឌទាំងស្រុងបាននោះដែរ គ្រាន់តែមានលក្ខខណ្ឌពិសេសមួយចំនួនដែលត្រូវបានបញ្ញត្តិដោយច្បាប់ដោយឡែកគឺ «**ច្បាប់ស្តីពីអនីតិជន**» ដើម្បីយកមក ធ្វើការអនុវត្តទៅលើជនល្មើស ក៏ដូចជាជនត្រូវចោទដែលជាអនីតិជន។ ដោយសារអនីតិជនគឺជាជន ដែលស្ថិតក្នុងដំណាក់កាលកំពុងវិវឌ្ឍន៍ផ្នែកចិត្តគំនិតប្រាជ្ញាស្មារតី និងការគិតពិចារណា ដែលទាំងអស់នេះហើយគឺជាមូលហេតុដែលនាំឲ្យតុលាការត្រូវធ្វើការពិចារណាជាមូលដ្ឋានមុននឹងឈានដល់ការកំណត់អំពីលទ្ធភាព នៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជននោះថាតើអនីតិជនដែលប្រព្រឹត្តបទល្មើសនោះនឹងត្រូវធ្វើការទទួលខុសត្រូវព្រហ្មទណ្ឌ ឬគួរតែរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ។ កត្តាអាយុ កាលៈទេសៈនៃបទល្មើស និងបុគ្គលិកលក្ខណៈរបស់អនីតិជនគឺជាចំណុចដែលតុលាការ ក៏ដូចជាតំណាងអយ្យការត្រូវធ្វើការពិចារណាឲ្យបានល្អិតល្អន់ ពីព្រោះថាលទ្ធផលនៃការសម្រេចនេះអាចនឹងនាំឲ្យមានផលប៉ះពាល់ដល់អនាគតរបស់អនីតិជននោះ។ ម្យ៉ាងវិញទៀត ចំពោះការអនុវត្តទោសព្រហ្មទណ្ឌលើអនីតិជន ច្បាប់ស្តីពីអនីតិជនបានបញ្ញត្តិនូវវិធានការពិសេសមួយ គឺវិធានការបង្វែរដែលវិធានការនេះមានគោលបំណងលើកទឹកចិត្ត ជៀសវាងនូវស្នាមអាក្រក់ក្នុងអារម្មណ៍របស់អនីតិជន និងបង្កឲ្យទៅជាមានការរើសអើង ក៏ដូចជាប្រវត្តិជាប់ពន្ធនាគារក្នុងបញ្ជីថ្កោលទោសជាអាទិ៍។

សរុបជារួមមក នីតិវិធីនៃការអនុវត្តរឿងក្តីព្រហ្មទណ្ឌដែលមានជនត្រូវចោទជាអនីតិជនគឺមានលក្ខណៈពិសេសខុសពីនីតិជន ដែលលំហូរនៃនីតិវិធីនេះទៀតសោតត្រូវបានបញ្ញត្តិក្នុងច្បាប់ស្តីពីអនីតិជន ក្នុងគោលបំណងដើម្បីផ្តល់ឲ្យអនីតិជននូវឧត្តមប្រយោជន៍នានា ក៏ដូចជាសិទ្ធិជាមូលដ្ឋានទាំងឡាយដែលអនីតិជនត្រូវតែទទួលបាននៅក្នុងអំឡុងពេលនៃដំណើរការនីតិវិធីចំពោះរឿងក្តីព្រហ្មទណ្ឌ។ ការបញ្ញត្តិនូវនីតិវិធីពិសេសបែបនេះគឺបានផ្តល់នូវផលវិជ្ជមានជាច្រើនសម្រាប់ជនត្រូវចោទដែលជាអនីតិជន ជាពិសេសគឺផ្តល់ឱកាសសម្រាប់ការស្តារមកវិញនូវនីតិសម្បទា និងការសម្របខ្លួនត្រឡប់ទៅក្នុងសង្គមវិញ។

# អនុសាសន៍

# អនុសាសន៍

ក្រោយពីបានសិក្សាទៅលើទ្រឹស្តីគតិយុត្តនៃនីតិវិធីពិសេសដែលត្រូវអនុវត្តទៅលើអនីតិជន ហើយនោះយើងក៏ឃើញថាច្បាប់បានបញ្ញត្តិពីការពារនូវឧត្តមប្រយោជន៍របស់អនីតិជនបានយ៉ាងល្អ ក៏ប៉ុន្តែចំពោះការអនុវត្តជាក់ស្តែងវិញគឺនៅមានភាពខ្វះចន្លោះ និងភាពខ្វះខាតនៅឡើយ ដោយសារកង្វះខាតធនធានមនុស្ស កត្តាសម្ភារៈ រួមផ្សំនឹងយន្តការនៃការអនុវត្តរឿងក្តីព្រហ្មទណ្ឌដែលមាន ជនត្រូវចោទជាអនីតិជននៅមានកម្រិតនៅឡើយផងដែរ។ បញ្ហាទាំងអស់នេះគឺជា បញ្ហាចោទយ៉ាងសំខាន់ហើយក៏ជាកត្តាលីករមួយដែលនាំឲ្យមានការរាំងស្ទះការអនុវត្តបញ្ញត្តិច្បាប់ដែលពាក់ព័ន្ធនឹងអនីតិជនឲ្យបានកាន់តែមានប្រសិទ្ធិភាពផងដែរ។

ហេតុនេះហើយ ដើម្បីដោះស្រាយបញ្ហាទាំងអស់នេះបានគឺទាមទារឲ្យមានដំណោះស្រាយប្រកបទៅដោយការយកចិត្តទុកដាក់មួយចំនួនដូចជា ៖

- បង្កើតតុលាការជំនាញរឿងក្តីព្រហ្មទណ្ឌអនីតិជន ដែលមានមន្ត្រីជំនាញមានសមត្ថកិច្ចធ្វើការដោះស្រាយរឿងក្តីអនីតិជន។
- ផ្សព្វផ្សាយច្បាប់ដែលពាក់ព័ន្ធឲ្យបានទូលំទូលាយ ដើម្បីធានាបាននូវការយល់ដឹងទៅដល់មន្ត្រីអាជ្ញាធរដែលជាប់ពាក់ព័ន្ធ និងប្រជាពលរដ្ឋនៅគ្រប់មជ្ឈដ្ឋាន។
- ពង្រឹងនូវការអនុវត្តនីតិវិធី ក៏ដូចជាធានាឲ្យបានថានៅគ្រប់ដំណាក់កាលដែលប្រព្រឹត្តទៅគឺមានភាពស្របតាមលក្ខណៈនីតិវិធីកុមារមេត្រី ដែលនេះជាគឺជាមូលដ្ឋានមួយនៃការផ្តល់នូវឧត្តម ប្រយោជន៍ដល់អនីតិជន។
- ជម្រុញ និងលើកទឹកចិត្តទៅដល់ស្ថាប័ន អាជ្ញាធរមានសមត្ថកិច្ចដែលពាក់ព័ន្ធទាំងឡាយឲ្យមានការពិចារណាជាបឋមទៅលើការប្រើប្រាស់នូវវិធានការបង្វែរមុននឹងឈានដល់ការសម្រេចដាក់នូវទណ្ឌកម្មព្រហ្មទណ្ឌ។

# ឯកសារយោង

## ឯកសារយោង

### ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

១. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានប្រកាសឲ្យប្រើនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣។

២. សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨។

៣. ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/ រ១១០៩ / ០២២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

៤. ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/ រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

៥. ច្បាប់ស្តីពីលក្ខន្តិកៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/ រកម/០៨៩៥/០៦ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៥។

៦. ច្បាប់ស្តីពីយុត្តិធម៌អនីតិជននៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧១៦/០០៩ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៦។

### សៀវភៅ និងអត្ថបទផ្សេងៗ

១. ឯកឧត្តម ហ៊ី សោភា សៀវភៅ នីតិព្រហ្មទណ្ឌទូទៅ

២. លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត, នីតិវិធីព្រហ្មទណ្ឌទូទៅ ឆ្នាំ ២០១១

៣. លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត, នីតិវិធីព្រហ្មទណ្ឌ និងនីតិគ្រួសារ ឆ្នាំ២០១៧

៤. លោក ជ្រ សុភារ៉ា ឯកសារជំនួយស្មារតីនីតិព្រហ្មទណ្ឌទូទៅ ឆ្នាំ២០២០។

### វចនានុក្រម និងសន្ទានុក្រម

១. វចនានុក្រមសម្តេចសង្ឃ ជួន ណាត ចេញផ្សាយដោយវិទ្យាស្ថានពុទ្ធសាសនាបណ្ឌិត ឆ្នាំ១៩៦៧ ។

២. សន្ទានុក្រមពាក្យច្បាប់ ខ្មែរ-អង់គ្លេស-បារាំង ផ្នែកព្រហ្មទណ្ឌ ចេញផ្សាយដោយទីស្តីគណៈរដ្ឋមន្ត្រី ឆ្នាំ ២០១១ ។

### ប្រភពផ្សេងៗ

សាលាត្រាជូ. វាក្យស័ព្ទច្បាប់. ដកស្រង់ចេញពី https://salatraju.com/lexique/1551។

# ឧបសម្ព័ន្ធ

# បញ្ជីរាយនាមឧបសម្ព័ន្ធ

| | |
|---|---|
| ឧបសម្ព័ន្ធទី១ | កំណត់ហេតុសួរចម្លើយ |
| ឧបសម្ព័ន្ធទី២ | ទម្រង់នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ |
| ឧបសម្ព័ន្ធទី៣ | ដីកាសន្និដ្ឋានស្ថាពរ |
| ឧបសម្ព័ន្ធទី៤ | ដីកាលើកលែងចោទប្រកាន់ |
| ឧបសម្ព័ន្ធទី៥ | ដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះ |
| ឧបសម្ព័ន្ធទី៦ | សាលក្រមរបស់សាលាដំបូងរាជធានីភ្នំពេញ ។ |

# ឧបសម្ព័ន្ធទី១

## កំណត់ហេតុសួរចម្លើយ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**********

អយ្យការអម
សាលាដំបូងរាជធានីភ្នំពេញ

## កំណត់ហេតុសួរចម្លើយ

សំណុំរឿងព្រហ្មទណ្ឌលេខ: ៨០៣៩
ចុះថ្ងៃទី ១៣ ខែតុលា ឆ្នាំ ២០១៥

ឆ្នាំពីរពាន់ដប់ប្រាំ ខែតុលា ថ្ងៃទីដប់បួន វេលាម៉ោងប្រាំបួន និងសាមសិបនាទីព្រឹក។

**យើង** **ព្រះរាជអាជ្ញារង អមសាលាដំបូងរាជធានីភ្នំពេញ** ដោយមាន លោកស្រី ជាក្រឡាបញ្ជីអមផង បានសួរកត់យកចម្លើយរបស់ឈ្មោះ ភេទប្រុស <u>អាយុ ១៥ឆ្នាំ</u> ជនជាតិខ្មែរ មុខរបរដឹកអេតចាយ មានទីលំនៅកំណើត ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង និងទីលំនៅបច្ចុប្បន្ននៅ ភូមិស្វាយតាអុក សង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ នៅលីវ ឪពុកឈ្មោះ (រស់) ម្តាយឈ្មោះ (ស្លាប់) ជា<u>អនីតិជន</u> ទោសពីមុនគ្មាន។ ដោយមានបងស្រីបង្កើត ឈ្មោះ ចូលរួមស្តាប់ចម្លើយ ។

សួរ.ចម្លើយ៖ ខ្ញុំបាទសុំជម្រាបជូនថា ខ្ញុំបាទអាចឆ្លើយដោយខ្លួនឯងបាន ដោយពុំចាំបាច់មានវត្តមានមេធាវីទេ។

សួរ.ចម្លើយ៖ ចំពោះចម្លើយដែលឆ្លើយនៅចំពោះមុខសមត្ថកិច្ចពិតជាចម្លើយរបស់ខ្ញុំបាទមែន ដូច្នេះសុំរក្សាទុកនូវខ្លឹមសារទាំងស្រុងដដែល។

សួរ.ចម្លើយ៖ បានជាសមត្ថកិច្ចឃាត់ខ្លួនខ្ញុំដោយសារ នៅវេលាម៉ោងប្រហែល ០៥ល្ងាច ថ្ងៃទី ០៨.១០.២០១៥ ខ្ញុំបានពិតជាបានអោយម៉ូតូមួយគ្រឿងម៉ាក C100 កូរ៉េ ផ្លើស ពណ៌ក្រហម ទៅឈ្មោះ ខ្ញីយកជិះទៅធ្វើសកម្មភាពគាស់ទ្វាផ្ទះគេចូលលួចទូដែកប្រាកដមែន។ ប៉ុន្តែខ្ញុំបាទពុំបានចូលរួមទៅធ្វើសកម្មភាពលួចជាមួយពួកគាត់ទេ។ លុះព្រឹកឡើងថ្ងៃទី ០៩.១០.២០១៥ វេលាម៉ោងប្រហែល ០៧ព្រឹក ឈ្មោះ បានទូរសព្ទ័ហៅខ្ញុំទៅផ្ទះគាត់នៅខាងក្រោយវត្តច្បារអំពៅ មកយកម៉ូតូវិញ និងបានអោយប្រាក់មកខ្ញុំចំនួន ០១លានរៀល រួចខ្ញុំក៏វិលមកផ្ទះវិញ។,

សួរ.ចម្លើយ៖ រហូតដល់ស្អែកឡើងថ្ងៃទី ១០.១០.២០១៥ វេលាម៉ោងប្រហែល ១១ថ្ងៃត្រង់ ខណៈពេលខ្ញុំបាទកំពុងមើលឈ្មោះ និងឈ្មោះ លែងហ្គេម ស្រាប់តែសមត្ថកិច្ចមកដល់ឃាត់ខ្លួនខ្ញុំបាទ និងឈ្មោះ តែម្តង ចំនែកឈ្មោះ បានរត់គេចខ្លួនបាត់។

សួរ.ចម្លើយ៖ ខ្ញុំបាទប្រើប្រាស់ថ្នាំញៀនប្រភេទម៉ាទឹកកក។

សួរ.ចម្លើយ៖ ដូច្នេះខ្ញុំបាទសុំសំណូមពរដល់តុលាការមេត្តាជួយរកយុត្តធម៌ដល់រូមខ្ញុំបាទផង ព្រោះខ្ញុំបាទពុំបានចូលរួមធ្វើសកម្មភាពលួចជាមួយគេទេ។

ចំណាំខ្ញុំអស់តែប៉ុណ្ណេះ។

ឈប់សួរ បានអានអោយស្តាប់ សាមីខ្លួនបានឆ្លើយថាត្រឹមត្រូវហើយ ហើយសុខចិត្តចុះហត្ថលេខា ឬ ផ្តិតម្រាមដៃជាមួយយើង។

| អ្នកឆ្លើយ | ក្រឡាបញ្ជី | ព្រះរាជអាជ្ញារង |
|---|---|---|

# ឧបសម្ព័ន្ធទី២

## ទម្រង់នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម
សាលាដំបូងរាជធានីភ្នំពេញ
សំណុំរឿងព្រហ្មទណ្ឌលេខ ៤០៣៩
ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៥
លេខ ៦៥៩៦ អ.យ.ទ

# ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ

យើង ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

- បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ៤០៣៩ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៥ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

- បានឃើញ របាយការណ៍សំយោគលេខ ២០៩/១៥ រ.ប.ក ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៥ របស់[១] អធិការដ្ឋាននគរបាលខណ្ឌចំការមន នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ។

ក្រោយពីបានពិនិត្យឯកសារខាងលើ

យល់ឃើញថា មានតម្រុយសន្និដ្ឋានថា៖

១- នាមត្រកូល-នាមខ្លួន ភេទប្រុស អាយុ១៤ឆ្នាំ (ឃាត់ខ្លួន) ជនជាតិខ្មែរ កើតនៅសង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន ក្រុងភ្នំពេញ សាសនាព្រះពុទ្ធ ទីលំនៅសព្វថ្ងៃភូមិស្វាយតាអុក សង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ មុខរបរ រើសអេតចាយ នៅលីវ ឪពុកឈ្មោះ "ស" ម្តាយឈ្មោះ "រ" ទោសពីមុន "គ្មាន" ជា-នីតិជន។

២- ឈ្មោះ ហៅ ភេទប្រុស ប្រពន្ធឈ្មោះ (គេចខ្លួន)

៣- ឈ្មោះ ភេទប្រុស (គេចខ្លួន)

៤- ឈ្មោះ ភេទប្រុស (គេចខ្លួន)

៥- ឈ្មោះ ភេទប្រុស (គេចខ្លួន)

៦- នាមត្រកូល-នាមខ្លួន ហៅ ភេទប្រុស អាយុ១៥ឆ្នាំ (ឃាត់ខ្លួន) ជនជាតិខ្មែរ កើតនៅស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង សាសនាព្រះពុទ្ធ ទីលំនៅសព្វថ្ងៃភូមិតាអុក សង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ មុខរបររើសអេតចាយ នៅលីវ ឪពុកឈ្មោះ "រ" ម្តាយឈ្មោះ "ស" ទោសពីមុន "គ្មាន" ជា-នីតិជន។

៧- ឈ្មោះ ភេទស្រី ប្តីឈ្មោះ ហៅ (គេចខ្លួន)

**បានប្រព្រឹត្តអំពើដូចតទៅ[២] ÷**

កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ វេលាម៉ោងប្រហែល ៣និង១៥នាទី ទាបភ្លឺ ជនសង្ស័យឈ្មោះ ភេទប្រុស អាយុ១៤ឆ្នាំ, ឈ្មោះ . . . . . ហៅ ឈ្មោះ ឈ្មោះ និងឈ្មោះ បានជិះម៉ូតូម៉ាក CITY 100 Plus ពណ៌ក្រហម គ្មានស្លាកលេខ លេខម៉ាស៊ីន ០១៧៤៤៦ ដោយមានសណ្តោងរ៉ឺម៉ក

---

[១] លេខសំណុំរឿងរបស់អង្គភាពនគរបាលយុត្តិធម៌

[២] សេចក្តីសង្ខេបអង្គហេតុ

ដែលជាកម្មសិទ្ធិរបស់ឈ្មោះ ភេទប្រុស <u>អាយុ១៥ឆ្នាំ</u> មកឈប់នៅខាងមុខក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BE₀ ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ ហើយជនសង្ស័យឈ្មោះ បានធ្វើសកម្មភាពយកទួឡីវីសឆ្កឹះសោទ្វារខាងមុខ ចំណែកជនសង្ស័យឈ្មោះ បានឆ្កឹះសោទ្វារខាងក្នុង រួចនាំគ្នាចូលក្នុងក្រុមហ៊ុនលួចយកទូរដែកចំនួនមួយ ដែលក្នុងនោះមានប្រាក់ដុល្លារចំនួន៥ម៉ឺនដុល្លារអាមេរិក ប្រាក់រៀលចំនួន២លានរៀល និងឯកសារប្លង់ដី ព្រមទាំងសៀវភៅធនាគារ និងលួចយកម៉ាស៊ីនស្កេនចំនួនមួយ។ បន្ទាប់មកជនសង្ស័យបានគេចខ្លួនទៅផ្ទះរបស់ជនសង្ស័យឈ្មោះ ហើយយកប្រាក់ទាំងនោះចែកជាចំណែក ដោយឈ្មោះ បានទទួលប្រាក់ចំនួន ១លានរៀល។ ក្រោយមកជនសង្ស័យឈ្មោះ បានយកប្រាក់ចំនួន ៤ពាន់ដុល្លារអាមេរិក ផ្ញើទុកនៅនឹងឈ្មោះ ត្រូវជាប្រពន្ធរបស់ជនសង្ស័យឈ្មោះ ។ ចំណែកជនសង្ស័យឈ្មោះ បានឲ្យប្រាក់ទៅប្រពន្ធចំនួន ១ម៉ឺនដុល្លារអាមេរិក។ រហូតដល់ថ្ងៃទី១១ ខែតុលា ឆ្នាំ ២០១៥ សមត្ថកិច្ចបានធ្វើការស្រាវជ្រាវ ហើយឃាត់ខ្លួនជនសង្ស័យពីរនាក់មានឈ្មោះ និងឈ្មោះ ព្រមទាំងដកហូតវត្ថុតាងដូចមានក្នុងកំណត់ហេតុ ដើម្បីកសាងសំណុំរឿងចាត់ការតាមនីតិវិធីច្បាប់។

អំពើរបស់ឈ្មោះ ឈ្មោះ ហៅចយ ឈ្មោះ ឈ្មោះ និងឈ្មោះ ជាបទល្មើសលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BE₀ ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា ៣៥៣-៣៥៧ នៃក្រមព្រហ្មទណ្ឌ។

អំពើរបស់ឈ្មោះ ជាបទល្មើស សមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BE₀ ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា ២៩-៣៥៣-៣៥៧ នៃក្រមព្រហ្មទណ្ឌ។

អំពើរបស់ឈ្មោះ ជាបទល្មើស ទទួលផលចោរកម្ម ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BE₀ ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា ៣៩៩-៤០០ នៃក្រមព្រហ្មទណ្ឌ។

បានឃើញ មាត្រា ៤៤ និងមាត្រា ១២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

<u>**ហេតុដូច្នេះសម្រេច**</u>

- បើកការស៊ើបសួរលើរង្គហេតុខាងលើ និង

☑ ដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យលើឈ្មោះ[៣]

១- ភេទប្រុស <u>អាយុ១៤ឆ្នាំ</u> (ឃាត់ខ្លួន)

២- ហៅ ភេទប្រុស (គេចខ្លួន)

៣- ភេទប្រុស (គេចខ្លួន)

៤- ភេទប្រុស (គេចខ្លួន)

៥- ភេទប្រុស (គេចខ្លួន)

---

[៣] ឈ្មោះជនត្រូវចោទ

ពីបទ៖ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៨១BE₀ ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា ៣៥៣-៣៥៧ នៃក្រមព្រហ្មទណ្ឌ។

៦- ហៅ ភេទប្រុស <u>អាយុ១៥ឆ្នាំ</u> (ឃាត់ខ្លួន)

ពីបទ សមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៨១BE₀ ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា ២៩-៣៥៣-៣៥៧ នៃក្រមព្រហ្មទណ្ឌ។

៧- ភេទស្រី

ពីបទ ទទួលផលចោរកម្ម ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៨១BE₀ ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា ៣៩៩-៤០០ នៃក្រមព្រហ្មទណ្ឌ។

☐ ដាក់អោយស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ[៨]៖ ..............................................។

☑ ដាក់អោយស្ថិតនៅក្រោមការឃុំខ្លួនបណ្តោះអាសន្ន[៩]៖

១- ភេទប្រុស <u>អាយុ១៤ឆ្នាំ</u> (ឃាត់ខ្លួន)

២- : ហៅ ភេទប្រុស (គេចខ្លួន)

៣- . ភេទប្រុស (គេចខ្លួន)

៤- . ភេទប្រុស (គេចខ្លួន)

៥- ភេទប្រុស (គេចខ្លួន)

ពីបទ៖ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា

៦- ហៅ ភេទប្រុស <u>អាយុ១៥ឆ្នាំ</u> (ឃាត់ខ្លួន)

ពីបទ៖ សមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា

៧- . ភេទស្រី ពីបទ ទទួលផលចោរកម្ម

- ដោយហេតុថា ការឃុំខ្លួនបណ្តោះអាសន្នជាមូលហេតុតែមួយគត់ដើម្បី ៖
  - បញ្ឈប់បទល្មើស ឬ បង្ការបទល្មើសកុំឲ្យកើតជាថ្មី
  - រក្សាភស្តុតាង ឬតម្រុយជាសម្ភារៈ
  - ធានារក្សាជនត្រូវចោទ ទុកជូនតុលាការចាត់ការតាមនីតិវិធី
  - រារាំងការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងបក្ខពួក។

រាជធានីភ្នំពេញ ថ្ងៃទី <u>១៤</u> ខែតុលា ឆ្នាំ២០១៥

ជ.ព្រះរាជអាជ្ញា



ព្រះរាជអាជ្ញារង

---

[៨] កាតព្វកិច្ចណាមួយដែលបានចែងនៅក្នុងមាត្រា២២៣

[៩] មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្នដែលបានចែងនៅក្នុងមាត្រា២០៥

# ឧបសម្ព័ន្ធទី៣

## ដីកាសន្និដ្ឋានស្លាក

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម
សាលាដំបូងរាជធានីភ្នំពេញ
សំណុំរឿងព្រហ្មទណ្ឌលេខ ៤០៣៩
ចុះថ្ងៃទី ១៣ ខែតុលា ឆ្នាំ ២០១៥
លេខ : ៦៣ អ.យ.ទ

# ដីកាសន្និដ្ឋានស្ថាពរ

យើង ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

- បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ៤០៣៩ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៥ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

- បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ២៥៩៤ អ.យ.ទ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៥ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

- បានឃើញ សំណុំរឿងស៊ើបសួរលេខ២៦០៥ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៥ របស់សាលាដំបូងរាជធានីភ្នំពេញ ។

- បានឃើញ ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យលេខ២១១៦៩ ត.ព្រ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៥ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ ។

## ក្រោយពីបានពិនិត្យឯកសារខាងលើ

ឃើញថា

១. គោត្តនាម-នាម ភេទប្រុស <u>អាយុ១៤ឆ្នាំ</u> ជនជាតិខ្មែរ(ឃាត់ខ្លួន) កើតនៅសង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ សាសនាព្រះពុទ្ធ ទីលំនៅសព្វថ្ងៃ ភូមិស្វាយតាអុក សង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ មុខរបរលើសអេតចាយ នៅ លីវ ឪពុកឈ្មោះ "ស្លាប់"ម្ដាយឈ្មោះ "រស់"ទោសពីមុន "គ្មាន"ជា<u>អនីតិជន</u>។

២.គោត្តនាម-នាម ហៅ ភេទប្រុស អាយុ២៧ឆ្នាំ ជនជាតិខ្មែរ (ឃាត់ខ្លួន) កើតនៅភូមិស្លែង សង្កាត់ច្បារអំពៅ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ មានទីលំនៅបច្ចុប្បន្ន ភូមិស្លែង សង្កាត់ច្បារអំពៅទី២ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ប្រពន្ធឈ្មោះ (រ) កូនគ្មាន ឪពុកឈ្មោះ (ស) ម្ដាយឈ្មោះ (រ) ជានីតិជន ទោសពីមុនគ្មាន។

៣.ឈ្មោះ ភេទប្រុស(គេចខ្លួន)

៤.ឈ្មោះ ភេទប្រុស(គេចខ្លួន)

៥.ឈ្មោះ ភេទប្រុស(គេចខ្លួន)

ត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យពីបទ ៖លួចមានស្ថានទម្ងន់ទោសដោយសារប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តិនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ មានទីតាំងផ្ទះលេខ ៤១BE0 ផ្លូវលេខ ៣៨៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា៣៥៣ និង មាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

៦. គោត្តនាម-នាម ហៅ ភេទប្រុស អាយុ១៥ឆ្នាំ ជនជាតិខ្មែរ(ឃាត់ខ្លួន) កើតនៅស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង សាសនាព្រះពុទ្ធ ទីលំនៅសព្វថ្ងៃ ភូមិស្វាយតាអុក សង្កាត់ភ្លាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ មុខរបររើសអេតចាយ នៅ លីវ ឪពុកឈ្មោះ រស់-ម្តាយឈ្មោះ ស្លាប់-ទោសពីមុន-គ្មាន-ជាអនីតិជន។

ត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យពីបទ ៖សមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តិនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ មានទីតាំងផ្ទះលេខ ៤១BE0 ផ្លូវលេខ៣៨៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា២៩, ៣៥៣ និង មាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

៧. ឈ្មោះ ភេទស្រី អាយុ២២ឆ្នាំ មានទីលំនៅបច្ចុប្បន្ន ភូមិស្លែង សង្កាត់ច្បារអំពៅទី២ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ប្តីឈ្មោះ ហៅ (រ) កូនគ្មាន ជានីតិជន ទោសពីមុនគ្មាន។

ត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យពីបទ ៖ទទួលផលចោរកម្ម ប្រព្រឹត្តិនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ មានទីតាំងផ្ទះលេខ ៤១BE0 ផ្លូវលេខ៣៨៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា៣៩៩ និងមាត្រា៤០០ នៃក្រមព្រហ្មទណ្ឌ ។

ឃើញថា

កាលពីថ្ងៃទី ០៩ ខែតុលា ឆ្នាំ២០១៥ វេលាម៉ោងប្រហែល ៣ម១៥នាទី ទាបភ្លឺជនត្រូវចោទឈ្មោះ ភេទប្រុស អាយុ១៤ឆ្នាំ, ឈ្មោះ ហៅ , ឈ្មោះ ឈ្មោះ និង ឈ្មោះ បានជិះម៉ូតូម៉ាក CITY 100PLUS ពណ៌ក្រហម គ្មានស្លាកលេខ លេខម៉ាស៊ីន ០១៧៤៤៦ ដោយមានសណ្តោងរ៉ឺម៉ក ដែលជាកម្មសិទ្ធិរបស់ឈ្មោះ ភេទប្រុស អាយុ១៥ឆ្នាំ មកឈប់នៅខាងមុខក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BE0 ផ្លូវលេខ៣៨៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ មានជនត្រូវចោទឈ្មោះ បានធ្វើសកម្មភាពយកទូឡឺវីសឆ្កឹះសោរទ្វារខាងមុខ ចំណែកជនត្រូវចោទឈ្មោះ បានឆ្កឹះសោរទ្វាខាងក្នុង រួចនាំគ្នាចូលក្នុងក្រុមហ៊ុនលួចយកទូរដែកចំនួនមួយ ដែលក្នុងនោះមានប្រាក់ចំនួនប្រាំម៉ឺនដុល្លារអាមេរិក ប្រាក់រៀលចំនួន២លានរៀល និងឯកសារប្លង់ដី ព្រមទាំងសៀវភៅធនាគារ និងលួចយកម៉ាស៊ីនស្កេនចំនួនមួយ។ បន្ទាប់មកជនត្រូវចោទបានគេចខ្លួនទៅផ្ទះរបស់ជនត្រូវចោទឈ្មោះ ហើយយកប្រាក់ទាំងនោះចែកជាចំណែក ដោយឈ្មោះ បានទទួលប្រាក់ចំនួន១លានរៀល។ ក្រោយមកជនត្រូវចោទឈ្មោះ បានយកប្រាក់ចំនួន៤ពាន់ដុល្លារអាមេរិក ផ្ញើទុកនៅនឹងឈ្មោះ ត្រូវជាប្រពន្ធរបស់ជនត្រូវចោទឈ្មោះ ។ ចំណែកជនត្រូវចោទឈ្មោះ បានឲ្យប្រាក់ទៅប្រពន្ធចំនួន១ម៉ឺនដុល្លារអាមេរិក។ រហូតដល់ថ្ងៃទី ១១ ខែតុលា ឆ្នាំ២០១៥ សមត្ថកិច្ចបានធ្វើការ

ស្រាវជ្រាវ ហើយឃាត់ខ្លួនជនត្រូវចោទពីរនាក់មានឈ្មោះ និង ឈ្មោះ ព្រមទាំងដកហូតវត្ថុតាងដើម្បីកសាងសំណុំរឿងចាត់ការតាមនីតិវិធីច្បាប់។

បានឃើញរបាយការណ៍សំយោគលេខ ២០៩/១៥ រ.ប.ក ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៥ របស់អធិការដ្ឋាននគរបាលខណ្ឌចំការមន នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ បានសន្និដ្ឋានថា៖ ជនត្រូវចោទឈ្មោះ (ឃាត់ខ្លួន) និងបក្ខពួកឈ្មោះ .,ឈ្មោះ , ឈ្មោះ និង ឈ្មោះ (គេចខ្លួន) ពិតជាបានប្រព្រឹត្តអំពើលួចមានស្ថានទម្ងន់ទោស កាលពីវេលាម៉ោង ០៣ម១៥នាទី រំលងអាធ្រាតឈានចូលថ្ងៃទី ០៩ ខែតុលា ឆ្នាំ២០១៥ នៅចំណុចក្រុមហ៊ុនស៊ីហ្គាទេសចរណ៍ និង ពាណិជ្ជ មានទីតាំងផ្ទះលេខ ៤១BE0 ផ្លូវលេខ ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ ពិតប្រាកដមែន។ ចំណែកជនត្រូវចោទឈ្មោះ (ឃាត់ ខ្លួន) ពិជាបានសមគំនិត ផ្តល់ជាមធ្យោបាយធ្វើសកម្មភាព និង ទទួលផលចោរកម្ម ក្នុងករណីនេះប្រាកដមែន រីឯឈ្មោះ (គេចខ្លួន) ដែលជាប្រពន្ធរបស់ជនត្រូវចោទឈ្មោះ ក៏ជាអ្នកទទួលផលចោរកម្ម ក្នុងករណីនេះផងដែរ។

បានឃើញចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ... បានឆ្លើយនៅសមត្ថកិច្ចថា ៖កាលពីថ្ងៃទី ០៨ ខែតុលា ឆ្នាំ២០១៥ ខ្លួនបានចេញពីក្រុមហ៊ុនរបស់ខ្លួន មានទីតាំងផ្ទះលេខ ៤១BE0 ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ ត្រលប់ទៅសំរាកនៅផ្ទះ។ លុះដល់ម៉ោងប្រហែល ០៤ម០០នាទី ទៀបភ្លឺចូលថ្ងៃទី ០៩ ខែតុលា ឆ្នាំ២០១៥ ពេលខ្លួនកំពុងសំរាក ក៏មានសមត្ថកិច្ចទូរស័ព្ទមកប្រាប់ខ្លួនថា ក្រុមហ៊ុនរបស់ខ្លួនត្រូវបានចោរគាស់ទ្វារ ពេលនោះ ខ្លួនក៏បានមកមើល ទើបដឹងថា បាត់ទូដែកចំនួន០១ ហើយក្នុងទូដែកនោះមានប្រាក់ចំនួន ៥ម៉ឺនដុល្លារអាមេរិក ប្រាក់រៀលចំនួន ២លានរៀល ឯកសារប្លង់ដីមួយចំនួន សៀវភៅធនាគារចំនួន០៣ក្បាល និង បាត់ម៉ាស៊ីនស្កេនចំនួន០១គ្រឿងផងដែរ។

បានឃើញចម្លើយរបស់សាក្សីឈ្មោះ /បានឆ្លើយនៅសមត្ថកិច្ចថា៖ កាលពីថ្ងៃទី ០៨ ខែតុលា ឆ្នាំ២០១៥ ខ្លួនបានចេញពីក្រុមហ៊ុន ត្រលប់ទៅផ្ទះសំរាក ដោយខ្លួនបានចាក់សោរទ្វាក្រុមហ៊ុនត្រឹមត្រូវ។ លុះទៀបភ្លឺថ្ងៃទី ០៩ ខែតុលា ឆ្នាំ២០១៥ ប្រធានក្រុមហ៊ុនរបស់ខ្លួនបានទូរស័ព្ទមកប្រាប់ខ្លួនថា នៅក្រុមហ៊ុនមានចោរចូលគាស់ទ្វា ពេលនោះខ្លួនក៏ប្រញ៉ាប់មកក្រុមហ៊ុន រួចទើបដឹងថាចោរលួចយកទូរដែក០១ នៅក្នុងបន្ទប់របស់ប្រធានក្រុមហ៊ុន។

បានឃើញ ចម្លើយរបស់ជនត្រូវចោទឈ្មោះ ភេទប្រុស អាយុ១៤ឆ្នាំ បានឆ្លើយនៅសមត្ថកិច្ច និងនៅអយ្យការ ប្រហាក់ប្រហែលទៅនឹងចម្លើយនៅចៅក្រមស៊ើបសួរថា៖ កាលពីថ្ងៃទី ០៩ ខែ តុលា ឆ្នាំ២០១៥ វេលាម៉ោងប្រហែល ០៣ម ១៥នាទី ខ្លួនពិតជាបានធ្វើសកម្មភាពគាស់ទ្វារក្រុមហ៊ុននៅម្តុំទួលស្វាយព្រៃ ដោយលួចបានទូរដែកប្រាកដមែន។ មុនដំបូងឈ្មោះ ( ) បានយកម៉ូតូ០១គ្រឿងម៉ាកសេ១០០កូរ៉េផ្លើសពណ៌ក្រហម គ្មានស្លាកលេខ ពីឈ្មោះ ( ) មកតកន្ទុយរ៉ឺម៉ក ដឹករូបខ្លួន និង បក្ខពួកផ្សេងទៀតឈ្មោះ , , និង ដើររកគាស់ផ្ទះរបស់គេយកទ្រព្យសម្បត្តិ។ ពេលពួកខ្លួនធ្វើដំណើរមកដល់ម្តុំទួលស្វាយព្រៃ ក៏បានឃើញក្រុមហ៊ុនរបស់គេចាក់សោរនៅខាងក្រៅ ពេលនោះពួកខ្លួនក៏បានឈប់ម៉ូតូ ហើយខ្លួនក៏បានយកទុលឡឺវីសមកឆ្កឹះសោរសូឡិចទ្វាខាងមុខ ចំណែកឈ្មោះ ឆ្កឹះសោរទ្វាខាងក្នុង រួចនាំគ្នាចូលទៅក្នុងក្រុមហ៊ុនរើកកាយ និងលួចយកបានទូរដែក០១នៅជាន់ខាងលើ ហើយក៏នាំគ្នាដឹកតាមរ៉ឺម៉ក ទៅផ្ទះរបស់ឈ្មោះ

ដើម្បីគាស់ បានឃើញលុយដុល្លារជាច្រើន និង ឯកសារផ្សេងទៀត ហើយចែកលុយគ្នា ដោយខ្លួនទទួលបានប្រាំមួយពាន់ដុល្លារ រីឯឯកសារទាំងនោះត្រូវបានដុតចោល។ បន្ទាប់មកខ្លួនបានយកលុយចំនួនបួនពាន់

ដុល្លារទៅផ្ញើរនិងឈ្មោះ      ហើយសល់ប៉ុន្មានខ្លួនទៅចាយវាយនិងចែកអ្នកជិតខាងនៅស្វាយរៀង។ លុះដល់ថ្ងៃទី ១១ ខែ តុលា ឆ្នាំ២០១៥ ម៉ោងប្រហែល ១៣ម០០នាទី រសៀល ពេលខ្លួនកំពុងអង្គុយលេងជាមួយឈ្មោះ   និង ឈ្មោះ   ស្រាប់តែមានសមត្ថកិច្ចមកដល់ ហើយឃាត់ខ្លួនតែម្តង ចំណែកឈ្មោះ   បានរត់គេចខ្លួន។

បានឃើញ ចម្លើយរបស់ជនត្រូវចោទឈ្មោះ      ភេទប្រុស អាយុ១៥ឆ្នាំ បានឆ្លើយនៅសមត្ថកិច្ច និងនៅអយ្យការ ប្រហាក់ប្រហែលទៅនឹងចម្លើយនៅចៅក្រមស៊ើបសួរថា៖ កាលពីថ្ងៃទី ០៩ ខែ តុលា ឆ្នាំ២០១៥ ខ្លួនពិតជាបានអោយម៉ូតូទៅឈ្មោះ   ជិះធ្វើសកម្មភាពគាស់ផ្ទះរបស់គេលួចទូរដែក ប្រាកដមែន។ មុនដំបូងនៅល្ងាចថ្ងៃទី ០៨ ខែតុលា ឆ្នាំ២០១៥ ឈ្មោះ   បានទូរសព្ទ័មកខ្លួនអោយទៅយកគេនៅម៉ុំច្បារអំពៅ ពេលនោះខ្លួនក៏បានជិះម៉ូតូម៉ាក ១០០ កូរ៉េឆ្នើស ពណ៌ក្រហម គ្មានស្លាកលេខ ហើយឈ្មោះ   ក៏បានខ្ចីម៉ូតូរបស់ខ្លួនជិះ រួចខ្លួនក៏បានជិះម៉ូតូរបស់ឈ្មោះ   ត្រលប់មកផ្ទះវិញ។ មូលហេតុដែលឈ្មោះ   ខ្ចីម៉ូតូរបស់ខ្លួន គឺម៉ូតូរបស់ខ្លួនមានប្រដាប់សណ្តោងរ៉ឺម៉កស្រាប់។ លុះព្រឹកឡើងថ្ងៃទី ០៩ ខែតុលា ឆ្នាំ២០១៥ ម៉ោងប្រហែល៧ម០០នាទី ឈ្មោះ   បានទូរស័ព្ទមកខ្លួនអោយយកមកម៉ូតូ និង បានឲ្យលុយមកខ្លួនចំនួនមួយលានរៀល។ រហូតដល់ថ្ងៃទី ១១ ខែតុលា ឆ្នាំ២០១៥ ម៉ោងប្រហែល ១៣ម០០នាទី ខ្លួនបានជិះម៉ូតូមកអង្គុយលេងជាមួយឈ្មោះ   និង ឈ្មោះ   នៅផ្ទះរបស់ឈ្មោះ   ស្រាប់មានសមត្ថកិច្ចមកឃាត់រូបខ្លួន និង ឈ្មោះ   នាំមកកាន់អធិការដ្ឋាននគរបាលចំការមនតែម្តង ចំណែកឈ្មោះ   បានរត់គេចខ្លួនបាត់។

បានឃើញ ចម្លើយរបស់ជនត្រូវចោទឈ្មោះ    ភេទប្រុស បានឆ្លើយនៅចៅក្រមស៊ើបសួរថា៖ ខ្លួនពិតជាបានចូលរួមប្រព្រឹត្តអំពើលួចគាស់ផ្ទះគេពិតមែន និងមានគ្នាទាំងអស់៥នាក់ ក្នុងនោះមានឈ្មោះ   , ឈ្មោះ  , ឈ្មោះ  , ឈ្មោះ   ហៅ   ។ ពេលនោះពួកខ្លួនលួចបាន ទូដែក១ យកទៅបើកនៅផ្ទះរបស់ខ្លួន ក្នុងនោះមានលុយចំនួន៥០,០០០$ (ប្រាំម៉ឺនដុល្លារអាមេរិកគត់) ហើយក៏បានចែកគ្នា ដោយរូបខ្លួនបានចំណែកចំនួន ១០,០០០$ (មួយម៉ឺនដុល្លារអាមេរិកគត់) លុយសល់ពីនោះ ទុកឲ្យបក្ខពួក៤នាក់ទៀតចែកគ្នា។ ចំណែកទូរដែកនោះ បានបោះចោល ជាមួយឯកសារនៅក្បែរវត្តច្បារអំពៅ។

- ដីកាបង្គាប់ឲ្យចូលខ្លួនលេខ ១៨៤៨៦ ចុះថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ លើឈ្មោះ    ។

- ដីកាបង្គាប់ឲ្យនាំខ្លួនលេខ ៨០៦ ចុះថ្ងៃទី ១៨ ខែធ្នូ ឆ្នាំ២០១៥ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ លើឈ្មោះ    ។

- ដីកាសម្រេចឲ្យឃុំខ្លួនបណ្តោះអាសន្នលេខ ៥១៦៣ ត.ព្រ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៥ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ លើឈ្មោះ    ។

- ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ៣៥២៦ ក.ព្រ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៥ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ លើឈ្មោះ    ។

- ដីកាសម្រេចឲ្យឃុំខ្លួនបណ្តោះអាសន្នលេខ ៤១២៤ ត.ព្រ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៥ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ លើឈ្មោះ ... . . ...។

- ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ២៨៣៤ ត.ព្រ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៥ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ លើឈ្មោះ    ។

- ដីកាសម្រេចឲ្យឃុំខ្លួនបណ្តោះអាសន្នលេខ ៤១២៣ ត.ព្រ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៥ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ លើឈ្មោះ ។

- ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ២៨៣៩ ត.ព្រ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៥ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ លើឈ្មោះ ។

- ដីកាបញ្ជូនឲ្យឆ្លើយលេខ ២០៩១២ តព្រ ចុះថ្ងៃទី ២១ ខែធ្នូ ឆ្នាំ២០១៥ របសចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ លើឈ្មោះ ។

- ដីកាបង្គាប់ឲ្យចាប់ខ្លួនលេខ ៨១៣ តព្រ ចុះថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ២០១៥ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ លើឈ្មោះ ។

- ដីកាចាត់ឲ្យស៊ើបសួរជំនួសលេខ ១៨៤៨៩ តព្រ ចុះថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ លើឈ្មោះ ភេទប្រុស, ឈ្មោះ ភេទប្រុស និង ឈ្មោះ ភេទប្រុស។

- របាយការណ៍របស់នគរបាលប៉ុស្តិ៍ទួលស្វាយព្រៃទី១ ចុះថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ២០១៥ តាមការចុះស្រាវជ្រាវរកឈ្មោះ ភេទប្រុស, ឈ្មោះ ភេទប្រុស និង ឈ្មោះ ភេទប្រុស ជាប់ចោទពីបទ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ពុំមានស្ថិតិស្នាក់នៅនិងសាវតាជាតិនៅក្នុងមូលដ្ឋានមណ្ឌលទី៤នោះទេ។

- លិខិតជូនដំណឹង ឬជូនព័ត៌មានដល់តំណាងអយ្យការលេខ ២០៧៣៧ ត.ព្រ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ របស់សាលាដំបូងរាជធានីភ្នំពេញ ។

- ឯកសារមួយចំនួនទៀតដែលពាក់ព័ន្ធសំណុំរឿង ។

## <u>យល់ឃើញថា</u>

- តាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី សាក្សី និងចម្លើយសារភាពរបស់ជនត្រូវចោទ ពេនភាពស៊ីសង្វាក់ទៅនឹងភស្តុតាងអាចបង្ហាញឲ្យឃើញថា ៖ ជនត្រូវចោទឈ្មោះ ភេទប្រុស អាយុ២៧ឆ្នាំ , ឈ្មោះ ភេទប្រុស <u>អាយុ១៥ឆ្នាំ</u> និង ឈ្មោះ ភេទប្រុស <u>អាយុ១៤ឆ្នាំ</u> ពិតជាបានប្រព្រឹត្តអំពើឆ្កឹះសោរទ្វារក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ដើម្បីលួចយកប្រាក់របស់ជនរងគ្រោះឈ្មោះ ភេទប្រុស អាយុ៤២ឆ្នាំ ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ មានទីតាំងផ្ទះលេខ ៤១BE0 ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ ពិតប្រាកដមែន ។

- អំពើរបស់ឈ្មោះ ភេទប្រុស អាយុ២៧ឆ្នាំ, ឈ្មោះ ភេទប្រុស <u>អាយុ១៤ឆ្នាំ</u>, ឈ្មោះ ភេទប្រុស (គេចខ្លួន), ឈ្មោះ ភេទប្រុស (គេចខ្លួន) និង ឈ្មោះ ភេទប្រុស (គេចខ្លួន) គឺអំពើដកហូតទ្រព្យសម្បត្តិរបស់ជនរងគ្រោះដោយចេតនាទុច្ចរិត តាមមធ្យោបាយឆ្កឹះសោទ្វារក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ ដើម្បីមកធ្វើជាកម្មសិទ្ធរបស់ខ្លួន ដែលធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ជនរងគ្រោះ ហើយធ្វើឲ្យប៉ះពាល់ដល់សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ព្រមទាំងរបៀបរៀបរយល្អរបស់សង្គម ដែលច្បាប់បញ្ញត្តិថាជាបទល្មើសលួចមានស្ថានទម្ងន់ទោស និងបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

- អំពើរបស់ឈ្មោះ ភេទប្រុស <u>អាយុ១៥ឆ្នាំ</u> គឺជាអំពើសំរបសំរួលដើម្បីសម្រេចបាននូវសកម្មភាពក្នុងអំពើលួចទ្រព្យសម្បត្តិរបស់ជនរងគ្រោះដោយចេតនាទុច្ចរិតតាមមធ្យោបាយឆ្កឹះសោទ្វារក្រុមហ៊ុន

ស៊ុហ្គាទេសចរណ៍ដើម្បីយកប្រាក់ធ្វើជាកម្មសិទ្ធរបស់ខ្លួន ដែលធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ជនរងគ្រោះ ហើយធ្វើឲ្យប៉ះពាល់ដល់សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ព្រមទាំងរបៀបរៀបរយល្អរបស់សង្គម ដែលច្បាប់បញ្ញត្តិថាជាបទល្មើសសមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោសដោយប្រើអំពើហិង្សា និងបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា២៩, ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

- អំពើរបស់ឈ្មោះ ភេទប្រុស អាយុ២២ឆ្នាំ គឺជាអ្នកទទួលផលក្នុងអំពើលួចទ្រព្យសម្បត្តិរបស់ជនរងគ្រោះដោយចេតនាទុច្ចរិត ដែលធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ជនរងគ្រោះ ហើយធ្វើឲ្យប៉ះពាល់ដល់សន្តិសុខនិងសណ្តាប់ធ្នាប់សាធារណៈ ព្រមទាំងរបៀបរៀបរយល្អរបស់សង្គម ដែលច្បាប់បញ្ញត្តិថាជាបទល្មើសទទួលផលចោរកម្ម និងបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា៣៩៩ និងមាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ។

- ឈ្មោះ ភេទប្រុស អាយុ២៧ ឆ្នាំ និងឈ្មោះ ភេទស្រី អាយុ២២ឆ្នាំ ជានីតិជនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវចំពោះមុខច្បាប់ នូវអំពើដែលខ្លួនបានប្រព្រឹត្ត។

- ឈ្មោះ ភេទប្រុស អាយុ១៥ឆ្នាំ និង ឈ្មោះ ភេទប្រុស អាយុ១៤ឆ្នាំ ជា អនីតិជន ប៉ុន្តែមានលក្ខណៈសម្បត្តិយល់ដឹងធនល្មមក្នុងការទទួលខុសត្រូវចំពោះមុខច្បាប់ នូវអំពើដែលខ្លួនបានប្រព្រឹត្ត។

- មានភស្តុតាងគ្រប់គ្រាន់សម្រាប់ដាក់បន្ទុកលើឈ្មោះ និង ឈ្មោះ ពីបទះលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា, ឈ្មោះ ភេទប្រុស ពីបទះសមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា និងឈ្មោះ ភេទស្រី ពីបទះ ទទួលផលចោរកម្ម ប្រព្រឹត្តិនៅចំណុចក្រុមហ៊ុនស៊ុហ្គាលទេសចរណ៍ និងពាណិជ្ជ មានទីតាំងផ្ទះលេខ ៤១BE0 ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ ។

- តាមលទ្ធផលស្រាវជ្រាវរបស់នគរបាលប៉ុស្តិ៍ទួលស្វាយព្រៃទី១ ចុះថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ២០១៥ រកពុំឃើញឈ្មោះ ភេទប្រុស, ឈ្មោះ ភេទប្រុស និង ឈ្មោះ ភេទប្រុស ជាប់ចោទពីបទ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ស្ថិតិស្នាក់នៅនិងសាវតាជាតិនៅក្នុងមូលដ្ឋានមណ្ឌលទី៤ ទេ។

- យោងតាមមាត្រា ២៤៧ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មមាត្រា២៤៧ មាត្រា៣៦៨ មាត្រា៣៧១ និងមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ គប្បីចៅក្រមលើកលែងចោទប្រកាន់លើឈ្មោះ ឈ្មោះ ភេទប្រុស, ឈ្មោះ ភេទប្រុស និង ឈ្មោះ ភេទប្រុស ដោយហេតុជនត្រូវចោទនេះពុំសាវតាជាតិពិតប្រាកដ។

## ហេតុដូច្នេះ

ប្តឹងសុំឲ្យចៅក្រមស៊ើបសួរសម្រេច ៖

☑ បញ្ជូនជនត្រូវចោទឈ្មោះ

១. ...... ភេទប្រុស អាយុ២៧ឆ្នាំ (ឃាត់ខ្លួន)

២. ... ភេទប្រុស អាយុ១៤ឆ្នាំ(ឃាត់ខ្លួន) ទៅជំនុំជម្រះ។

ពីបទ ៖លួចមានស្ថានទម្ងន់ទោសដោយសារប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តិនៅចំណុចក្រុមហ៊ុនស៊ុហ្គាលទេសចរណ៍ និងពាណិជ្ជ មានទីតាំងផ្ទះលេខ ៤១BE0 ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី

១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញត្តិឲ្យផ្ដន្ទាទោសតាមមាត្រា៣៥៣ និង មាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

៣. ភេទប្រុស <u>អាយុ១៥ឆ្នាំ</u> (ឃាត់ខ្លួន) ទៅជំនុំជម្រះ

ពីបទ ៖សមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោសដោយសារប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តិនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ មានទីតាំងផ្ទះលេខ ៤១BE0 ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញត្តិឲ្យផ្ដន្ទាទោសតាមមាត្រា២៩, មាត្រា៣៥៣ និង មាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

៤. ភេទស្រី អាយុ២២ឆ្នាំ (គេចខ្លួន) ទៅជំនុំជម្រះ

ពីបទ ៖ទទួលផលចោរកម្ម ប្រព្រឹត្តិនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ មានទីតាំងផ្ទះលេខ ៤១BE0 ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញត្តិឲ្យផ្ដន្ទាទោសតាមមាត្រា៣៩៩ និង មាត្រា៤០០ នៃក្រមព្រហ្មទណ្ឌ ។

☑ លើកលែងចោទប្រកាន់

- ឈ្មោះ ភេទប្រុស, ឈ្មោះ ភេទប្រុស និង ឈ្មោះ ភេទប្រុស

ពីបទ ៖លួចមានស្ថានទម្ងន់ទោសដោយសារប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តិនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ មានទីតាំងផ្ទះលេខ ៤១BE0 ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញត្តិឲ្យផ្ដន្ទាទោសតាមមាត្រា៣៥៣ និង មាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ មករា ឆ្នាំ២០១៦

ព្រះរាជអាជ្ញា

**ព្រះរាជអាជ្ញារង**

# ឧបសម្ព័ន្ធទី៤

## ដីកាលើកលែងចោទប្រកាន់

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

មន្ទីរស៊ើបសួរ ( ៣ )

លេខ ២១០ ដដ

## <u>ដីកាលើកលែងចោទប្រកាន់</u>

យើង ចៅក្រមស៊ើបសួរ សាលាដំបូងរាជធានីភ្នំពេញ

អមដោយលោក ជាក្រឡាបញ្ជី ។

បានឃើញមាត្រា ២៤៧ និងមាត្រាពាក់ព័ន្ធនៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ ៤០៣៩ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៥។

បានឃើញដីកាសន្និដ្ឋានឲ្យស៊ើបសួរលេខ ២៥៩៤ អ.យ.ទ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៥ របស់តំណាងអយ្យការ អមសាលាដំបូងរាជធានីភ្នំពេញ។

បានឃើញសំណុំរឿងស៊ើបសួរលេខ ២៦០៥ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៥ របស់សាលាដំបូងរាជធានីភ្នំពេញ។

បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ ៦៣ អ.យ.ទ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១៦ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

ក្រោយពីបានស៊ើបសួរ និងពិនិត្យសំណុំរឿងចប់សព្វគ្រប់

### សំអាងហេតុ

១.ជនត្រូវចោទឈ្មោះ ភេទប្រុស ,ឈ្មោះ ភេទប្រុស និងឈ្មោះ ភេទប្រុស (គ្មានអត្តសញ្ញាណ) ត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យពីបទ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BE0 ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ តាមមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

២.តាមដីកាសន្និដ្ឋានស្ថាពរលេខ ៦៣ អ.យ.ទ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១៦ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ បានប្ដឹងសុំឲ្យចៅក្រមស៊ើបសួរលើកលែងចោទប្រកាន់លើឈ្មោះ ភេទប្រុស ,ឈ្មោះ ភេទប្រុស និងឈ្មោះ ភេទប្រុស (គ្មានអត្តសញ្ញាណ) ដែលត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យពីបទ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BE0 ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ តាមមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។ គប្បីចៅក្រមស៊ើបសួរចេញដីកាដំណោះស្រាយ លើកលែងចោទប្រកាន់លើឈ្មោះ ភេទប្រុស ,ឈ្មោះ ភេទប្រុស និងឈ្មោះ ភេទប្រុស (គ្មានអត្តសញ្ញាណ) តាមមាត្រា២៤៧ថ្មី នៃច្បាប់ស្ដីពីវិសោធនកម្មមាត្រា២៤៧ ក្រមនីតិវិធីព្រហ្មទណ្ឌ។

## ហេតុដូច្នេះសម្រេច

លើកលែងចោទប្រកាន់លើឈ្មោះ ភេទប្រុស ,ឈ្មោះ ភេទប្រុស និងឈ្មោះ ភេទប្រុស (គ្មានអត្តសញ្ញាណ) ពីបទៈលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BE0 ផ្លូវលេខ ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី ០៩ ខែតុលា ឆ្នាំ២០១៥ តាមមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

លេខ ......៦៨......អ.យ.ទ

បានទទួលដំណឹង

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែមករា ឆ្នាំ២០១៦

ជ.ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញារង

ក្រឡាបញ្ជី

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែមករា ឆ្នាំ២០១៦

ចៅក្រមស៊ើបសួរ

# ឧបសម្ព័ន្ធទី៥

## ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះ

សាលាដំបូងរាជធានីភ្នំពេញ

មន្ទីរស៊ើបសួរ ( ៣ )

លេខ ៤១ ដ.ជ

យើង ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ

អមដោយលោក ជាក្រឡាបញ្ជី ។

បានឃើញ មាត្រា ២៤៧ និងមាត្រា ២៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខៈ ៨០៣៩ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៥។

បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខៈ ២៥៩៤ អ.យ.ទ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៥ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខៈ ៦៣ អ.យ.ទ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១៦ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

បានឃើញ ដីកាសម្រេចរក្សាជនជាប់ចោទក្នុងឃុំបណ្ដោះអាសន្នលេខ៦៥៤,៦៥១,៦៩០(ព)ដឃដ ចុះថ្ងៃទី.....១៨..... ខែមករា ឆ្នាំ២០១៦។

ក្រោយពីបានពិនិត្យស៊ើបសួរចប់សព្វគ្រប់ហើយយល់ឃើញថា មានពិរុទ្ធភាពគ្រប់គ្រាន់លើ :

១.ឈ្មោះ ភេទប្រុស អាយុ១៨ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរ រើសអេតចាយ ទីកន្លែងកំណើតនៅសង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន ក្រុងភ្នំពេញ ទីលំនៅបច្ចុប្បន្ននៅភូមិស្វាយតាអុក សង្កាត់ភ្នំលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ឪពុកឈ្មោះ (ស) ម្ដាយឈ្មោះ (រ) នៅលីវ ជានីតិជន។

២.ឈ្មោះ ហៅ ភេទប្រុស អាយុ២៧ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើតភូមិស្លែង សង្កាត់ច្បារអំពៅ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ មានទីលំនៅបច្ចុប្បន្នភូមិស្លែង សង្កាត់ច្បារអំពៅទី២ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ឪពុកឈ្មោះ (ស) ម្ដាយឈ្មោះ (រ) ប្រពន្ធឈ្មោះ (រ) ជានីតិជន។

ប្រវត្តិនៃការផ្តន្ទាទោសតាមផ្លូវតុលាការៈ គ្មាន។

ពីបទៈ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BE0 ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ តាមមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

៣.ឈ្មោះ ហៅ ភេទប្រុស អាយុ១៥ឆ្នាំ ជាតិខ្មែរ មុខរបរ រើសអេតចាយ ទីកន្លែងកំណើតនៅស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ទីលំនៅបច្ចុប្បន្ននៅភូមិស្វាយតាអុក សង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ឪពុកឈ្មោះ (រ) ម្ដាយឈ្មោះ (ស) នៅលីវ ទោសពីមុនគ្មាន ជានីតិជន។

ប្រវត្តិនៃការផ្តន្ទាទោសតាមផ្លូវតុលាការៈ គ្មាន។

ជាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យពីបទៈ សមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BE0 ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ តាមមាត្រា២៩,មាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

៤.ឈ្មោះ ភេទស្រី អាយុ២២ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិគ្រួស ឃុំគ្រួស ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង ទីលំនៅបច្ចុប្បន្ននៅភូមិគ្រួស ឃុំគ្រួស ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង ឪពុកឈ្មោះ (ស) ម្តាយឈ្មោះ (រ) ប្តីឈ្មោះ ទោសពីមុនគ្មាន ជានីតិជន។

ប្រវត្តិនៃការផ្តន្ទាទោសតាមផ្លូវតុលាការៈ គ្មាន។

ដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យពីបទៈ ទទួលផលចោរកម្ម ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BE0 ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ តាមមាត្រា៣៩៩ និងមាត្រា៤០០ នៃក្រមព្រហ្មទណ្ឌ។

## ហេតុដូច្នេះសម្រេច

បញ្ជូនជនត្រូវចោទឈ្មោះ ភេទប្រុស អាយុ២៧ឆ្នាំ ជាតិខ្មែរ ,ឈ្មោះ ភេទប្រុស អាយុ១៤ឆ្នាំ ,ឈ្មោះ ភេទប្រុស អាយុ១៥ឆ្នាំ និងឈ្មោះ ភេទស្រី អាយុ២២ឆ្នាំ ខាងលើនេះ និងសំណុំរឿងព្រហ្មទណ្ឌលេខៈ ៤០៣៩ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៥ ព្រមទាំងវត្ថុតាង និងបញ្ជីរាយនាមជនដែលទាក់ទិនក្នុងរឿងនេះ ទៅប្រធានសាលាដំបូងរាជធានីភ្នំពេញដើម្បីកំណត់ពេលសវនាការជំនុំជម្រះ។

បានទទួលដំណឹង

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែមករា ឆ្នាំ២០១៦

ជ. ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញារង

ក្រឡាបញ្ជី

រាជធានីភ្នំពេញ ថ្ងៃទី ១០... ខែមករា ឆ្នាំ២០១៦

ចៅក្រមស៊ើបសួរ

# ឧបសម្ព័ន្ធទី៦

## សាលក្រម

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌ
លេខ :៤០៣៩
ចុះថ្ងៃទី១៣/១០/២០១៥
ជំនុំជំរះលេខ: ១៩៧
ចុះថ្ងៃទី២២/០១/២០១៦
សាលក្រមព្រហ្មទណ្ឌ
លេខ: ១៤១ ក្រ៨ "ជ"
ចុះថ្ងៃទី២២/០៤/២០១៦

**នាមនាមប្រជារាស្ត្រខ្មែរ**

**សាលាដំបូងរាជធានីភ្នំពេញ**

បានបើកសវនាការជាសាធារណៈនៅសាលាដំបូងរាជធានីភ្នំពេញនាថ្ងៃទី ០៧ ខែមេសា ឆ្នាំ២០១៦ នៅវេលាម៉ោង ០៨.៣០នាទី ព្រឹកដែលមានសមាសភាពដូចខាងក្រោម :

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក ប្រធានក្រុមប្រឹក្សា
លោក ចៅក្រមប្រឹក្សា
លោក ចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

លោក ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

លោកស្រី ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

**ដើម្បីជំនុំជំរះ**

លើសំណុំរឿងព្រហ្មទណ្ឌលេខ ៤០៣៩ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៥ មានជនជាប់ចោទ:

១/ឈ្មោះ ភេទប្រុស អាយុ១៤ឆ្នាំ ជនជាតិខ្មែរ មុខរបរដើររើសអេតចាយ ទីកន្លែងកំណើតសង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ ទីលំនៅបច្ចុប្បន្នភូមិស្វាយតាអុក សង្កាត់វាស្សរ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ឪពុកឈ្មោះ (ស) ម្តាយឈ្មោះ (រ)នៅលីវ ជាអនីតិជន ។

-ឃាត់ខ្លួននៅថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៥។

-និងឃុំខ្លួនតាមដីកាលេខ២៨៣៩ ត.ព ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៥។

២/ឈ្មោះ ហៅ ភេទប្រុស អាយុ២៧ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិស្លែង សង្កាត់ច្បារអំពៅ២ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ (ស) ម្តាយឈ្មោះ (រ) ប្រពន្ធឈ្មោះ (រ) ជានីតិជន ។

-ឃាត់ខ្លួនកាលពីថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៥។

-និងឃុំខ្លួនតាមដីកាលេខ៣៥២៦ តព ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៥ ។

ពីបទ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គោលទេសចរណ៍ និងពាណិជ្ជ ដែលមានទីតាំងនៅផ្ទះលេខ៤១BEo ផ្លូវលេខ៣៤៨ ក្រុម១៤ ភូមិ១៤ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញាតិឲ្យផ្តន្ទាទោសតាមមាត្រា៣៥៣, ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

៣/ឈ្មោះ ហៅ ភេទប្រុស អាយុ១៥ឆ្នាំ ជាតិខ្មែរ មុខរបរដើររើសអេតចាយទីកន្លែងកំណើតស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង ទីលំនៅបច្ចុប្បន្នភូមិស្វាយតាអុក

សង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ឪពុកឈ្មោះ (រ) ម្តាយឈ្មោះ (រ) ជាអនីតិជន ទោសពីមុនគ្មាន ។

-ឃាត់ខ្លួនកាលពីថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៥។

-និងឃុំខ្លួនតាមដីកាលេខ២៨៣៤ តព ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៥។

ត្រូវជាប់ចោទពីបទ សមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គោលទេសចរណ៍ និងពាណិជ្ជ ដែលមានទីតាំងនៅផ្ទះលេខ៤១BEo ផ្លូវលេខ៣៤៨ ក្រុម១៤ ភូមិ១៤ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញាតិឲ្យផ្តន្ទាទោសតាមមាត្រា២៩,៣៥៣, ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

៤/ឈ្មោះ ភេទស្រី អាយុ២២ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិគ្រួស ឃុំគ្រួស ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ទីលំនៅសព្វថ្ងៃភូមិគ្រួស ឃុំគ្រួស ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ឪពុកឈ្មោះ (ស)ម្តាយឈ្មោះ (រ)ប្តីឈ្មោះ ទោសពីមុនគ្មាន ជានីតិជន(ក្រៅឃុំ) ។

ដោយមានកញ្ញា ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

ត្រូវជាប់ចោទពីបទ ទទួលផលចោរកម្ម ក្រុមហ៊ុនស៊ីហ្គោលទេសចរណ៍ និងពាណិជ្ជ ដែលមានទីតាំងនៅផ្ទះលេខ៤១BEo ផ្លូវលេខ៣៤៨ ក្រុម១៤ ភូមិ១៤ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញាតិឲ្យផ្តន្ទាទោសតាមមាត្រា៣៩៩,៤០០ នៃក្រមព្រហ្មទណ្ឌ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ភេទប្រុស អាយុ៤២ឆ្នាំ ជាតិខ្មែរ មុខរបរជាប្រធានក្រុមហ៊ុនស៊ីហ្គោលទេសចរណ៍និងពាជ្ជណិ ទីលំនៅកំណើតឃុំកំពង់សៀម ស្រុកកំពង់សៀម ខេត្តកំពង់ចាម ទីលំនៅសព្វថ្ងៃផ្ទះលេខ២៧៩BEo ផ្លូវ១៨២ ភូមិ៨ សង្កាត់ទឹកល្អក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

-បានឃើញ របាយការណ៍សំយោគលេខ ២០៩ រ.ប.ក ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៥ របស់របស់អធិការដ្ឋាននគរបាលខណ្ឌចំការមន នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ។

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ៦៣ អ.យ.ទ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១៦ របស់ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជំរះលេខ ២០៩ ដ.ដ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១៦ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ ។

<u>**អង្គហេតុដែលត្រូវបានចោទប្រកាន់និងបញ្ជូនមកជំនុំជម្រះ**</u>

កាលពី០៩ ខែតុលា ឆ្នាំ២០១៥ វេលាម៉ោងប្រហែល៣,១៥នាទីទាបភ្លឺជនជាប់ចោទឈ្មោះ , ឈ្មោះ ហៅ , ឈ្មោះ , ឈ្មោះ និងឈ្មោះ បានជិះម៉ូតូម៉ាក CITY 100 PLUS ពណ៌ក្រហមគ្មានស្លាកលេខ លេខម៉ាស៊ីន០១៧៤៤៦ ដោយមាន សណ្តោងរ៉ឺម៉កដែលជាកម្មសិទ្ធិរបស់ឈ្មោះ មកឈប់នៅខាងមុខក្រុមហ៊ុនស៊ិនស៊ីហ្គោលទេសចរណ៍ និងពាជ្ជណិ ដែលមានទីតាំងស្ថិតនៅផ្ទះលេខ៤១BEo ផ្លូវលេខ៣៤៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន មានជនជាប់ចោទឈ្មោះ បានធ្វើសកម្មភាពយកទូឡឺវីសឆ្កឹះសោទ្វាខាងមុខចំណែកជនជាប់ចោទឈ្មោះ បានឆ្កឹះសោទ្វាខាងក្នុងរួចបាននាំគ្នាចូលទៅក្នុងក្រុមហ៊ុនលួចយកទូរដែកចំនួន១ ដែលក្នុងនេះមានប្រាក់ចំនួន

ប្រាំម៉ឺនដុល្លារអាមេរិក ប្រាក់រៀលចំនួន២លានរៀល និង ឯកសារប្លង់ដីព្រមទាំងសៀវភៅធនាគារ និងលួចយកម៉ាស៊ីនស្កេនចំនួន១ បន្ទាប់មកជនជាប់ចោទបានគេចខ្លួនទៅផ្ទះរបស់ឈ្មោះ ហើយបានយកប្រាក់ទាំងនេះចែកជាចំណែក ដោយឈ្មោះ ទទួលបានប្រាក់ចំនួន១លានរៀល បន្ទាប់មកជនជាប់ចោទឈ្មោះ បានយកប្រាក់ចំនួន៤,០០០$ផ្ញើទុកនៅនឹងឈ្មោះ ដែលត្រូវជាប្រពន្ធរបស់ជនជាប់ចោទរបស់ឈ្មោះ ។ ចំណែកជនជាប់ចោទឈ្មោះ បានឲ្យប្រាក់ទៅប្រពន្ធចំនួន១ម៉ឺនដុល្លារអាមេរិក រហូតដល់ថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៥ សមត្ថកិច្ចបានធ្វើការស្រាវជ្រាវហើយឃាត់ខ្លួនជនជាប់ចោទបានចំនួន២នាក់គឺឈ្មោះ និងឈ្មោះ ព្រមទាំងដកហូតបានវត្ថុតាងដើម្បីកសាងសំណុំរឿងចាត់ការតាមនីតិវិធី ។

<u>នាពេលសវនាការ</u>

-ជនជាប់ចោទឈ្មោះ ឆ្លើយនៅពេលសវនាការថា: កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ វេលាម៉ោងប្រហែល៣,១៥នាទី ខ្ញុំពិតជាបានធ្វើសកម្មភាពគាស់ទ្វាក្រុមហ៊ុននៅម្តុំទួលស្វាយព្រៃដោយលួចបានទូរដែកប្រាកដមែន ។ មុនដំបូងឈ្មោះ បានយកម៉ូតូមួយគ្រឿងម៉ាកសេ១០០កូរ៉េឆ្នើលពណ៌ក្រហមគ្មានស្លាកលេខពីឈ្មោះ ( ) មកកកន្ទុយរ៉ឺម៉កបានដឹករូបខ្ញុំនិងបក្ខពួកផ្សេងទៀតឈ្មោះ , , និង ដើររកគាស់ផ្ទះរបស់គេយកទ្រព្យសម្បត្តិ ។ ពេលពួកខ្ញុំធ្វើដំណើរមកដល់ទួលស្វាយព្រៃក៏បានឃើញក្រុមហ៊ុនរបស់គេចាក់សោនៅខាងក្រៅ ពេលនោះពួកខ្ញុំក៏បានឈប់ម៉ូតូហើយខ្ញុំក៏បានយកទូឡឺវីសមកឆ្កិះសោសូឡិចទ្វាខាងមុខ ចំណែកឈ្មោះ ឆ្កិះសោទ្វាខាងក្នុងរួចបាននាំគ្នាចូលទៅក្នុងក្រុមហ៊ុនរើកកាយនិងលួចយកបានទូរដែក១នៅជាន់ខាងលើ ហើយក៏នាំគ្នាដឹកតាមរ៉ឺម៉កទៅផ្ទះរបស់ឈ្មោះ ដើម្បីគាស់បានឃើញលុយជាច្រើន និងឯកសាផ្សេងទៀត រួចហើយបានចែកលុយគ្នាដោយខ្ញុំទទួលបានប្រាំពាន់ដុល្លារអាមេរិក រីឯឯកសារទាំងនោះត្រូវបានដុតចោល បន្ទាប់មកខ្ញុំបានយកលុយចំនួន៤ពាន់ដុល្លារអាមេរិក ទៅផ្ញើនិងឈ្មោះ នៅសល់ប៉ុន្មានពួកខ្ញុំបានយកទៅចាយវាយនិងចែកអ្នកជិតខាង នៅស្វាយរៀង លុះដល់ថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៥ ម៉ោងប្រហែល១៣,០០នាទីរសៀលខ្ញុំកំពង់អង្គុយលេង ជាមួយឈ្មោះ និងឈ្មោះ ស្រាប់តែមានសមត្ថកិច្ចមកដល់ ហើយឃាត់ខ្លួនតែម្តង ចំណែកឈ្មោះ បានរត់គេចខ្លួនបាត់ ។

-ជនជាប់ចោទឈ្មោះ ឆ្លើយនៅពេលសវនាការថា: កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ ខ្ញុំពិតជាបានយកម៉ូតូទៅឈ្មោះ ជិះធ្វើសកម្មភាពគាស់ផ្ទះរបស់គេលួចទូរដែកប្រាកដមែន ។ មុនដំបូងនៅល្ងាចថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៥ឈ្មោះ បានឲ្យទូរសព្ទមកខ្ញុំឲ្យយកទៅគេនៅម្តុំច្បាររអំពៅ ពេលនោះខ្ញុំក៏បានជិះម៉ូតូម៉ាកសងសេ១០០ កូរ៉េឆ្នើសពណ៌ក្រហមគ្មានស្លាកលេខ ហើយឈ្មោះ ក៏បានខ្ចីម៉ូតូរបស់ខ្ញុំជិះរួចខ្ញុំក៏បានជិះម៉ូតូរបស់ឈ្មោះ ត្រលប់មកផ្ទះវិញមូលហេតុដែលឈ្មោះ ខ្ចីម៉ូតូរបស់ខ្ញុំគឺម៉ូតូរបស់ខ្ញុំមានប្រដាប់សន្តោងរ៉ឺម៉កស្រាប់ ។ លុះព្រឹកថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ វេលាម៉ោងប្រហែល៧,០០នាទីឈ្មោះ បានទូរសព្ទប្រាប់ឲ្យខ្ញុំមកយកម៉ូតូ និងបានឲ្យលុយមកខ្ញុំចំនួន១លានរៀល ។ រហូតដល់ថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៥ ម៉ោងប្រហែល១៣,០០នាទី ខ្ញុំបានជិះម៉ូតូមកអង្គុយលេងជាមួយឈ្មោះ និងឈ្មោះ នៅផ្ទះរបស់ឈ្មោះ ស្រាប់តែមានសមត្ថកិច្ចមកឃាត់ខ្លួនខ្ញុំ និងឈ្មោះ នាំមកកាន់អធិការដ្ឋាននគរបាលតែម្តង ចំណែកឈ្មោះ បានរត់គេចខ្លួនបាត់ ។

-ជនជាប់ចោទឈ្មោះ ឆ្លើយនៅពេលសវនាការថា: ខ្ញុំពិតជាបានចូលរួមគាស់ផ្ទះគេពិតមែន និងមានគ្នាទាំងអស់៥នាក់ក្នុងនេះមានឈ្មោះ ឈ្មោះ ,ឈ្មោះ ,ឈ្មោះ ហៅ ។ ពេលនោះពួកខ្ញុំលួចបានទូដែក១ យកទៅបើកនៅផ្ទះរបស់ខ្ញុំ ក្នុងនោះមានលុយចំនួន៥០,០០០$ រួចហើយក៏បានចែកគ្នា ដោយខ្ញុំបានចំនួន១០,០០០$ លុះសល់ពីនោះទុកឲ្យបក្សពួក៤នាក់ទៀតចែកគ្នា ចំណែកទូរដែកនេះបានបោះចោល ជាមួយឯកសារនៅក្បែរវត្តច្បាររអំពៅ ។

-ក្រឡាបញ្ជីអានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ . . . . នៅពេលសវនាការថា: កាលពី ថ្ងៃទី០៨ខែតុលា ឆ្នាំ២០១៥ ខ្ញុំបានចេញពីក្រុមហ៊ុនរបស់ខ្ញុំមានទីតាំងផ្ទះលេខ៤១BEo ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ ត្រលប់ទៅ សម្រាក់នៅផ្ទះលុះដល់ម៉ោងប្រហែល៤,០០នាទីទាបភ្លឺ ចូលថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ ពេល ខ្ញុំកំពង់សម្រាកក៏មានសមត្ថកិច្ចបានទូរសព្ទ័ប្រាប់ខ្ញុំថា ក្រុមហ៊ុនរបស់ខ្ញុំត្រូវមានចោរលួចគាស់ទ្វា ពេលនោះខ្ញុំក៏បាននមករមើល ទើបទឹងថាបាត់ទូរដែកចំនួន១ ហើយក្នុងទូរដែកនេះ មានប្រាក់ចំនួន៥០,០០០$ , ប្រាក់រៀលចំនួន២លានរៀល , ឯកសារប្លង់ដីមួយចំនួន , សៀវ ភៅធនាគារចំនួន៣ក្បាល និងបាត់ម៉ាស៊ីនស្កេនចំនួន១ផងដែរ នៅក្នុងរឿងនេះខ្ញុំសុំទាមទារប្រាក់ដែលបានបាត់បង់ទៅសរុបចំនួន ៥០,០០០$ លុយខ្មែរចំនួន ២,០០០,០០០រៀល ព្រមទាំងឯកសារផ្សេងៗទៀត ។

-ក្រឡាបញ្ជីអានចម្លើយសាក្សីឈ្មោះ . នៅពេលសវនាថា : កាលពីថ្ងៃទី ០៨ ខែតុលា ឆ្នាំ២០១៥ ខ្ញុំបាន ចេញពីក្រុមហ៊ុនត្រលប់ទៅផ្ទះសម្រាក ហើយខ្ញុំបានចាក់សោរទ្វាត្រឹមត្រូវលុះទាមភ្លឺថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ ប្រធានក្រុមហ៊ុនរបស់ខ្ញុំបានទូរសព្ទ័មកប្រាប់ខ្ញុំថា នៅក្រុមហ៊ុនមានចោរ ចូលគាស់ទ្វា ពេលនោះខ្ញុំក៏ប្រញាប់មកក្រុមហ៊ុន ទើបដឹងថាចោរបានលួចយកទូរដែក១នៅ ក្នុងបន្ទប់របស់ប្រធានក្រុមហ៊ុន ។

-តំណាងយក្សការធ្វើសេចក្តីសន្និដ្ឋានថា: ក្រោយពីបានសួរដេញដោលចប់សព្វគ្រប់ឃើញថា ជនជាប់ឈ្មោះ ,ឈ្មោះ និងឈ្មោះ បានឆ្លើយសារភាពថាពួកខ្លួនពិតជាបានលួចគាស់ទ្វាក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជដោយលួចបានទូរដែកចំនួន១ ហើយនៅក្នុងទូរដែកនេះមានប្រាក់ចំនួន៥០,០០០$ , ប្រាក់រៀលចំនួន២លានរៀល , ឯកសារប្លង់ដីមួយចំនួន , សៀវភៅធនាគារចំនួន៣ក្បាល និងបាត់ម៉ាស៊ីនស្កេនចំនួន១ផងដែរ រួចហើយពួកខ្លួនក៏បានយកលុយទៅចែកគ្នាអស់ ចំណែកឯកសារផ្សេងៗពួកគេបានយកទៅបោះចោលអស់ ដូច្នេះតំណាងអយ្យការនៅតែរក្សាការចោទប្រកាន់ទុក នៅដដែល ដោយជនជាប់ចោទឈ្មោះ , ឈ្មោះ ហៅ និងឈ្មោះ

ពីបទ លួចមានស្ថានទម្ងន់ទោស សមគំនិតក្នុងអំពើលួច ដោយសារការប្រព្រឹត្តអំពើហឹង្សា ប្រព្រឹត្តនៅចំណុច ក្រុមហ៊ុនស៊ីហ្គោលទេសចណ៍ និងពាណិជ្ជ ដែលមានទីតាំងនៅផ្ទះលេខ៤១BEo ផ្លូវលេខ៣៤៨ ក្រុម១៤ ភូមិ១៤ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី៩ .ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញាតិឲ្យផ្តន្ទាទោសតាមមាត្រា២៩និងមាត្រា ៣៥៣, ៣៥៧ នៃក្រមព្រហ្មទណ្ឌ ចំណែកឈ្មោះ ត្រូវជាប់ចោទពីបទ ទទួលផលចោរកម្ម ក្រុមហ៊ុនស៊ីហ្គោលទេសចរណ៍ និងពាណិជ្ជ ដែលមានទីតាំងនៅផ្ទះលេខ៤១BEo ផ្លូវលេខ៣៤៨ ក្រុម១៤ ភូមិ១៤ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញាតិឲ្យផ្តន្ទាទោសតាមមាត្រា៣៩៩,៤០០ នៃក្រមព្រហ្មទណ្ឌ ។

-មេធាវីការពារឲ្យជនជាប់ចោទឈ្មោះ , ឈ្មោះ ហៅ និងឈ្មោះ បានធ្វើសេចក្តីសន្និដ្ឋានការពារសិទ្ធិថា : កូនក្តីរបស់ខ្ញុំបានឆ្លើយសារភាពនៅគ្រប់ដំណាក់កាលថាខ្លួនពិតជាបានលួចគាស់ទ្វាក្រុមហ៊ុនស៊ីហ្គោលទេសចរណ៍ និងពាណិជ្ជពិតប្រាកដមែនដូច្នេះសុំឲ្យលោកប្រធានក្រុមប្រឹក្សា មេត្តាជួយសម្រាលទោសឲ្យកូនក្តីខ្ញុំដោយអនុគ្រោះចំណែកខ្ញុំឈ្មោះ ខ្លួនមិនបានដឹងអីទេសូមឲ្យលោកប្រធានក្រុមហ៊ុនមេត្តាលើកលែងឲ្យកូនក្តីខ្ញុំរួចខ្លួនពីបទចោទ ។

*-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ*

*-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ*

*-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារឲ្យជនជាប់ចោទ*

*-ក្រោយពីបានពិនិត្យភស្តុតាង និងឯកសារនានាក្នុងសំណុំរឿង*

*-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ*

*-ក្រោយពីក្រុមប្រឹក្សាបានពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់ហើយ*

**<u>សាលាដំបូងរាជធានីភ្នំពេញ</u>**

**<u>យល់ឃើញថា</u>**

១/តាមរបាយការណ៍សំយោគលេខ២០៩ រ.ប.ក ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៥ របស់អធិការដ្ឋាននគរបាលខណ្ឌចំការមន នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ បានសន្និដ្ឋានថា: ផ្អែកតាមរបាយការណ៍នគរបាលប៉ុស្តិ៍ តាមពាក្យបណ្តឹងរបស់ជនរងគ្រោះ និងតាមចម្លើយសារភាពរបស់ជនជាប់ចោទឃើញថាឈ្មោះ និងឈ្មោះ

ពិតជាបានប្រព្រឹត្តអំពើលួចមានស្ថានទម្ងន់ទោស (គាស់សោទ្វាក្រុមហ៊ុនលួចទូដែក) កាលពីវេលាម៉ោង៣,១៥នាទី រំលងអាធ្រាតឈានចូលថ្ងៃ ទី៩ ខែតុលា ឆ្នាំ២០១៥ នៅចំណុចក្រុមហ៊ុនទេសចរណ៍ និងពាណិជ្ជដែលមានទីតាំងស្ថិតនៅផ្ទះលេខ៤១BEo ផ្លូវ៣៤៨ ក្រុម១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ ប្រាកដមែនចំណែកជនជាប់ចោទឈ្មោះ ពិតជាបានសមគំនិត ផ្តល់មធ្យោបាយធ្វើសកម្មភាព និងទទួលផលចោលរកម្មក្នុងករណីនេះប្រាកដមែនរីឯជនជាប់ឈ្មោះ ដែលជាប្រពន្ធរបស់ជនជាប់ចោទឈ្មោះ ក៏ជាអ្នកទទួលផលចោរកម្មក្នុងករណីខាងលើនេះដែរ ។

២-តាមចម្លើរបស់ជនជាប់ចោទឈ្មោះ ឆ្លើយថា: កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ វេលាម៉ោងប្រហែល៣,១៥នាទីខ្លួនពិតជាបានធ្វើសកម្មភាពគាស់ទ្វាក្រុមហ៊ុននៅម្តុំទួលស្វាយព្រៃដោយលួចបានទូរដែកប្រាកដមែន ។ មុនដំបូងឈ្មោះ បានយកម៉ូតូមួយ គ្រឿងម៉ាកសេ១០០ក្បរ៉េផ្លើលពណ៌ក្រហមគ្មានស្លាកលេខពីឈ្មោះ ( ) មកតកន្ទុយរ៉ឺម៉កខ្លួនបានដឹកបក្ខពួកផ្សេងទៀតឈ្មោះ , , និងដើររកគាស់ផ្ទះរបស់គេយកទ្រព្យសម្បត្តិ ។ ពេលខ្លួនធ្វើដំណើរមកដល់ទួលស្វាយព្រៃក៏បានឃើញក្រុមហ៊ុនរបស់គេចាក់សោនៅខាងក្រៅ ពេលនោះពួកខ្លួនក៏បានឈប់ម៉ូតូហើយក៏បានយកទូឡឺវីសមកឆ្កឹះសោសូឡិចទ្វាខាងមុខ ចំណែកឈ្មោះ ឆ្កឹះសោទ្វាខាងក្នុងរួចបាននាំគ្នាចូលទៅក្នុង ក្រុមហ៊ុនរើកកាយនិងលួចយកបានទូរដែក១នៅជាន់ខាងលើហើយក៏នាំគ្នាដឹកតាមរ៉ឺម៉កទៅ ផ្ទះរបស់ឈ្មោះ ដើម្បីគាស់បានឃើញលុយជាច្រើន និងឯកសាផ្សេងទៀត រួចហើយបានចែកលុយគ្នាខ្លួនទទួលបានប្រាំពាន់ដុល្លាអាមេរិក រីឯឯកសារទាំងនោះត្រូវបានដុតចោល បន្ទាប់មកខ្លួនយកលុយចំនួន៤ពាន់

ដុល្លារអាមេរិក ទៅផ្ញើនិងឈ្មោះ នៅសល់ប៉ុន្មានខ្លួនបានយកទៅចាយវាយ និងចែកអ្នកជិតខាងនៅស្វាយរៀង លុះដល់ថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៥ ម៉ោងប្រហែល ១៣,០០នាទីរសៀលពេលដែលខ្លួនកំពុងអង្គុយលេង ជាមួយឈ្មោះ និងឈ្មោះ ស្រាប់តែមានសមត្ថកិច្ចមក ឃាត់ខ្លួនតែម្តង ចំណែកឈ្មោះ បានរត់គេចខ្លួនបាត់ ។

៣/តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ ឆ្លើយថា: កាលពីថ្ងៃទី ០៩ ខែ តុលា ឆ្នាំ២០១៥ ខ្លួនពិតជាបានយកម៉ូតូទៅឈ្មោះ ជិះធ្វើសកម្មភាពគាស់ផ្ទះរបស់គេលួចទូរដែកប្រាក់ដមែន ។ មុនដំបូងនៅល្ងាចថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៥ឈ្មោះ បានឲ្យទូរសព្ទ័មកខ្លួនឲ្យយកទៅគេនៅម្តុំច្បាររអំពៅ ពេលនោះក៏បានជិះម៉ូតូម៉ាក សង់សេ១០០ ក្រវ៉ាផ្លើសពណ៌ក្រមគ្មានស្លាកលេខ ហើយឈ្មោះ ក៏បានខ្ចីម៉ូតូខ្លួនជិះរួចខ្លួនក៏បានជិះម៉ូតូរបស់ឈ្មោះ ត្រលប់មកផ្ទះវិញ មូលហេតុដែលឈ្មោះ ខ្ចីម៉ូតូរគឺម៉ូតូរបស់ខ្លួនមានប្រដាប់សន្តោងរ៉ឺម៉កស្រាប់ ។ លុះព្រឹកថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ វេលាម៉ោងប្រហែល៧,០០នាទីឈ្មោះ បានទូរសព្ទ័ប្រាប់ខ្លួនថាឲ្យមកយកម៉ូតូ និងបានឲ្យលុយខ្លួនចំនួន១លានរៀល ។ រហូតដល់ថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៥ ម៉ោងប្រហែល១៣,០០នាទី ខ្លួនក៏បានជិះម៉ូតូមកអង្គុយ លេងជាមួយឈ្មោះ ... និងឈ្មោះ នៅផ្ទះរបស់ឈ្មោះ ស្រាប់តែមានសមត្ថកិច្ចមកឃាត់ខ្លួនជាមួយឈ្មោះ នាំមកតែម្តង ចំណែកឈ្មោះ បាន រត់គេចខ្លួនបាត់ ។

៤/តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ ឆ្លើយថា: ខ្លួនពិតជាបានចូលរួមគាស់ផ្ទះគេពិតមែន និងមានគ្នាទាំងអស់៥នាក់ក្នុងនេះមានឈ្មោះ ឈ្មោះ , ឈ្មោះ ...,ឈ្មោះ .. ហៅ .. ។ ពេលនោះពួកខ្លួនលួចបានទូដែក១ យកទៅបើកនៅផ្ទះខ្លួន ក្នុងនោះមានលុយចំនួន៥០,០០០$ រួចហើយក៏បានចែកគ្នា ដោយខ្លួនបានចំនួន ១០,០០០$ លុះ សល់ពីនោះទុកឲ្យបក្សពួក៤នាក់ទៀតចែកគ្នា ចំណែកទូរដែកនេះបានបោះចោល ជាមួយឯកសារនៅក្បែរវត្តច្បាររអំពៅ ។

៥/តាមចម្លើយបណ្តឹងរដ្ឋប្បវេណីឈ្មោះ .. ឆ្លើយថា: កាលពី ថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៥ខ្លួនបានចេញពីក្រុមហ៊ុនដែលមានទីតាំងផ្ទះលេខ៤១BEo ផ្លូវលេខ ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ ត្រលប់ទៅសម្រាក់នៅផ្ទះលុះដល់ម៉ោងប្រហែល៤,០០នាទីទាបភ្លឺ ចូលថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ ពេលខ្លួនកំពង់សម្រាកក៏មានសមត្ថកិច្ចបានទូរសព្ទ័ប្រាប់ថា ក្រុមហ៊ុនរបស់ខ្លួនត្រូវមានចោរលួចគាស់ទ្វា ពេលនោះខ្លួនក៏បានមកមើល ទើបទឹងថាបាត់ទូរដែកចំនួន១ ហើយក្នុងទូរដែកនេះ មានប្រាក់ចំនួន៥០,០០០$ , ប្រាក់រៀលចំនួន២លានរៀល , ឯកសារប្លង់ដីមួយចំនួន , សៀវ ភៅធនាគារចំនួន៣ក្បាល និងបាត់ម៉ាស៊ីនស្កេនចំនួន១ផងដែរ ។

៦/តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ ,ឈ្មោះ . , ឈ្មោះ

បានឆ្លើយស៊ីសង្វាក់ទៅនឹងចម្លើយរបស់បណ្តឹងរដ្ឋប្បវេណី , ចម្លើយសាក្សីនិងភស្តុ តាងនានានៅក្នុងសំណុំរឿងថាជនជាប់ចោទពិតជាបានប្រព្រឹត្តអំពើលួចគាស់ទ្វាក្រុមហ៊ុនស៊ី ហ្គោលទេសចរណ៍ និងពាណិជ្ជ ពិតប្រាកដមែន ។

៧/ជនជាប់ចោទមានស្មារតីល្អនៅពេលប្រព្រឹត្តបទល្មើស អំពើប្រព្រឹត្តរបស់ជនជាប់ជាប់ចោទឈ្មោះ , ឈ្មោះ "..ពី , ឈ្មោះ . . ...., និងឈ្មោះ. .

បានធ្វើឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និងសណ្តាប់ធ្នាប់សង្គមយ៉ាង

ធ្ងន់ធ្ងរដែលដែលធ្វើឲ្យបាត់បង់ទ្រព្យសម្បត្តិរបស់ជនរងគ្រោះ និងផ្ទុយទៅនឹងច្បាប់កំណត់ ។

៨/ជនជាប់ចោទឈ្មោះ និងជនជាប់ចោទឈ្មោះ ជាអនីតិជនតុលាការគប្បីពិចារណាពីស្ថានសម្រាល ។

៩/តំណាងអយ្យការធ្វើសេចក្ដីសន្និដ្ឋានមានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

១០/មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ ភេទប្រុស អាយុ១៤ឆ្នាំ ជនជាតិខ្មែរ , ឈ្មោះ ហៅ ភេទប្រុស អាយុ២៧ឆ្នាំ ជាតិខ្មែរ ពីបទ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុច ក្រុមហ៊ុនស៊ីហ្គោលទេសចរណ៍ និងពាណិជ្ជ ដែលមានទីតាំងនៅផ្ទះលេខ៤១BEo ផ្លូវលេខ៣៤៨ ក្រុម១៤ ភូមិ១៤ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញាតិឲ្យផ្ដន្ទាទោសតាមមាត្រា៣៥៣, ៣៥៧ នៃក្រមព្រហ្មទណ្ឌ , ឈ្មោះ ហៅ ភេទប្រុស អាយុ១៥ឆ្នាំ ជាតិខ្មែរ ត្រូវជាប់ចោទពីបទ សមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រ ព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គោលទេសចរណ៍ និងពាណិជ្ជ ដែលមានទីតាំងនៅផ្ទះលេខ៤១BEo ផ្លូវលេខ៣៤៨ ក្រុម១៤ ភូមិ១៤ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញាតិឲ្យផ្ដន្ទាទោសតាមមាត្រា២៩,៣៥៣, ៣៥៧ នៃក្រមព្រហ្មទណ្ឌ និងឈ្មោះ ភេទស្រី អាយុ២២ឆ្នាំ ជាតិខ្មែរត្រូវជាប់ចោទពីបទ ទទួលផលចោរកម្ម ក្រុមហ៊ុនស៊ីហ្គោលទេសចរណ៍ និងពាណិជ្ជ ដែលមានទីតាំងនៅផ្ទះលេខ៤១BEo ផ្លូវលេខ៣៤៨ ក្រុម១៤ ភូមិ១៤ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញាតិឲ្យផ្ដន្ទាទោសតាមមាត្រា៣៩៩,៤០០ នៃក្រមព្រហ្មទណ្ឌ ។

១១/វត្ថុចាប់យកមាន:

១១.១/ម៉ូតូមួយគ្រឿងម៉ាក CITY Pluo ពណ៌ក្រហមគ្មានស្លាកលេខៗម៉ាស៊ីន ០១៧៤៤៦ (ម៉ូតូចាស់មានកែត្យ) និង អង្គចងចាំចំនួន១ គប្បីប្រគល់ឲ្យម្ចាស់ដើមវិញ ។

១១.២/ញញួរចំនួន២ , ដែកដាប់ចំនួន៣ , ដែកគាស់ចំនួន១ , កន្ត្រៃចំនួន១ , កូនកាំបិតចំនួន២ , កាំបិតតាំងតោចំនួន៤ , ដាវចំនួន១ និងដបសម្រាប់ដក់គ្រឿងញៀនចំនួន១តុលាការគប្បីសម្រេចរឹបអូស ។

១២/ដើមបណ្ដឹងសុំទាមទារសំណង ជាប្រាក់ដែលបានបាត់បង់ចំនួន ៥០,០០០$ (ប្រាំម៉ឺនដុល្លារអាមេរិក) ,លុយខ្មែរចំនួន២,០០០,០០០រៀល (ពីរលានរៀល) និងសម្ភារៈដែល បានបាត់បង់ជាឯកសារ តុលាការគប្បីសម្រេចតាមច្បាប់ ។

<u>**ហេតុដូច្នេះសាលាដំបូងរាជធានីភ្នំពេញ**</u>

**វិនិច្ឆ័យសេចក្ដី**

១/ផ្ដន្ទាទោស:

១.១/ឈ្មោះ ភេទប្រុស <u>អាយុ១៤ឆ្នាំ</u> ជនជាតិខ្មែរដាក់ពន្ធនាគារកំណត់រយៈ០២ឆ្នាំ (ពីរឆ្នាំ) និងឈ្មោះ ហៅ ភេទប្រុស អាយុ២៧ឆ្នាំ ជាតិខ្មែរដាក់ពន្ធនាគារក្នុងម្នាក់កំណត់រយៈពេល០៤ឆ្នាំ (បួនឆ្នាំ) ពីបទ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុច ក្រុមហ៊ុនស៊ីហ្គោលទេសចរណ៍ និងពាណិជ្ជ ដែលមានទីតាំងនៅផ្ទះលេខ៤១BEo ផ្លូវលេខ៣៤៨ ក្រុម១៤ ភូមិ១សង្កាត់ ទួលស្វាយព្រៃ

១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា៣៥៣, ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

១.២/ផ្តន្ទាទោសលើឈ្មោះ ហៅ ភេទប្រុស <u>អាយុ១៥ឆ្នាំ</u> ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល០២ឆ្នាំ (ពីរឆ្នាំ) ពីបទ សមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គោលទេសចរណ៍ និងពាណិជ្ជ ដែលមានទីតាំងនៅផ្ទះលេខ៤១BEo ផ្លូវលេខ៣៤៨ ក្រុម១៤ ភូមិ១៤ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា២៩,៣៥៣, ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

១.៣/ផ្តន្ទាទោសលើឈ្មោះ ភេទស្រី អាយុ២២ឆ្នាំ ជាតិខ្មែរដាក់ពន្ធនាងគារកំណត់តយៈពេល ០៣ឆ្នាំ (បីឆ្នាំ) ពីបទ ទទួលផលចោរកម្ម ក្រុមហ៊ុនស៊ីហ្គោលទេសចរណ៍ និងពាណិជ្ជ ដែលមានទីតាំងនៅផ្ទះលេខ៤១BEo ផ្លូវលេខ៣៤៨ ក្រុម១៤ ភូមិ១៤ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា៣៩៩,៤០០ នៃក្រមព្រហ្មទណ្ឌ ។

២/វត្ថុចាប់យកមាន:

២.១/ម៉ូតូមួយគ្រឿងម៉ាក CITY Pluo ពណ៌ក្រហមគ្មានស្លាកលេខ ម៉ាស៊ីន ០១៧៤៤៦ (ម៉ូតូចាស់មានកែត្បូ) និង អង្គចងចាំចំនួន១ ប្រគល់ឲ្យម្ចាស់ដើមវិញ ។

២.២/ញញួរចំនួន២ , ដែកដាប់ចំនួន៣ , ដែកគាស់ចំនួន១ , កន្ត្រៃចំនួន១ , កូនកាំបិតចំនួន២ , កាំបិតតាំងតោចំនួន៤ , ដាវចំនួន១ និងដបសម្រាប់ដក់គ្រឿងញៀនចំនួន១រឹបអូស ។

៣/បង្គាប់ឲ្យឈ្មោះ , ឈ្មោះ ,ឈ្មោះ និងឈ្មោះ រួមគ្នាសងសំណងដែលបានបាត់បង់ទៅឲ្យដើមបណ្តឹងរដ្ឋប្បវេណី ចំនួន ៥០,០០០$ (ប្រាំម៉ឺនដុល្លាអាមេរិក) , លុយខ្មែរចំនួន ២,០០០,០០០រៀល (ពីរលានរៀល) និងសម្ភារៈ ដែល បានបាត់បង់ជាឯកសារ ទាមទារលើសពីនេះបដិសេធន៍ចោល ។

៤/បង្គាប់ឲ្យចេញដីកាចាប់នឹងឃុំខ្លួនឈ្មោះ ដើម្បីអនុវត្តទោសតាមអំណាចសាលក្រមតាមមាត្រា៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

-សាលក្រមនេះជំនុំជំរះនៅថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១៦ និងប្រកាសជាសាធារណៈនៅថ្ងៃទី២២ខែមេសា ឆ្នាំ ២០១៦ចំពោះមុខជនជាប់ចោទឈ្មោះ , ឈ្មោះ និងឈ្មោះ កំបាំងមុខជនជាប់ចោទឈ្មោះ និងដើមបណ្តឹងរដ្ឋប្បវេណីទុកសិទ្ធិប្តឹងទាស់ និងបើផ្លូវប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
| --- | --- | --- | --- |
| ហត្ថលេខានិងត្រា | ហត្ថលេខានិងត្រា | ហត្ថលេខានិងត្រា | ហត្ថលេខានិងត្រា |

បានឃើញ
ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"
រាជធានីភ្នំពេញ ថ្ងៃទី២២ខែមេសា ឆ្នាំ២០១៦
ក្រឡាបញ្ជី